ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ការអប់រំពីសន្តិភាព និងសិទ្ធិមនុស្ស
- អង្គជំនុំជម្រះតុលាការកំពូលតម្កល់ការផ្តន្ទាទោសឱ្យជាប់ឃុំឃាំង

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២០៤ ខែធ្នូ ឆ្នាំ២០១៦

ស្វែងរកការពិត

លេខ២០៤ ខែធ្នូ ឆ្នាំ២០១៦

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ ការអប់រំពីសន្តិភាព និងសិទ្ធិមនុស្ស ........................................................ ១

### ផ្នែកឯកសារ

◆ ចម្លើយសារភាព អ៊ឹម យឿត អតីតគ្រូបង្រៀន ................................. ៧

◆ វាយសម្រុកឲ្យខ្លាំងក្លាថែមទៀត តាមមាគ៌ាសកម្មត្រឹមត្រូវ ................ ១០

### ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ

◆ នៅសល់តែភាពសោកស្តាយ និងអាឡោះអាល័យ ............................ ១៤

◆ នៅរស់ជីវិតដោយសារអំពើល្អ .................................................. ១៦

◆ បានឃើញត្រឹមចម្លើយសារភាព ................................................ ១៨

◆ ហ៊ាន ដានី ៖ ការបាត់បង់ដោយមិនដឹងខ្លួន ................................ ២១

◆ ជីវិតយាយ យ៉ាត ក្នុងរបបខ្មែរក្រហម ........................................ ២៣

◆ ឈ្លបចោទម្តាយខ្ញុំថា “ចោរ” ...................................................... ២៥

◆ ការប្រែប្រួលបរិស្ថាននៅអន្លង់វែងក្នុងពេលបច្ចុប្បន្ន .......................... ២៦

◆ ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង ................................................. ២៨

### ផ្នែកច្បាប់

◆ “ខ្ញុំចាប់ផ្តើមវាយប្រហារ ប៉ុល ពត” ............................................ ៣៨

### វេទិកាពិភាក្សាសាធារណៈ

◆ អង្គជំនុំជម្រះតុលាការកំពូលតម្កល់ការផ្តន្ទាទោសឲ្យជាប់ឃុំ ................. ៤៣

### ទំព័រស្រាវជ្រាវរកគ្រួសារ

◆ គេរងរំពៃលដេះផងសល់ពីរបបខ្មែរក្រហម ...................................... ៥១

◆ “សល់មួយគ្រាប់” ..................................................................... ៥៧



យុទ្ធនារីបដិវត្តន៍ខ្មែរក្រហម

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ ៖*** គ្រីស្តូហ្វ័រ ឌៀរីង, ឌី ខាំបូលី, ហេង ទីតា, វ៉ា សាម៉េត, វ៉ាង ពិសិដ្ឋ, ប៉ោ សន្តិភាព, លីអូនី គីដេស្តី, សៀវ សុផន, ហែម សុវណ្ណារិទ្ធិ ***អ្នកនិពន្ធនិងស្រាវជ្រាវ ៖*** ទាវ សារៈមុនិន្ទ ***អ្នកបកប្រែ ៖*** ឈឹម អមរ័ត្ន និង អែម សីលា ***និពន្ធនាយកទូទៅ ៖*** ឆាំង យុ ***ជំនួយការនិពន្ធនាយក ៖*** សោម ប៊ុនថន ***ក្រាហ្វិកកុំព្យូទ័រ ៖*** សោម ប៊ុនថន ***គ្រប់គ្រងការចែកផ្សាយ ៖*** ផេង ពង្សរ៉ាស៊ី និង សន ល័ក្ខ **Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org**

# ការអប់រំសន្តិភាព និងសិទ្ធិមនុស្ស

មជ្ឈមណ្ឌលឯកសារកម្ពុជាប្រមើលមើលកម្មវិធីសិក្សាអំពីសន្តិភាពមួយ ដែលបំពេញបន្ថែមដល់សេចក្តីថ្លែងការណ៍របស់អាស៊ានស្តីពីចលនាសកលនៃភាពអព្យាក្រឹត្យ និងសន្ធិសញ្ញាដទៃទៀតដែលត្រូវបានទទួលស្គាល់ជាសកលដូចជា អនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិមនុស្សក្នុងសហគមន៍អាស៊ាន ។ កម្មវិធីនេះនឹងបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ប្រទេសជាសមាជិកចំពោះសិទ្ធិមនុស្ស និងសម្រេចបានការទទួលស្គាល់ពីប្រជាជនងាយរងគ្រោះបំផុតពោលគឺយុវជនរបស់យើង ។

បទពិសោធន៍របស់កម្ពុជាចំពោះអំពើប្រល័យពូជសាសន៍ក៏នឹងមានតួនាទីជាសំអាងដ៏សំខាន់ចំពោះកម្មវិធីសិក្សានេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជារំពឹងនូវតួនាទីសម្របសម្រួលចម្បងមួយនៅក្នុងកម្មវិធីសិក្សាអំពីសន្តិភាព និងសិទ្ធិមនុស្សសម្រាប់តំបន់អាស៊ាន តាមរយៈការរៀបចំការសម្របសម្រួល និងការផ្តល់នូវជំនាញបច្ចេកទេស ។

ប្រសិនបើត្រូវបានបង្កើតឡើង កម្មវិធីសិក្សានេះនឹងប្រកបដោយភាពបង្កើតថ្មី និងនិរន្តរភាព ។ វានឹងដើរតួនាទីជាគំរូមួយសម្រាប់ប្រទេស និងតំបន់ដទៃទៀត ក្នុងការឆ្លើយតប និងរារាំងចំពោះភេរវកម្ម អំពើឃោរឃៅទ្រង់ទ្រាយធំ ព្រមទាំងអំពើហិង្សា និងគំនិតជ្រុលនិយម ។

ស្របពេលនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងស្វះស្វែងរកការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីរៀបចំវេទិកាមួយរំពុកអំពីច្បាប់ស្តីពីសិទ្ធិមនុស្សសំខាន់ៗ ។ ជាពិសេស យើងមានបំណងរំលេចឡើងអំពីអនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ជាអនុសញ្ញាដ៏ចាំបាច់មួយដែលផ្តន្ទា និងរារាំងអំពើប្រល័យពូជសាសន៍ក្នុងរយៈពេលជាង៦០ឆ្នាំកន្លងមកហើយ ។ យើងក៏ប៉ុនប៉ងទាញយកចំណាប់អារម្មណ៍ចំពោះសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិមនុស្សរបស់សហគមន៍អាស៊ានដែលធ្វើឡើងនាពេលថ្មីៗនេះដែរ ។ យើងមានការរំពឹងចំពោះការដឹកនាំវេទិកាមួយដែលមានកិច្ចសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ជាភាគីដែលបានអនុវត្តអនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅក្នុងឆ្នាំ១៩៥០ និងបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិមនុស្សរបស់សហគមន៍អាស៊ាន នៅខែវិច្ឆិកា ឆ្នាំ ២០១២ ។ អនុសញ្ញាដែលលើកឡើងដំបូង តំណាងឲ្យមូលដ្ឋានគ្រឹះមួយនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិបែបទំនើប ។ ចំណែកឯសេចក្តីថ្លែងការណ៍ខាងលើវិញ បង្ហាញអំពីការប្តេជ្ញាថ្នាក់តំបន់បន្តទៀត ចំពោះសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរជាមូលដ្ឋាន ។


កងចល័តកុមារ ។ ក្រោយរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ កុមាររាប់សែននាក់ បានក្លាយជាក្មេងកំព្រា ។ រូបថតឆ្នាំ១៩៧៨ ដោយ ហ្កុនណា បឺយស្រ្តម

**មជ្ឈមណ្ឌលឯកសាកម្ពុជា**

# ចម្លើយសារភាព អ៊ឹម យឿត អតីតគ្រូបង្រៀន និងជាប្រជាជនថ្មីស្រុកភ្នំសំពៅ តំបន់៣ ភាគពាយ័ព្យ

***ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ J០០៥៨៦***

អ៊ឹម យឿត មុនរបបខ្មែរក្រហម ធ្វើជាគ្រូបង្រៀន ហើយនៅក្នុងរបបខ្មែរក្រហម យឿត ត្រូវបានអង្គការចាត់ជាប្រជាជនថ្មី និងរស់នៅស្រុកភ្នំសំពៅ តំបន់៣ ភូមិភាគពាយ័ព្យ ។ នៅក្នុងចម្លើយសារភាពរបស់ យឿត ដែលមានចំនួន៣៣ទំព័រ យឿត បានរៀបរាប់ពីសកម្មភាពរបស់ខ្លួនក្នុងការប្រឆាំងនឹងអង្គការ ការរៀបចំគម្រោង និងខ្សែសង្វាក់ចំនួន៣៩នាក់ផ្សេងទៀតក្នុងការធ្វើសកម្មភាពនេះ ។ យឿត ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៧៧ នៅពេលដែល យឿត បម្រុងរត់ទៅប្រទេសសៀម ។ យឿត ត្រូវបានបញ្ជូនបន្តមកភ្នំពេញនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៧ ។ ខាងក្រោមនេះជាសេចក្តីសង្ខេបចេញចម្លើយសារភាពរបស់ អ៊ឹម យឿត អំពីសកម្មភាពប្រឆាំងនឹងអង្គការ ៖

អ៊ឹម យឿត ហៅ អ៊ិម សុផាន់ណា អាយុ៤៥ឆ្នាំ ជាអតីតគ្រូបង្រៀនសាលាបឋមសិក្សា ។ យឿត មានគ្រួសារហើយ និងមានស្រុកកំណើតនៅឃុំភ្នំសំពៅ ស្រុកភ្នំសំពៅ ខេត្តបាត់ដំបង ។ នៅឆ្នាំ១៩៥១ ដល់ឆ្នាំ១៩៥៦ យឿត បានសិក្សានៅមធ្យមសាលាបឋមសិក្សាបាត់ដំបងក្រុង និងឆ្នាំ១៩៦០ គាត់បានផ្លាស់មកសិក្សានៅវិទ្យាល័យព្រះមុនីវង្ស ។ ឆ្នាំ១៩៦១ យឿត បានសិក្សានៅសាលាគរុកោសល្យខាងជើង ផ្នែកអប់រំគ្រូបង្រៀននៅភ្នំពេញ និងបានចេញទៅបង្រៀននៅវិទ្យាល័យកំពង់ឆ្នាំង នៅឆ្នាំដដែល ។



បូជនីយដ្ឋានតម្កល់អដ្ឋិធាតុជនរងគ្រោះនៅវត្តកកោះ អតីតមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស ស្ថិតនៅខេត្តបាត់ដំបង ភូមិភាគពាយ័ព្យ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

## សកម្មភាពរបស់ យឿត និងបក្សពួក

រយៈពេលបីឆ្នាំដែល យឿត រស់នៅកំពង់ឆ្នាំង គាត់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងសាស្ត្រាចារ្យបីនាក់មានឈ្មោះ ពេជ ប៊ុន, ទុំ ប៉ុង និង ម៉ា គិមហ៊ាន ។ នៅឆ្នាំ១៩៦៤ ឈ្មោះ ឡឹក វ៉ា មាននាទីជាមេបញ្ជាការផ្នែកសឹករងកំពង់ឆ្នាំង បានមកទាក់ទងសម្ងាត់ជាមួយនឹងអ្នកទាំងបួន ដើម្បីអូសទាញចូល សេ.អ៊ី.អា និងបានលើកយកពីផលវិបាកផ្សេងៗនៃលទ្ធិក្រហមមកនិយាយ ។ នៅខែសីហា ឆ្នាំ១៩៦៤ ឡឹក វ៉ា បានធ្វើពិធីបញ្ចូលអ្នកទាំងបួនជាភ្នាក់ងារ សេ.អ៊ី.អា ពេញសិទ្ធិ ដែលមាន ទួន ឡាង អភិបាលខេត្តកំពង់ឆ្នាំង ជាអ្នកទទួលស្គាល់ ។ ឡឹក វ៉ា ក៏បានណែនាំឲ្យអ្នកទាំងបួនឲ្យស្គាល់នូវខ្សែ សេ.អ៊ី.អា ចាស់ៗមួយចំនួនដូចជា សុក ហេង និង ប្រាក់ សំអឿន ហើយបានប្រគល់ភារកិច្ចឲ្យអ្នកទាំងអស់គ្នាធ្វើគឺ៖

◆ តាមដានសកម្មភាពគ្រូ និងសិស្ស ក្នុងវិទ្យាល័យទាំងមូល

◆ អប់រំ ពន្យល់ណែនាំគ្រូ និងសិស្សក្នុងវិទ្យាល័យឲ្យប្រឆាំងនឹងចលនាខ្មែរក្រហម

◆ កសាងកម្លាំង សេ.អ៊ី.អា ក្នុងចំណោមគ្រូ និងសិស្ស

ក្នុងសកម្មភាពនេះ យឿត, ទុំ ប៉ុង, ពេជ ប៊ុន និង ម៉ា គិមហ៊ាន បានពិនិត្យតាមដានក្នុងចំណោមគ្រូ និងសិស្ស តែមិនឃើញមានខ្មែរក្រហមបន្លំចូលទេ ។ ហេតុនេះក៏មិនមានការចាប់ខ្លួនគ្រូ និងសិស្សដែរ ។ អ្នកទាំងបួនតែងតែធ្វើការអប់រំគ្រូ និងសិស្សឲ្យប្រឆាំងនឹងចលនាខ្មែរក្រហម នៅម៉ោងសម្រាក ឬបង្រៀនមេរៀនចប់ ។ យឿត បានអប់រំសិស្សម្នាក់ ឈ្មោះ ស៊ិន សឿន ឲ្យចូល សេ.អ៊ី.អា ហើយនៅខែធ្នូ ឆ្នាំ១៩៦៤ យឿត បានបញ្ចូល ស៊ិន សឿន ចូលជាសមាជិក សេ.អ៊ី.អា ពេញសិទ្ធិ ដោយមាន ឡឹក វ៉ា ជាអ្នកខទ្មេសនាម និង ទួន ឡាង ជាអ្នកទទួលស្គាល់ ។

នៅឆ្នាំ១៩៦៥ អ្នកទាំងបួន និង ស៊ិន សឿន បានយកភារកិច្ចបីមកអនុវត្តនៅវិទ្យាល័យដូចតទៅ៖

◆ តាមដានខ្មែរក្រហមក្នុងចំណោមគ្រូ និងសិស្សក្នុងវិទ្យាល័យ

◆ ប្រឆាំងនឹងខ្មែរក្រហម ដោយខិតខំពន្យល់ណែនាំគ្រូ និងសិស្សឲ្យប្រឆាំងដាច់ខាតនឹងខ្មែរក្រហម ដោយបានលើកយកពីជីវភាពរបស់ប្រជាជនក្នុងលទ្ធិក្រហមមកបញ្ជាក់ផង ។

◆ កសាងកម្លាំងថ្មី ដោយណែនាំគ្រូ និងសិស្សដើម្បីទាក់ទាញកម្លាំងថ្មី ក្នុងនោះ ប៉ុង និង គិមហ៊ាន បានទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងសិស្សបីនាក់ឈ្មោះ ម៉ក រេត, ហោ ឡឹង និង ចាន់ សោម ។ បន្ទាប់ពីទទួលការអប់រំរួចមក សិស្សទាំងបីនាក់នេះបានស្ម័គ្រចិត្តចូលរួមក្នុងចលនា សេ.អ៊ី.អា នៅឆ្នាំ១៩៦៥ ដោយមាន ឡឹក វ៉ា ជាអ្នកទទួលស្គាល់ ។ នៅឆ្នាំ១៩៦៦ យឿត បានផ្លាស់ទៅបង្រៀននៅវិទ្យាល័យបាត់ដំបង ក្នុងខេត្តបាត់ដំបង ។ ពេលនោះ ឡឹក វ៉ា ក៏ណែនាំ យឿត ឲ្យស្គាល់ឈ្មោះ ឆាយ ឡាយ ជាមេបញ្ជាការយោធភូមិភាគទី៣ ដើម្បីបន្តខ្សែ និងទាក់ទងកម្លាំង សេ.អ៊ី.អា ។

## សកម្មភាពរបស់ យឿត នៅខេត្តបាត់ដំបង

ទៅដល់បាត់ដំបង ឆាយ ឡាយ បានណែនាំខ្សែរបស់ខ្លួន៥នាក់ឲ្យ យឿត ស្គាល់មាន ម៉ក ភឹន អតីតនាយកវិទ្យាល័យបាត់ដំបង, ចាន សយ, ហម សាប, ចាន់ សយ, អៀម រិត និង ខូវ សិរៈ ដែលអ្នកទាំង៥ នេះជាអតីតសាស្ត្រាចារ្យ ។ ម៉ក់ ភឹន និង ហម សាប បានចាត់ឲ្យ យឿត ទាក់ទង និងអប់រំសិស្សពីរនាក់ ឈ្មោះ ងួន ប៊ុនងី និង ហែម ស្រ៊ន ជាសម្ងាត់ ។ រហូតដល់ខែមីនា ឆ្នាំ១៩៦៦ យឿន និង ហម សាប បានស្នើទៅ ឆាយ ឡាយ ឲ្យបញ្ចូលសិស្សទាំងពីរជា សេ.អ៊ី.អា ដោយមាន យ៉ែម មុនីរតន៍ អភិបាលខេត្តបាត់ដំបង ជាអ្នកទទួលស្គាល់ ។

ឆ្នាំ១៩៦៧ យឿត និងកម្លាំង សេ.អ៊ី.អា ចាស់ថ្មីទាំងអស់ បានធ្វើសកម្មភាពឃ្លាំមើលសកម្មភាពផ្សេងៗរបស់គ្រូ និងសិស្សក្នុងវិទ្យាល័យទាំងមូលដើម្បីតាមដាន និងកុំឲ្យខ្មែរក្រហមចូលមកបន្លំធ្វើសកម្មភាពក្នុងវិទ្យាល័យបាន ។ យឿត និងក្រុម បានបន្តសកម្មភាពតាមដាន និងកសាងកម្លាំងបានជាបន្តបន្ទាប់ ។ ខែកុម្ភៈ ឆ្នាំ១៩៦៧ អៀម រិត និង ចាន់ សយ កសាងកម្លាំងសិស្សថ្នាក់ទីបញ្ចប់ពីរនាក់ឈ្មោះ កែវ ហេង និង សេ ទ្រី ដោយបានលើកយកពីបញ្ហាជីវភាពរស់នៅរវាងរបបទាំងពីរមកអប់រំ ។

នៅឆ្នាំ១៩៦៨ សកម្មភាពខ្មែរក្រហមបានផុសឡើងគ្រប់ជនបទ ។ នៅស្រុកសំឡូត ប្រជាជនរំដើបរំជួលខ្លាំង រដ្ឋាភិបាលបានយកកម្លាំងទ័ពទៅបង្ក្រាប ។ សិស្សនៅបាត់ដំបង បាននាំគ្នាប្រឆាំងដោយសរសេរបដាចងនៅមុខវិទ្យាល័យ សុំឲ្យរដ្ឋាភិបាលបញ្ឈប់ការបង្ក្រាបប្រជាជន ។ ក្នុងសកម្មភាពនេះ ក្រុមរបស់ យឿត

បានពិនិត្យតាមដានសកម្មភាពសិស្សទាំងនោះ រួចក៏ស្នើទៅ ឆាយ ឡាយ ឲ្យចាប់ខ្លួនសិស្ស៤នាក់ គឺ សោម ខេង, សេង ហាក់, ហែម ប៊ុនសេង និង ស៊ុយ តែម ដែលអ្នកទាំងបីគឺជាសិស្សថ្នាក់ទីបញ្ចប់ ។

នៅឆ្នាំ១៩៦៩ ម៉ក់ ភឺន ត្រូវផ្លាស់មកភ្នំពេញ ហើយ ខូវ សិរៈ ធ្វើជានាយកវិទ្យាល័យបាត់ដំបងជំនួស ។ ក្នុងពេលនោះ យឿត និង ខូវ សិរៈ អប់រំបានសិស្សពីរនាក់ទៀត គឺ សោម ប៊ុន និង ទ្រី ផល ។ នៅខែមីនា ឆ្នាំ១៩៦៩ យឿត បានបញ្ចូលសិស្សទាំងពីរខាងលើជា សេ.អ៊ី.អា ជាផ្លូវការ ដោយមាន សេក សំអៀត មេបញ្ជាការយោធភូមិភាគទី៣ និងជាអភិបាល ជាអ្នកខទ្ទេសនាម និងទទួលស្គាល់ ។

នៅខែឧសភា ឆ្នាំ១៩៧០ សេក សំអៀត បានចាត់ យឿត ឲ្យទៅធ្វើការនៅក្រសួងការពារជាតិ ដោយស្នើឲ្យតែងតាំងជាស័ក្តិ១បម្រុង ។ មួយរយៈក្រោយមក យឿត មានជំងឺឈាមជាទម្ងន់ និងត្រូវមកសម្រាកពេទ្យជាង៦ខែ ។ បន្ទាប់មក យឿត បានស្នើឈប់ធ្វើជាទាហានមកធ្វើការនៅនាយកដ្ឋានមធ្យមសិក្សាខេត្តបាត់ដំបងវិញ ។ នៅឆ្នាំ១៩៧១ ខូវ សិរៈ និង យឿត បានប្រជុំសមាជិក សេ.អ៊ី.អា ទាំងអស់ដើម្បីរៀបចំគម្រោងការថ្មី គឺពិនិត្យមើលសកម្មភាពខ្មែរក្រហមក្នុងចំណោមគ្រូ និងសិស្សនៅគ្រប់វិទ្យាល័យនៅបាត់ដំបង ។ ក្នុងសកម្មភាពនេះ សិរៈ និង យឿត បានអប់រំបានសាស្ត្រាចារ្យពីរនាក់ឈ្មោះ ឈា យួង សាស្ត្រាចារ្យវិទ្យាល័យនេត យ៉ង់ និង ធន់ នាវ៉ា សាស្ត្រាចារ្យវិទ្យាល័យ អ៊ាប យុត ។ នៅខែកុម្ភៈ ឆ្នាំ១៩៧១ សេក សំអៀត បានខទ្ទេសនាម និងទទួលស្គាល់អ្នកទាំងពីរជាសមាជិក សេ.អ៊ី.អា ជាផ្លូវការ ។

នៅឆ្នាំ១៩៧២ យឿត និងក្រុម នៅតែបន្តធ្វើសកម្មភាពតាមដានគ្រូ និងសិស្សនូទាំងវិទ្យាល័យដដែល ដើម្បីកុំឲ្យកម្លាំងខ្មែរក្រហមបន្ទំចូលមកធ្វើសកម្មភាពបាន ។ ការអប់រំពន្យល់ណែនាំគ្រូ និងសិស្សឲ្យប្រឆាំងនឹងខ្មែរក្រហមក៏ធ្វើជាប់ តាមពេលវេលា និងស្ថានការណ៍ហុចឲ្យ គឺនៅពេលចេញលេង ឬពេលទំនេរ ។ ដើម្បីប្រមូលកម្លាំងប្រឆាំងនឹងខ្មែរក្រហមបានច្រើនទៀត ខូវ សិរៈ និង អៀម រិត បានខំទាក់ទង និងពន្យល់ណែនាំសាស្ត្រាចារ្យម្នាក់ទៀតឈ្មោះ តូច យឿម ។ អ្នកទាំងពីរបានអប់រំ តូច យឿម ដោយលើកយកសារប្រយោជន៍នៃការប្រឆាំងនឹងខ្មែរក្រហមនេះ មកលាតត្រដាងឲ្យឃើញ គឺការពារសិទ្ធិសេរីភាពរបស់ប្រជាជន ការពារកេរដំណែលពីដូនតា និងការពារព្រះពុទ្ធសាសនា ។ បន្ទាប់ពីការអប់រំនេះមក តូច យឿម បានស្ម័គ្រចិត្តចូលជាសមាជិក សេ.អ៊ី.អា នៅខែមេសា ឆ្នាំ១៩៧២ ដោយមាន សេក សំអៀត ជាអ្នកទទួលស្គាល់ ។

ឆ្នាំ១៩៧៣ សមាគមគ្រូនៅបាត់ដំបងបានធ្វើបាតុកម្មទាមទារឲ្យរដ្ឋាភិបាលដំឡើងប្រាក់ខែ ដើម្បីទប់ទល់នឹងទំនិញឡើងថ្លៃ ដោយនាំឲ្យផ្អាកបង្រៀនសិស្សជាបណ្តោះអាសន្ន ។ ខូវ សិរៈ, តូច យឿម និង យឿត បានតាមដានរឿងនេះយ៉ាងហ្មត់ចត់ រួចរាយការណ៍ទៅឲ្យ សេក សំអៀត ។ នៅកុម្ភៈ ឆ្នាំដដែល យឿត បានកសាងកម្លាំងបានសិស្សពីរនាក់ទៀតមាន ហែម សូផុន និង គង់ ឆេង ដោយលើកយកពីបញ្ហា សេរីភាព និង សាសនា មកអប់រំ ។

ឆ្នាំ១៩៧៤ សកម្មភាពរបស់ខ្មែរក្រហមបានរីកដុសដាលយ៉ាងខ្លាំង នៅក្នុងក្រុងបាត់ដំបង ។ ជីវភាពប្រជាជនកាន់តែដុនដាបឡើង ដោយសារតែទំនិញឡើងថ្លៃ ។ ក្រុមសិស្សនៅបាត់ដំបងព្រមទាំងប្រជាជន បានធ្វើបាតុកម្មហែក្បួនតាមថ្នល់ដើម្បីប្រឆាំងរដ្ឋាភិបាលដែលបានអនុញ្ញាតឲ្យទំនិញឡើងថ្លៃ ហើយសុំឲ្យបញ្ចុះថ្លៃទំនិញនេះជាបន្ទាន់ ជាពិសេស គឺ អង្ករ និងគ្រឿងឧបភោគបរិភោគជាដើម ។ បាតុកម្មនេះបានរាលដាលរហូតដល់វាយកម្ទេច និងដុតបំផ្លាញហាងទំនិញខ្លះនៅក្នុងក្រុងបាត់ដំបង ។

ឆ្នាំ១៩៧៥ ក្រោយពីបានសន្តិភាពថ្ងៃ១៧ មេសា អង្គការជម្លៀសប្រជាជនចេញពីក្រុង និងតាមភូមិឲ្យទៅប្រកបរបរកសិកម្មនៅតាមស្រែចម្ការ ។ ពេលនោះ យឿត បាននាំគ្រួសារទៅនៅក្នុងភូមិស្រែកណ្តាល ឃុំឱម៉ាល់ ស្រុកភ្នំសំពៅ តំបន់៣ ភូមិភាគពាយ័ព្យ ដោយមាននាទីជាប្រជាជនថ្មី ។ ការរស់នៅទីនោះបានមួយរយៈ យឿត បានស្គាល់ និងទាក់ទងគ្នាសម្ងាត់ជាមួយឈ្មោះ រី នាទីប្រធានភូមិ ។ ដោយការទុកចិត្តគ្នា រី ហ៊ាននិយាយពីការមិនពេញចិត្តរបស់ខ្លួនចំពោះការគ្រប់គ្រងរបស់អង្គការប្រាប់ដល់ យឿត ។ រី ចង់រស់នៅដូចរបបចាស់វិញ ។ ក្រោយពីការផ្លាស់ប្តូរយោបល់គ្នាមក រី បានបង្ហាញពីគម្រោងការមួយ គឺការកែប្រែការរស់នៅខ្លះរបស់ប្រជាជនក្នុងភូមិឲ្យមានសភាពធូរស្រាលជាងអង្គការកំណត់ និងសេរីខ្លះដូចដើមវិញ ។ គម្រោងការនោះមានដូចតទៅ ៖



អដ្ឋិធាតុជនរងគ្រោះពីរបបខ្មែរក្រហម

◆ កែប្រែជីវភាពប្រជាជនក្នុងភូមិ ជាពិសេស គឺការហូបឲ្យមានសេរីភាពខ្លះដូចធម្មតាវិញ ។

◆ អប់រំណែនាំប្រជាជនឲ្យស្រឡាញ់របបចាស់ប្រឆាំងនឹងរបបបដិវត្តន៍ ។

◆ ទាក់ទងកសាងកម្លាំងឲ្យបានច្រើន ។

គម្រោងការនេះ ត្រូវអនុវត្តដោយស្ងាត់ៗ នៅក្នុងភូមិស្រែកណ្តាលតែប៉ុណ្ណោះ ។ ការអនុវត្តនូវគម្រោងនេះ វី បានចែកអង្ករឲ្យប្រជាជនដាំហូបដោយសេរីតាមគ្រួសារ គឺផ្ទុយពីទិសអង្គការដែលឲ្យដាំ និងហូបរួមនៅតាមក្រុមក្នុងភូមិទាំងមូល ។ សកម្មភាពនេះ វី និង យឿត ធ្វើជារៀងរាល់ថ្ងៃ ដោយពន្យល់ប្រាប់ប្រជាជនក្នុងភូមិឲ្យស្រឡាញ់របបសេរី ។ អ្នកទាំងពីរបានលើកយកការរស់នៅពីសង្គមចាស់មកប្រៀបធៀបនឹងការរស់នៅរបស់បដិវត្តន៍ ។ ក្រៅពីនេះ វី និង យឿត បានអប់រំប្រជាជនពីរនាក់ទៀតមាន ដាត ដួល អនុប្រធានភូមិ និង វ៉ែ រ៉ាំ ជាសមាជិកភូមិ ។ អ្នកទាំងពីរបានស្ម័គ្រចិត្តចូលរួមធ្វើការប្រឆាំងនឹងបដិវត្តន៍ដោយសម្ងាត់ផង ។

នៅឆ្នាំ១៩៧៦ វី, ដាត ដួល, វ៉ែ រ៉ាំ និង យឿត បានមកប្រជុំប្តូរយោបល់គ្នា និងបានសម្រេចយកគម្រោងការប្រឆាំងឆ្នាំ១៩៧៥ មកអនុវត្តបន្តទៀត ។ គម្រោងការនេះគឺ ៖

◆ ពន្យល់ណែនាំប្រជាជនឲ្យប្រឆាំងរបបបដិវត្តន៍

◆ កែប្រែជីវភាពប្រជាជនទៅរករបបចាស់វិញ

◆ ទាក់ទងកម្លាំងថ្មីសម្រាប់ធ្វើការប្រឆាំង

◆ លាក់ស្រូវខ្លះទុកសម្រាប់ប្រឆាំងទៅថ្ងៃក្រោយ នៅពេលដែលអត់បាយ គឺសម្រាប់ធ្វើការប្រឆាំង ។

អ្នកទាំងបួន ក៏បានអប់រំអតីតទាហាន លន់ នល់ និងជាប្រជាជនថ្មី៦នាក់ទៀតមាន កើត សុង, គួច ប៊ិន, ទូច ឆឹត, ចាន់ ខេង, សោម យ៉ាន់ និង យឿន ផុន ។ យឿត និង វី បានអប់រំអ្នកទាំង៦នេះ ឲ្យឃើញច្បាស់ពីការអនុវត្តសង្គមនិយមបដិវត្តន៍ គ្មានកម្មសិទ្ធិឯកជន គ្មានសេរីភាព និងជំនឿសាសនាផ្សេងៗ ត្រូវបានបំបាត់ចោល និងស្នើអ្នកទាំង៦ ឲ្យចូលរួមសកម្មភាពប្រឆាំងបដិវត្តន៍តទៅទៀត ។

នៅដើមខែកុម្ភៈ ឆ្នាំ១៩៧៧ ដោយមានទិសពីអង្គការឃុំ ប្រធានសហករណ៍៣ បានចាត់តាំង វី, ដួល និង យឿត ឲ្យទៅលើកទំនប់នៅកំពីងពួយ ។ អង្គការលើក៏បានចាត់ឲ្យ រ៉ាំ, ខេង និង យ៉ាន់ ក្តាប់ភូមិជំនួស វី និង ដួល ។ ឈ្មោះ រ៉ាំ, ខេង និង យ៉ាន់ នេះហើយដែលបានលាក់ស្រូវ១៥០បាវ នៅឆ្នាំ១៩៧៧នេះ ។ នៅខែមេសា ឆ្នាំ១៩៧៧ អ្នកដឹកនាំសហករណ៍៣ បានឆែកឆេរផ្ទះប្រជាជននៅភូមិស្រែកណ្តាលទាំងមូលឃើញស្រូវដែលលាក់១៥០បាវ ហើយនឹងបានចាប់ខ្លួន រ៉ាំ, ខេង និង យ៉ាន់ ទៀតផង ។

នៅខែកក្កដា ឆ្នាំ១៩៧៧ យឿត បានត្រឡប់ពីលើកទំនប់វិញ ។ ដោយបានដឹងពីការចាប់ខ្លួនអ្នកទាំង៣ខាងលើនោះ យឿត មានការភិតភ័យជាខ្លាំង និងមានផែនការលួចរត់ទៅសៀម នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៧៧ តែត្រូវយោធាចាប់ខ្លួនបាននៅតាមផ្លូវធ្វើដំណើរនៅភូមិចារក់នៅថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៧៧ និងត្រូវបានបញ្ជូនបន្តមកបាត់ដំបង ហើយមកដល់ភ្នំពេញនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៧ ។

ចម្លើយសារភាពរបស់ អ៊ឹម យឿត ត្រូវបានសរសេររួចរាល់នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៧៧ បន្ទាប់ពីមកដល់ភ្នំពេញអស់រយៈពេលជាង១០ថ្ងៃ ដោយមានឈ្មោះ អឿន ជាអ្នកសួរចម្លើយ ។ ក្នុងនោះដែរ យឿត ក៏បានរាយឈ្មោះអ្នកដែលចូលរួមក្នុងសកម្មភាពប្រឆាំងបដិវត្តន៍របស់ខ្លួនចំនួន៣៩នាក់ ដោយបញ្ជាក់យ៉ាងច្បាស់អំពីឈ្មោះ និងតួនាទីរបស់អ្នកទាំងនោះទៀតផង ។ **ធាង សារៈមុនិន្ទ**

# កម្មវិធីសម្ពោធវគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋាន និង ប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)









# ឧត្តមសិក្សា ស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជា កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៦









# កាលវិភាគបញ្ចាំងខ្សែភាពយន្ត ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា
















*រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង ១០ : ០០ ព្រឹក*

*ទីតាំង : អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង : ម៉ែន ពិចិត្រ ទូរសព្ទលេខ : ០២៣ ២១៤ ០០៩ អ៊ីម៉ែល : truthmpechet@dccam.org*

# ការិយាល័យព័ត៌មានសាធារណៈ

*“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។*

*មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។*

*តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។*

*ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អ៊ុន សុដាវី តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthsodavy.u@dccam.org ។*




















# វាយសម្រុកឱ្យខ្លាំងក្លាថែមទៀត តាមមាគ៌ាសកម្មត្រឹមត្រូវ និងស័ក្តិសិទ្ធិបំផុត ដើម្បីបន្តអនុវត្តភារកិច្ចនយោបាយរបស់បក្ស ឆ្នាំ១៩៧៦ ឱ្យបាន១០០ភាគរយ

*(ដកស្រង់ចេញឯកសារទង់បដិវត្តន៍លេខ៧ ខែកក្កដា ឆ្នាំ១៩៧៦ D២១៤១៦)*

**១) អំពីលទ្ធផលនៃការអនុវត្តភារកិច្ចនយោបាយរបស់បក្សឆ្នាំ១៩៧៦**

ក្នុងរយៈ៦ខែកន្លងទៅនេះ បក្សយើងបានដឹកនាំប្រជាជនយើង សម្រេចបានលទ្ធផលដ៏ល្អប្រពៃ ក្នុងការអនុវត្តភារកិច្ចនយោបាយរបស់បក្សឆ្នាំ១៩៧៦ ។ មហាចលនាបដិវត្តន៍របស់មហាជន កម្មករ-កសិករ និងកងទ័ពបដិវត្តន៍យើងក្នុងការបំពេញភារកិច្ច បន្តបដិវត្តន៍សង្គមនិយម វាយសម្រុកកសាងសង្គមនិយម និងកិច្ចការពារប្រទេសកម្ពុជាប្រជាធិបតេយ្យយើង បង្ហាញឲ្យឃើញច្បាស់នូវកម្លាំងខ្លាំងក្លាជាមូលដ្ឋានរបស់បដិវត្តន៍យើងក្នុងរយៈ៦ខែកន្លងទៅនេះ ។ តាមមហាចលនានេះ យើងឃើញច្បាស់នូវលទ្ធផល និងសមត្ថភាពរបស់មហាជន កម្មករ-កសិករ និងកងទ័ពបដិវត្តន៍យើង វាយសម្រុកឈានទៅមុខ ដណ្តើមមហាជ័យជម្នះគ្រប់ផ្នែកជាប្រាកដ ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាយើង ។

ទន្ទឹមនឹងនេះ បក្សយើងប្រកាន់នាទីដឹកនាំយ៉ាងខ្លាំងក្លា មោះមុត ដោយស្មារតីទទួលខុសត្រូវខ្ពស់ចំពោះបដិវត្តន៍ និងចំពោះ



កសិករនៅតាមសហករណ៍ស្ទូងស្រូវ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ (១៩៧៥-១៩៧៩)

កម្មករ កសិករ និងកងទ័ពបដិវត្តន៍យើង ។ នេះជាកត្តាសំខាន់បំផុត មានលក្ខណៈកំណត់ ហើយក៏ជាកម្លាំងជំរុញដឹកនាំមហាចលនាបន្តបដិវត្តន៍សង្គមនិយម វាយសម្រុកកសាងសង្គមនិយម និងកិច្ចការពារប្រទេស ឲ្យបានខ្លាំងក្លា និងឆាប់រហ័សថែមទៀត ។

អាស្រ័យនូវកត្តាទាំងពីរខាងលើនេះ យើងទទួលបានលទ្ធផលជាជ័យជម្នះជាច្រើន ក្នុងការបន្តបដិវត្តន៍សង្គមនិយម ក្នុងការវាយសម្រុកកសាងសង្គមនិយម បន្តការការពារប្រទេស ហើយជាពិសេសយើងបានទទួលលទ្ធផលមួយកម្រិតសំខាន់ ក្នុងការដោះស្រាយជីវភាពប្រជាជន ក្នុងរយៈឆ្នងកាត់ ហើយកំពុងវាយសម្រុកអនុវត្តភារកិច្ច ៣តោន ១ហិកតា ឆ្នាំ១៩៧៦ យ៉ាងខ្លាំងក្លា ។

## ២) បន្តអនុវត្តភារកិច្ចនយោបាយរបស់បក្សឆ្នាំ១៩៧៦ ក្នុងឆមាសទី២ឲ្យបានសម្រេច១០០ភាគរយ

ដើម្បីអនុវត្តភារកិច្ចនយោបាយរបស់បក្សឆ្នាំ១៩៧៦ ឲ្យបាន១០០ភាគរយទាំងស្រុង លុះត្រាតែបក្សទាំងមូល ដឹកនាំកងទ័ពបដិវត្តន៍ទាំងមូល និងវណ្ណៈកម្មករ-កសិករយើងទាំងមូល វាយសម្រុកឲ្យខ្លាំងក្លាថែមទៀត តាមមាគ៌ាសកម្មភាពត្រឹមត្រូវ និងស័ក្តិសិទ្ធិបំផុត ។ ជាក់ស្តែងគឺយកចិត្តទុកដាក់លើចំណុចសំខាន់ៗមួយចំនួនដូចតទៅ ៖

### ១.អំពីបដិវត្តន៍សង្គមនិយម

ដើម្បីការពារប្រទេសបានល្អ និងស័ក្តិសិទ្ធិពេញលេញ ដើម្បីកសាងសង្គមនិយមបានល្អ ស័ក្តិសិទ្ធិ និងឆាប់រហ័ស ត្រូវយកចិត្តទុកដាក់បន្តធ្វើបដិវត្តន៍សង្គមនិយម ឲ្យកាន់តែខ្លាំង ឲ្យកាន់តែជ្រៅ ឲ្យកាន់តែមោះមុត ក្នុងន័យកម្ចាត់សំណល់កម្មសិទ្ធិឯកជនគ្រប់ប្រភេទដាច់ខាត ក្នុងន័យពង្រឹងពង្រីកគោលជំហរ ទស្សនវិស័យ ការចាត់តាំង ការរស់នៅជាសមូហភាពឲ្យកាន់តែខ្លាំងក្លា ហើយត្រូវពង្រឹងពង្រីកវាជាបន្តបន្ទាប់ ទាំងក្នុងបក្ស ក្នុងអង្គការស្នូល ក្នុងកងទ័ពបដិវត្តន៍ ក្នុងសហជីពកម្មករ និងសហករណ៍កសិករ ។ ពិសេសបំផុតត្រូវយកចិត្តទុកដាក់ក្នុងបក្ស ហើយសំខាន់ទៅទៀត គឺក្នុងជួរកម្មាភិបាលបក្ស ។ យើងមានជំនឿជឿជាក់ថា ដំណើរការយ៉ាងនេះ វាធានាការអះអាងដល់ការវាយសម្រុកបំពេញភារកិច្ចការពារប្រទេស និងកសាងសង្គមនិយមបានល្អ និងឆាប់រហ័សចំពោះមុខផង និងទៅអនាគតផង ហើយវាធានាអះអាងមិនឲ្យបក្សបដិវត្តន៍ និងជួរយើងទាំងអស់ ប្រែពណ៌សម្បុរ ឬក៏ប្រាសចាកពីគោលជំហរវណ្ណៈអធនរបស់បក្ស ។ ដូច្នេះ យើងប្តេជ្ញាដាច់ខាតបន្តធ្វើបដិវត្តន៍សង្គមនិយមនេះឲ្យបានជ្រាលជ្រៅ និងជាប់ជានិច្ចលើគ្រប់ផ្នែកទាំងអស់ ។

### ២.អំពីភារកិច្ចការពារប្រទេស

ពិតមែនតែ៦ខែកន្លងមកនេះ យើងការពារប្រទេសបានល្អបានពេញទី និងបានទាំងស្រុងក៏ដោយ ក៏សន្និបាតឃើញច្បាស់ ខ្មាំងសត្រូវ វាមានទំនាស់ស្លាប់រស់ជាមួយយើង ។ ទំនាស់នេះវាស្ថិតនៅជាមូលដ្ឋានដដែល ។ ទន្ទឹមនឹងនេះ ពិតមែនតែខ្មាំងត្រូវបរាជ័យជាបន្តបន្ទាប់ក្នុងឧបាយកល និងសកម្មភាពវាគ្រប់បែបយ៉ាងជាបន្តបន្ទាប់មកក៏ដោយ ក៏វានៅតែបន្តធ្វើសកម្មភាពបំផ្លិចបំផ្លាញបដិវត្តន៍យើង បក្សយើង ប្រជាជនកម្មករ កសិករយើង និងកងទ័ពបដិវត្តន៍យើងតទៅទៀតតាមគ្រប់វិធី ពីក្រៅ ពីក្នុង ចំហ សម្ងាត់ ក្នុងប្រទេស និងលើឆាកអន្តរជាតិ ។ល ។ នៅក្នុងនេះ យើងត្រូវចាប់អារម្មណ៍ជាពិសេសឧបាយកល និងសកម្មភាពស៊ីរូងផ្ទៃក្នុងយើង ហើយនឹងវាយយើងពីក្នុងផ្ទៃក្នុងយើង ចេញពីផ្ទៃក្នុងយើង ។ ដូច្នេះ យើងត្រូវយកចិត្តទុកដាក់លើគ្រប់វិធានការទាំងអស់ ដើម្បីម្ចាស់ការលើខ្មាំងជាមុន ទាំងវិធានការតាមព្រំដែនគោក ព្រំដែនទឹក ហ្មត់ចត់ជាប់ជានិច្ច ទាំងវិធានការនៅលើផ្ទៃប្រទេសយើង ហ្មត់ចត់ និងជាប់ជានិច្ច ហើយជាពិសេសទាំងវិធានការក្តាប់ផ្ទៃក្នុងបក្ស អង្គការស្នូល កងទ័ពបដិវត្តន៍យើង និងជួរបដិវត្តន៍យើងទាំងមូល ឲ្យណែនខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង សម្រិតសម្រាំងសមាសភាពអន្តរាយ ដោយម្ចាស់ការជាមុន ដើម្បីផ្ទៃក្នុងយើងទាំងអស់ ជាកំពែងថែបខ្មាំងចូលមិនចុះ លូកដៃមិនបាន ហើយត្រូវបរាជ័យដាច់ខាតនៅក្នុងគ្រប់ឧបាយកល និងសកម្មភាពរបស់វា ។

### ៣.អំពីការវាយសម្រុកកសាងសង្គមនិយមឲ្យបានសម្រេច ១០០ភាគរយ ឆ្នាំ១៩៧៦ ពិសេសសម្រេចភារកិច្ច ៣តោន ១ហិកតា

ទន្ទឹមនឹងការបន្តធ្វើបដិវត្តន៍សង្គមនិយម ឲ្យជ្រាលជ្រៅ និងបន្តការពារប្រទេសឲ្យហ្មត់ចត់ បញ្ហាជាគន្លឹះមួយ គឺត្រូវវាយសម្រុកកសាងសង្គមនិយម ឲ្យបានស័ក្តិសិទ្ធិ និងឆាប់រហ័ស តាមពាក្យស្លោកមហាលោតផ្លោះ មហាអស្ចារ្យ ។ ជាក់ស្តែង គឺសម្រេច៣តោន១ហិកតា ជាផលស្រូវឆ្នាំ១៩៧៦ ។

ដើម្បីសម្រេចបាន៣តោន ១ហិកតា ឆ្នាំ១៩៧៦នេះ ត្រូវយកចិត្តទុកដាក់សំខាន់បំផុត តម្រង់ចលនាបដិវត្តន៍របស់មហាជនតាមមាគ៌ាសកម្មភាពឲ្យបានត្រឹមត្រូវ និងឲ្យស័ក្តិសិទ្ធិតាមពាក្យស្លោក វាយឲ្យចំ វាយឲ្យជាប់ កុំឲ្យវាយពាសវាលពាសកាល ។ ជាក់ស្តែងត្រូវយកចិត្តទុកដាក់លើបញ្ហា៖

**ក) តម្រង់រកដីដែលល្អ ដែលខ្លាញ់ ឲ្យផលច្រើន**

ដើម្បីធ្វើឲ្យចំដីនេះ ហើយរៀបចំលក្ខណៈសម្បត្តិផ្សេងៗ ជាទឹក ជាពូជ ជាជី ជាកម្លាំង ជាការថែទាំ ។ល ។ ឲ្យបានហ្មត់ចត់ជាអតិបរមា ។ តាមទិសសកម្មភាពនេះ យើងមានលទ្ធភាពពេញទី នឹងសម្រេចបានបីតោន មួយហិកតា ។


កងចល័តនៅតាមសហករណ៍ នាំគ្នាលើកទំនប់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ (១៩៧៥-១៩៧៩)

**១) បញ្ហាទឹក**

ប្រព័ន្ធភ្លឺ ប្រឡាយ ដែលយើងសម្រេចបានក្នុងប្រាំមួយខែនេះ ចំនួន៣០ភាគរយ តាមផែនការ ជាមហាជ័យជម្នះមួយ ។ ប៉ុន្តែដើម្បីម្ចាស់ការលើបញ្ហាទឹកជាយុទ្ធសាស្ត្រ យើងត្រូវលម្អមាគ៌ារកទឹកនេះថែមទៀត ។ គឺទន្ទឹមនឹងការយកចិត្តទុកដាក់អំពីប្រព័ន្ធភ្លឺប្រឡាយ ត្រូវយកចិត្តទុកដាក់ថែមទៀត រកប្រភពទឹកជាយុទ្ធសាស្ត្រពិសេស ដោយគិតគូរព្រែកជីក គិតគូរពីអាងធំៗ គិតគូរពីទំនប់សំខាន់ៗ ដែលធានាដល់ការផ្តល់ទឹកដោយមានប្រភពដើមរបស់វា ។ ដូច្នេះ ពីនេះតទៅមុខ ហើយជាពិសេស ចាប់តាំងពីប្រាំង

៧៧ទៅ ត្រូវយកចិត្តទុកដាក់អនុវត្តទិសរកទឹកតាមការលម្អថែមនេះឲ្យបានពិស្តារ ។

**គ) អំពីការបង្កបង្កើនផលស្រូវ ២ដងក្នុងមួយឆ្នាំ**

ដើម្បីជំរុញការកសាងសង្គមនិយមរបស់យើងឲ្យបានឆាប់រហ័សជាអតិបរមា ក៏ដូចជាដើម្បីការពារប្រទេស និងលើកតម្កើងជីវភាពប្រជាជនយើងបានល្អប្រពៃ និងឆាប់រហ័ស ។ ពីនេះតទៅត្រូវរៀបចំឲ្យសកម្ម នូវលក្ខណៈសម្បត្តិផ្សេងៗ ពិសេសគឺរកកន្លែងដីដែលមានលក្ខណៈដីជាតិ និងមានទឹកអនុគ្រោះ ដើម្បីធ្វើ២ដងឲ្យបានជាអតិបរមា ។

**ឃ) អំពីដំណាំផ្សេងៗ ពិសេសដំណាំដែលឲ្យផលនាំចេញទៅក្រៅប្រទេសបាន**

ត្រូវជំរុញការដាំដុះផ្សេងៗ តាមគ្រប់បែបគ្រប់វិធី ដើម្បីដោះស្រាយជីវភាពប្រជាជនចំពោះមុខផង និងយូរអង្វែងទៅទៀតផង ហើយជាពិសេសយកចិត្តទុកដាក់លើដំណាំដែលអាចឲ្យផលនាំចេញទៅលក់ក្រៅប្រទេសដូចជាសណ្តែកបាយ សណ្តែកដី សណ្តែកសៀង ។ល ។ ដើម្បីរកទុនឲ្យបានជាអតិបរមាក្នុងមួយឆ្នាំៗ ។ ដូច្នេះក្រោយពីការយកចិត្តទុកដាក់បំពេញ និងសម្រេចភារកិច្ចខាងដំណាំផ្សេងៗឲ្យបានជាអតិបរមា ដាច់ខាត ជាបន្តបន្ទាប់ទៅ ដោយមានផែនការ មានការចាត់តាំងត្រឹមត្រូវ ហ្មត់ចត់ និងជាប់លាប់ ។

**ង) អំពីកម្លាំងពលកម្ម និងឧបករណ៍ផលិតកម្មកសិកម្ម**

ត្រូវយកចិត្តទុកដាក់ អំពីបញ្ហានេះឲ្យដល់កម្រិត ព្រោះបញ្ហានេះ ទាក់ទងផ្ទាល់ដល់ផលិតកម្ម ។ ដូច្នេះ យកចិត្តទុកដាក់អំពីសុខភាព និងជីវភាពប្រជាជនឲ្យជិតដល់ និងជាប់ជានិច្ច ។ ទន្ទឹមនឹងនេះ ត្រូវយកចិត្តទុកដាក់ថែទាំសត្វ ជាក្របី ជាភ្លើងផ្សែង ជាទឹកភក់ ជាស្មៅចំណី ។ល ។ ដោយមានវិធានការចាត់តាំង ឲ្យបក្សទទួលខុសត្រូវ កុំបណ្តែតបណ្តោយឲ្យកម្លាំងសំណល់ ឬកម្លាំងបន្ទាប់

បន្សំទៅទទួលខុសត្រូវ ដូចបានធ្វើកន្លែងខ្លះកន្លងមក ។

## ៤.អំពីការកសាងបក្ស និងការកសាងសាខាក្នុងសហករណ៍

យើងត្រូវឃើញច្បាស់ ហើយជ្រួតជ្រាបថាកត្តាបក្សដឹកនាំជាកត្តាសម្រេចទាំងអស់ ។ ធ្វើបាន មិនបាន នៅលើបក្សទាំងអស់ក្នុងការបន្តបដិវត្តន៍សង្គមនិយមក្តី ក្នុងភារកិច្ចការពារប្រទេសក្តី ក្នុងការវាយសម្រុកកសាងសង្គមនិយមក្តី ។ ដូច្នេះត្រូវយកចិត្តទុកដាក់ ៖

### ក) ត្រូវយកចិត្តទុកដាក់កសាងបក្សទាំងមូល

ពិសេស គឺបក្សតាមថ្នាក់នីមួយៗ ឲ្យជ្រួតជ្រាបជ្រះស្រឡះក្នុងន័យអនុវត្តខាងមាគ៌ា ខាងសតិអារម្មណ៍ និងខាងចាត់តាំងដើម្បីបំពេញ និងសម្រេចភារកិច្ចជាក់ស្តែងក្នុងមូលដ្ឋាននីមួយៗ ត្រូវបន្តធ្វើបដិវត្តន៍សង្គមនិយមយ៉ាងណា ការពារប្រទេសយ៉ាងណា វាយសម្រុកកសាងសង្គមនិយមយ៉ាងណាឲ្យជាក់ស្តែង ។

កម្មាភិបាល និងបក្សជនគ្រប់រូប ត្រូវប្រកាន់នាទីដឹកនាំដោយម្ចាស់ការអនុវត្តមាគ៌ានយោបាយរបស់បក្ស ឲ្យសកម្មប្រយុទ្ធ ស៊ូះស្វាញក្នុងចលនាមហាជន កម្មករ-កសិករ និងកងទ័ពបដិវត្តន៍ពិសេសក្នុងមហាចលនា សម្រេចបីគោនមួយហិកតា ។

ត្រូវពង្រឹង និងសម្រិតសម្រាំងកម្មាភិបាល និងបក្សជនក្នុងមហាចលនាមហាជន កម្មករ កសិករ និងកងទ័ពបដិវត្តន៍នេះដើម្បីឲ្យបក្សកាន់តែខ្លាំង កាន់តែរឹង ដឹកនាំមហាចលនាមហាជនបំពេញភារកិច្ចរបស់បក្សគ្រប់ផ្នែកបាន ដោយមហាលោតផ្លោះមហាអស្ចារ្យ ។

### ខ) ក្នុងការកសាង ពង្រឹងពង្រីកបក្ស

ត្រូវសម្រេចផែនការកសាងសាខា សហករណ៍ភូមិឲ្យបានពី ៤០ភាគរយ ទៅ៥០ភាគរយ តាមការកំណត់នៅឆ្នាំ១៩៧៦ នេះ ។ ទាល់តែមានសាខាបក្សដឹកនាំត្រឹមត្រូវក្នុងសហករណ៍ ទើបសហករណ៍ខ្លាំងក្នុងការបំពេញភារកិច្ចបន្តបដិវត្តន៍សង្គមនិយមការពារប្រទេស និងវាយសម្រុកកសាងសង្គមនិយមនៅតាមសហករណ៍នីមួយៗ ។ បើសហករណ៍គ្មានសាខាបក្សផ្ទាល់ដឹកនាំត្រឹមត្រូវទេ សហករណ៍នោះមិនខ្លាំង ឬមិនសូវខ្លាំងទេ ក្នុងការបំពេញភារកិច្ចរបស់ខ្លួនគ្រប់ផ្នែក ។ សន្និបាតយល់ឃើញថា ទាល់តែនៅចុងឆ្នាំ១៩៧៦នេះ សហករណ៍ពី៤០ ទៅ៥០ភាគរយទូទាំងប្រទេសមានសាខាពេញអង្គ និងត្រឹមត្រូវដឹកនាំ ទើបយើងមានលក្ខណៈសម្បត្តិជាមូលដ្ឋានទៅកសាងសាខាបក្ស នៅគ្រប់សហករណ៍ភូមិទាំងអស់ទូទាំងប្រទេស ក្នុងឆមាសទី១ ឆ្នាំ១៩៧៧បាន ហើយកាលបើសហករណ៍ទាំងអស់មានសាខាពេញអង្គ និងត្រឹមត្រូវដឹកនាំនោះ សហករណ៍ទូទាំងប្រទេស វាខ្លាំងក្លាក្នុងការបំពេញភារកិច្ចគ្រប់ផ្នែករបស់វា ។ សន្និបាតកំណត់ថា ដើម្បីកសាងសាខាបក្សក្នុងសហករណ៍បានតាមការកកំណត់ ត្រូវកម្ចាត់ទស្សនៈ "ឆ្អេង" និងស្តាំ ឲ្យអស់ ។ "ឆ្វេង" គឺខ្ទចមហាជន មិនជឿមហាជន ឬក៏វាយតម្លៃទាប អំពីចលនាមហាជន ឃើញមហាជនសុទ្ធជាខ្មាំង ។ ស្តាំ គឺចេះតែបញ្ចូលដោយឆិនឆៃ គ្មានឈរលើមូលដ្ឋាននៃលក្ខន្តិកៈរបស់បក្ស ។

ដូច្នេះ ដើម្បីកសាងសាខាបានតាមការកំណត់ ត្រូវឈរលើមូលដ្ឋាននៃលក្ខន្តិកៈផង ត្រូវជឿជាក់ និងពឹងផ្អែកលើមហាជនកម្មករ-កសិករ និងកងទ័ពបដិវត្តន៍ក្នុងមហាចលនាបដិវត្តន៍ជាបន្តបន្ទាប់ដ៏ក្តៅគគុកនេះផង ។ ជាក់ស្តែងគឺជ្រើសរើសសមាសភាពល្អក្នុងចលនាកម្មករ-កសិករ និងកងទ័ពបដិវត្តន៍ ដោយយកលក្ខខណ្ឌរបស់លក្ខន្តិកៈ ទៅពិនិត្យសាកសួរមហាជនឲ្យហ្មត់ចត់ ។ បើធ្វើយ៉ាងនេះ យើងច្បាស់ជារកឃើញនូវសមាសភាពល្អ និងធានាអះអាងជាពិតប្រាកដ ។

ព្រមជាមួយនេះ ត្រូវពង្រឹងពង្រីកអង្គការស្នូលនៅក្នុងសហករណ៍ ឲ្យបានជាអតិបរមាដែលឈរលើមូលដ្ឋាននៃលក្ខន្តិកៈរបស់អង្គការនីមួយៗ ។ នេះគឺចំពោះទាំងសហករណ៍ ទាំងកម្មករ ទាំងកងទ័ពបដិវត្តន៍ ព្រមទាំងក្រសួងមន្ទីរផ្សេងៗ ។

### សរុបរួម

សេចក្តីបញ្ជាក់ថែមខាងលើនេះ គឺឈរលើមូលដ្ឋាននៃការកិច្ចនយោបាយឆ្នាំ៧៦ របស់បក្ស ។ ដូច្នេះ សេចក្តីបញ្ជាក់ថែមខាងលើនេះ វានឹងជំរុញការអនុវត្តភារកិច្ចឆ្នាំ៧៦ របស់បក្សក្នុងឆមាសទី២នេះ ឲ្យបានស័ក្តិសិទ្ធិ ត្រឹមត្រូវតាមមាគ៌ា សកម្មភាពច្បាស់លាស់ថែមទៀត ។ ដូច្នេះ ត្រូវក្តាប់ ជ្រួតជ្រាប ក្នុងន័យអនុវត្តថែមទៀតនូវភារកិច្ចនយោបាយឆ្នាំ៧៦ របស់បក្ស ដើម្បីសម្រេចវានៅចុងឆ្នាំ៧៦ នេះ ឲ្យបាន១០០ភាគរយ ។

**ឆេង ម៉េង**

# នៅសល់តែភាពសោកស្តាយ និងអាឡោះអាល័យ

នៅមុនពេលដែលខ្មែរក្រហមវាយចូលទីក្រុងភ្នំពេញ អ៊ំស្រី សែម សុវុទ្ធី រស់នៅក្នុងភូមិដើមគរ សង្កាត់ជ្រោយចង្វារ ក្រុងភ្នំពេញ ជាមួយនឹងបងប្អូនប្រុស៨នាក់ ។ ឪពុករបស់អ៊ំស្រីជាមន្ត្រីក្រសួងឃោសនាការ ដូច្នេះគ្រួសារគាត់មានជីវភាពធូរធារ និងរស់នៅដោយសុភមង្គលនាពេលនោះ ។ ប៉ុន្តែកុមារភាពដ៏រីករាយរបស់គាត់ត្រូវបានរលាយបាត់មួយប៉ប្រិចភ្នែក ក្រោយថ្ងៃជ័យជម្នះរបស់ខ្មែរក្រហម ។ នៅពេលនោះ អ៊ំស្រីមានអាយុទើបតែ១០ឆ្នាំប៉ុណ្ណោះ ។

ខ្មែរក្រហមបានជម្លៀសគ្រួសាររបស់អ៊ំស្រី រួមទាំងប្រជាជនដទៃទៀតទៅភូមិសំបកមាស ខេត្តកណ្តាល តាមផ្លូវជាតិលេខ ៦A ។ ពេលមកដល់ភូមិសំបកមាស ខ្មែរក្រហមបានបញ្ជូន ប្រជាជនទាំងនោះតាមកាណូតទៅស្ពាយសាច់ភ្នំ ។ ពេលមកដល់ស្ពាយសាច់ភ្នំ អ៊ំស្រីបានឃើញខ្មែរក្រហមចាប់ចងប្រជាជនរាប់រយនាក់ យកទៅសម្លាប់ចោល ។ សាកសព និងបង្ហូចខោអាវនៅរាយបា៉យពេញផ្លូវដែលមើលទៅគួរឲ្យតក់ស្លុត និងសោកសង្រេងជាពន់ពេក ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អ៊ំស្រីនៅតែត្រូវបន្តដំណើរទៅមុខទាំងភាពភ័យខ្លាច និងការស្រេកឃ្លាន ។ នៅតាមផ្លូវ ម្តាយរបស់គាត់បានយករបស់របរដែលមានជាប់ខ្លួនទាំងប៉ុន្មានទៅដូរយកអង្ករ អំបិល



រូបទីមួយ រាប់ពីស្តាំ ៖ សែម វុទ្ធី ថតជាមួយបងប្អូនបង្កើត នៅអំឡុងទសវត្សរ៍ឆ្នាំ៨០

និងជំឡង ។ អ៊ុំ ស្រី នៅចាំបានថា គាត់រួមទាំងគ្រួសារ បានរាក និងក្អួតចង្អោរស្ទើរនឹងស្លាប់ ដោយសារតែហូបអង្ករផ្សរដែលដូរពីអ្នកស្រុក ។

គ្រួសាររបស់អ៊ុំ ស្រី បានបន្តដំណើរដ៏លំបាករហូតដល់ខេត្តបាត់ដំបង ដែលនៅទីនោះគាត់បានវង្វេងបាត់បងប្រុសពីរនាក់ ។ ក្រោយពីរស់នៅបាត់ដំបងបានប្រមាណបីបួនខែ ឪពុករបស់អ៊ុំ ស្រី ក៏ត្រូវអង្គការយកទៅរៀនសូត្រ ពីព្រោះអង្គការស៊ើបដឹងថា ឪពុករបស់គាត់ជាអ្នករដ្ឋការសម័យ លន់ នល់ ។ បន្ទាប់មកទៀត គ្រួសាររបស់អ៊ុំ ស្រី ត្រូវបានបញ្ជូនទៅភូមិត្រពាំងព្រៃ ។

ទៅដល់ទីនោះ អ៊ុំ ស្រី ត្រូវបានអង្គការចាត់តាំងឲ្យធ្វើការនៅកងកុមារ ។ ថ្វីត្បិតតែគាត់មានអាយុត្រឹមតែ១០ឆ្នាំក៏ពិតមែន តែគាត់ត្រូវធ្វើការធ្ងន់ដូចមនុស្សធំដែរ ។ អ៊ុំ ស្រី ត្រូវអង្គការចាត់ឲ្យកាប់ព្រៃ និងច្រូតស្បូវដើម្បីក្រងប្រក់ផ្ទះ ។ គ្រួសាររបស់អ៊ុំ ស្រី ទទួលបានតែអង្ករ១ខាំ ប៉ុណ្ណោះសម្រាប់អាហារបីពេល ។ ពីមួយថ្ងៃទៅមួយថ្ងៃ អ៊ុំ ស្រី ត្រូវធ្វើការកាន់តែធ្ងន់ទៅៗ ។ នៅពេលស្រូវទុំ គាត់ត្រូវដើររើសកួរស្រូវ រហូតដល់ភ្នំកំបោរ និងភ្នំកងវ៉ាទៀតផង ។ មេកងនៅទីនោះតែងតែវាយធ្វើបាបគាត់ ហើយពេលខ្លះ មេកងនោះវាយគាត់រហូតលេចនោមក៏មានដែរ ។ អ៊ុំ ស្រី បានរស់នៅក្នុងភាពភ័យខ្លាច និងការធ្វើទារុណកម្មបែបនេះរហូតដល់ថ្ងៃរំដោះ៧ មករា ឆ្នាំ១៩៧៩ ។

ក្រោយថ្ងៃរំដោះ គ្រួសាររបស់អ៊ុំ ស្រី បានធ្វើដំណើរចេញពីខេត្តបាត់ដំបង ទៅខេត្តតាកែវ ដែលជាស្រុកកំណើតរបស់ម្តាយគាត់ ។ នៅពេលទៅដល់ស្រុកកំណើត អ៊ុំ ស្រី នៅតែរស់នៅដោយជីវភាពលំបាកដដែល ដោយសារតែគ្រួសាររបស់គាត់គ្មានស្រែចម្ការ គោក្របីដូចគ្រួសារដទៃ ។ គាត់ក៏គ្មានសាច់ញាតិច្រើននៅស្រុកដែរ ព្រោះបងប្អូនគាត់ភាគច្រើនសុទ្ធតែជាអ្នករដ្ឋការ លន់ នល់ រស់នៅទីក្រុងភ្នំពេញ ហើយបានស្លាប់ក្នុងរបបខ្មែរក្រហម ។ អ៊ុំ ស្រី នៅសល់តែបងប្អូន៤នាក់ និងម្តាយដែលមានជំងឺរ៉ាំរ៉ៃ ដែលបន្សល់ទុកដោយសង្គ្រាម និងការធ្វើទុក្ខបុកម្នេញពីសំណាក់ខ្មែរក្រហម ។

អ៊ុំ ស្រី បានដកដង្ហើមធំ ហើយបន្តថា គាត់មិនចង់រម្លឹកពីអតីតកាលទាំងនេះទេ ។ ការឈឺចាប់ និងទុក្ខវេទនា ដែលគាត់បានហែលឆ្លង គឺពិតជាលំបាក និងមិនអាចរៀបរាប់អស់ត្រឹមអត្ថបទមួយសន្លឹកនេះទេ ។ គាត់នៅតែសោកស្តាយចំពោះការបាត់បង់ឪពុក និងប្អូនប្រុសជាទីស្រលាញ់របស់គាត់ ។ កុមារភាពដ៏ខ្មៅងងឹតនេះ នៅតែដក់ជាប់ក្នុងអារម្មណ៍របស់គាត់រហូតដល់សព្វថ្ងៃនេះ ហើយរាល់ពេលដែលរម្លឹកពីវាម្តងៗ ទឹកភ្នែករបស់គាត់នៅតែស្រក់ចុះជាមួយនឹងការឈឺចាប់ ។

ថ្វីត្បិតតែខ្ញុំជាក្មេងជំនាន់ក្រោយ ដែលមិនធ្លាប់បានឆ្លងកាត់របបខ្មែរក្រហមក៏ពិតមែន ប៉ុន្តែខ្ញុំអាចយល់ពីការឈឺចាប់ទាំងនេះតាមរយៈក្រសែភ្នែកដែលគាត់សំឡឹងមើលមកខ្ញុំ ។ មនុស្សម្នាក់ៗ ដែលធ្លាប់បានរស់នៅក្នុងរបបខ្មែរក្រហមសុទ្ធតែធ្លាប់ឆ្លងកាត់ការធ្វើទុក្ខបុកម្នេញ និងការឈឺចាប់ដែលមិនអាចពណ៌នាបាន ។ លើសពីនេះទៅទៀត អ្នកទាំងនោះមិនអាចបំភ្លេចស្រមោលអតីតកាលនេះបានទេ ទោះបីជាវាបានកន្លងផុតទៅជាង៤០ឆ្នាំហើយក៏ដោយ ។

**ឯម សីលា**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន នឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.d.dccam.org*

# នៅរស់ជីវិតដោយសារអំពើល្អ

បន្ទាប់ពីស្រស់ស្រូបអាហារពេលល្ងាចជួបជុំគ្រួសាររួចមក គ្រួសាររបស់ខ្ញុំតែងតែពិភាក្សាគ្នាអំពីរឿងរ៉ាវ ឬបញ្ហានានាដែលម្នាក់ៗបានជួបប្រទះ ទាំងរឿងសប្បាយ និងមិនសប្បាយ ។ អ៊ំស្រីធំរបស់ខ្ញុំ ឈឹម មុំ គឺជាបងស្រីរបស់ឪពុកខ្ញុំ បានរៀបរាប់អំពីហេតុការណ៍ដ៏គួរឲ្យហួសចិត្ត និងអស់សំណើចនានាដែលគាត់ និងក្រុមគ្រួសារ បានជួបប្រទះក្នុងអំឡុងស្រុកមានសង្គ្រាម ។ ខ្ញុំឆ្លៀតយកឱកាសនេះ ដើម្បីសាកសួរពីការចងចាំផ្ទាល់របស់អ៊ំស្រីក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម ដោយសារតែសម័យនោះ អ៊ំស្រីជាបុគ្គលតែម្នាក់គត់ក្នុងក្រុមគ្រួសារដែលស្ថិតក្នុងវ័យជំទង់ និងត្រូវបានអង្គការចាត់តាំងឲ្យធ្វើការងារក្នុងសហករណ៍ ។


ឈឹម មុំ និងស្វាមី ថតនៅទសវត្សរ៍ឆ្នាំ១៩៨០

សព្វថ្ងៃនេះ អ៊ំស្រីមានអាយុ ៥៨ឆ្នាំ និងរស់នៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ក្រុងភ្នំពេញ ។ អ៊ំស្រីបានរៀបរាប់ថា ក្នុងរបប លន់ នល់ អ៊ំស្រី និងគ្រួសាររស់នៅទីក្រុងភ្នំពេញ ។ បន្ទាប់ពីខ្មែរក្រហមគ្រប់គ្រងប្រទេសបានទាំងស្រុង នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ អ៊ំស្រី និងគ្រួសារត្រូវខ្មែរក្រហមជម្លៀសដោយបង្ខំចេញពីផ្ទះ ។ នៅពេលនោះ ខ្មែរក្រហមបានប្រកាសឲ្យប្រជាជនក្នុងទីក្រុង ចេញពីផ្ទះមួយរយៈសិន ក្រោមហេតុផលថា ដើម្បីធានាសន្តិភាព សុវត្ថិភាព ព្រោះខ្លាចអាមេរិកមកទម្លាក់គ្រាប់បែក ហើយបីថ្ងៃក្រោយនឹងអនុញ្ញាតឲ្យវិលត្រឡប់មកផ្ទះវិញ ។

អំឡុងពេលនោះ គ្រួសាររបស់អ៊ំស្រីមានសភាពច្របូកច្របល់ និងភ័យព្រួយយ៉ាងខ្លាំង ។ លោកតាបានប្រញាប់ប្រញាល់យកលុយ និងសម្ភារមានតម្លៃមួយចំនួនកប់លាក់ទុកក្នុងបរិវេណផ្ទះ និងបានយកមាសបន្តិចបន្តួចតាមខ្លួន ។ អ៊ំស្រីបានបន្តថា ក្រោយពីពិភាក្សាគ្នាហើយ លោកតាលោកយាយ ក៏បានសម្រេចចិត្តធ្វើដំណើរទៅអង្គតាសោម ក្នុងខេត្តតាកែវ ដែលជាស្រុកកំណើតរបស់លោកយាយ ។

នៅតាមផ្លូវធ្វើដំណើរ អ៊ំស្រីមានការតក់ស្លុតយ៉ាងខ្លាំង ដោយបានឃើញសាកសពជាច្រើននៅតាមដងផ្លូវ ហើយមានអ្នកខ្លះដេកថ្ងូរដោយភាពហេវហត់ និងខ្លះទៀតត្រូវរបួសគ្មានអ្នកថែទាំ ។ ពេលទៅដល់ស្រុកកំណើតរបស់យាយភ្លាម ខ្មែរក្រហមបានប្រកាសឲ្យប្រជាជនថ្មីដែលទើបមកដល់ឲ្យចូលប្រជុំ ។ ពេលនោះ ខ្មែរក្រហមបានប្រកាសទៀតថា ប្រជាជនថ្មីទាំងអស់ត្រូវធ្វើប្រវត្តិរូប និងប្រាប់ពីមុខងារដែលខ្លួនធ្លាប់ធ្វើនៅក្នុងរបបចាស់ អង្គការនឹងចាត់តាំងឲ្យចូលធ្វើការងារដូចរបបចាស់វិញ ។ លោកតារបស់ខ្ញុំ បានសរសេរក្នុងប្រវត្តិរូបថា គាត់គឺជាអតីតសន្តិសុខយាមឃ្លាំង ។ រឿងនេះបានធ្វើឲ្យអ៊ំស្រីនឹកឆ្ងល់ក្នុងចិត្តថា លោកតាគឺជាវេជ្ជបណ្ឌិតនៅមន្ទីរពេទ្យលោកសង្ឃ តែហេតុអ្វីបានជាលោកតាកុហកខ្មែរក្រហមថាជាសន្តិសុខដូច្នេះ? ប៉ុន្តែអ៊ំស្រីក៏មិនហ៊ានសួរលោកតាដែរ ។ បន្ទាប់ពីការប្រជុំ និងធ្វើប្រវត្តិរូបបានបញ្ចប់ មានកម្មាភិបាលខ្មែរក្រហមម្នាក់ស្គាល់លោកតាច្បាស់ បានលួចមកប្រាប់លោកតាឲ្យនាំក្រុមគ្រួសារចាកចេញទៅភូមិតាភេម ស្រុកត្រាំកក់ ដែលជាស្រុកកំណើតរបស់លោក



រូបជួរខាងក្រោយ ឈរនៅកណ្ដាល ៖ ឈឹម មុំ និងសាច់ញាតិ ថតក្នុងពិធីបុណ្យបច្ច័យបួន កាលពីឆ្នាំ២០១៥

គាវិញ ព្រោះនៅនោះមានសុវត្ថិភាពជាង ។

លោកតាក៏ផ្លាស់ទៅស្រុកត្រាំកក់តាមការណែនាំរបស់កម្មាភិបាលម្នាក់នោះ ។ អ៊ំស្រីបានឲ្យដឹងថា នៅស្រុកត្រាំកក់នេះ អ្នកភូមិក៏ដូចជាកម្មាភិបាលខ្មែរក្រហមមួយចំនួនបានស្គាល់ និងដឹងពីអតីតភាពរបស់លោកតាច្រើន ប៉ុន្តែដោយសារតែអំពើល្អរបស់លោកតា អ្នកទាំងអស់គ្នាក៏បានជួយលាក់បាំងរឿងនេះ ព្រោះលោកតាធ្លាប់បានចែកថ្នាំសង្កូវ សម្ភារ និងថវិកា ដល់អ្នកភូមិពេលគាត់មកលេងស្រុកម្ដងៗ ។

ក្រោយពីផ្លាស់មកនៅស្រុកថ្មី អ៊ំស្រី ត្រូវបែកពីគ្រួសារ ដោយត្រូវអង្គការចាត់តាំងឲ្យចូលកងចល័តនារី ។ ការងាររបស់អ៊ំស្រី គឺជីកស្រះ ជីកប្រឡាយ លើកទំនប់ ។ ពេលខ្លះគាត់ត្រូវទូលដីកាត់ទឹកដែលមានជម្រៅជិតផុតចុងជង្គើមក៏មាន ។ វាពិតជាគ្រោះថ្នាក់សម្រាប់គាត់ ពីព្រោះអ៊ំស្រីមិនចេះហែលទឹក ។ ជាមួយនឹងការងារដ៏លំបាកនេះ អ៊ំស្រីទទួលបានមកវិញនូវរបបអាហារដ៏គួរឲ្យខ្លើមរអើម គឺបបររាវមួយចាន លាយជាមួយនឹងកម្ទេចត្រី បន្លែដែលមិនបានលាងសម្អាត ហើយពេលខ្លះមានជាប់អាចម៍គោមកជាមួយក៏មាន ។

ក្នុងឆ្នាំ១៩៧៦ អ៊ំស្រីបានធ្លាក់ខ្លួនឈឺជាទម្ងន់ ប៉ុន្តែលោកតាបានប្រថុយជីវិតស្កាត់មកមើលថែអ៊ំស្រីទាំងកណ្ដាលអាធ្រាត្រ ។ លោកតាបានយកមាសដែលគាត់ដាក់តាមខ្លួនពេលចាកចេញពីភ្នំពេញទៅដោះដូរយកថ្នាំបន្តិចបន្តួចពីកម្មាភិបាលដែលលោកតាស្គាល់ ដើម្បីយកមកព្យាបាលអ៊ំស្រី ។ មួយរយៈក្រោយមក អ៊ំស្រីក៏បានជាសះស្បើយឡើងវិញ ។ រស់នៅស្រុកត្រាំកក់មិនយូរប៉ុន្មាន អង្គការបានចាប់យកអ្នកដែលមានចំណេះដឹងម្នាក់ម្ដងៗ ។ អ៊ំស្រីមិនដឹងថា អ្នកទាំងនោះត្រូវបានអង្គការបញ្ជូនទៅកន្លែងណា ឬមានជោគវាសនាយ៉ាងណានោះទេ ។ រៀងរាល់យប់ អ៊ំស្រីដេកមិនដែលលក់ទេ ព្រោះភ័យខ្លាចថ្ងៃណាមួយនឹងដល់វេនគ្រួសារគាត់ជាក់ជាមិនខាន គឺដោយសារតែលោកតាមានអតីតភាពជាវេជ្ជបណ្ឌិត ។ ប៉ុន្តែជាភ័ព្វសំណាង ប្រវត្តិគ្រួសាររបស់អ៊ំស្រីត្រូវអ្នកគ្រប់គ្នាជួយលាក់រហូតដល់របបខ្មែរក្រហមដួលរលំ ។

រយៈពេលជាងបីឆ្នាំក្នុងរបបខ្មែរក្រហម អ៊ំស្រីរស់នៅដោយភាពភ័យខ្លាច ការធ្វើពលកម្មលើសកម្លាំង ការបង្ខំឲ្យរស់នៅបែកពីឪពុកម្ដាយ បងប្អូន ជាពិសេសគឺគំនាបផ្នែកសតិអារម្មណ៍ ។ អ៊ំស្រីជឿជាក់ថា នេះអាចជាភ័ព្វសំណាងដែលគាត់មានជីងី ប៉ុន្តែបានរួចផុតពីសេចក្ដីស្លាប់ ហើយនៅក្នុងកាលៈទេសៈដ៏លំបាកនេះ ក្រុមគ្រួសារនៅមានជីវិតទាំងអស់ ។ ដូច្នេះគាត់ជឿថា អំពើល្អមិនសាបសូន្យឡើយ ។ អំពើល្អដែលយើងសាង នឹងហុចផលវិជ្ជមានមកយើងវិញនៅពេលអនាគត ។ គ្រប់ពេល អ៊ំស្រីតែងតែបួងសួងសុំឲ្យប្រទេសជាតិមានសុខសន្តិភាពរហូត ដូចសព្វថ្ងៃនេះ ពីព្រោះអ្នកដែលរងទុក្ខដោយសង្គ្រាម គឺជាប្រជាជនគ្រប់រូប គ្មាននរណាម្នាក់អាចគេចផុតឡើយ ហើយអ្នកដែលមិនធ្លាប់ឆ្លងកាត់នូវសង្គ្រាម ច្បាស់ជាមិនយល់ពីតម្លៃនៃសន្តិភាពឡើយ ។

**ឈឹម អមរ័ត្ន**

# បានឃើញត្រឹមចម្លើយសារភាព

កាលពីខែវិច្ឆិកា កន្លងទៅ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើវេទិកាសាធារណៈមួយស្តីពីការផ្សាយបន្តផ្ទាល់ការប្រកាសសាលដីកាស្ថាពររបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ក្នុងសំណុំរឿង០០២ វគ្គទី១ ប្រឆាំងនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន នៅឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្តាល ។ ឆ្លៀតក្នុងឱកាសនេះ អ៊ំស្រី ឆេង ហ៊ាង បានសួរនាំ និងផ្តល់ឈ្មោះបងប្អូនរបស់គាត់មួយចំនួនដែលបានបាត់ខ្លួន និងស្លាប់ក្នុងរបបខ្មែរក្រហមដល់ក្រុមការងារយើងដើម្បីជួយស្វែងរកព័ត៌មានអំពីឈ្មោះទាំងនេះ ។

មកដល់ការិយាល័យនៅភ្នំពេញ ក្រុមការងាររបស់យើងបានខិតខំស្វែងរកឈ្មោះដែល ហ៊ាង បានផ្តល់ឲ្យក្នុងប្រព័ន្ធផ្ទុកទិន្នន័យរបស់មជ្ឈមណ្ឌល ។ ទីបំផុត ក្នុងចំណោមឈ្មោះបងប្អូនប្រុសស្រី៩នាក់របស់គាត់ យើងបានរកឃើញឈ្មោះ និងឯកសារចម្លើយសារភាពរបស់បងប្រុសច្បងរបស់ ហ៊ាង ម្នាក់ឈ្មោះ សៅ គា ។ ក្រុមការងាររបស់យើងបានធ្វើការទំនាក់ទំនងទៅ ហ៊ាង ភ្លាមសម្រាប់ដំណឹងមួយនេះ ។

នៅថ្ងៃទី១២ ខែធ្នូឆ្នាំ២០១៦ បន្ទាប់ពីទទួលបានដំណឹងអំពីការរកឃើញឯកសារទាក់ទងនឹងបងប្រុសមក ហ៊ាង និងក្រុមគ្រួសារ មានក្មេង មានចាស់ចំនួន៩នាក់ បានធ្វើដំណើរតាមរ៉ឺម៉កម៉ូតូកង់បីពីស្រុកកោះធំ ខេត្តកណ្តាល មកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ក្រុមការងាររបស់យើង បានយកឯកសារចម្លើយសារភាពសរសេរដោយដៃមានចំនួន១១ទំព័រ ជូន ហ៊ាង និងគ្រួសារពិនិត្យ និងអាន (ឯកសារចម្លើយសារភាពនេះមានបាត់ទំព័រខ្លះ) ។ បន្ទាប់ពីបានអានខ្លឹមសារដែលមាននៅក្នុងឯកសារចម្លើយសារភាពរួចមក ហ៊ាង បានអះអាងថា ឯកសារនេះ គឺពិតជារបស់បងប្រុសគាត់ ឈ្មោះ សៅ គា ព្រោះនៅក្នុងឯកសារមានរៀបរាប់យ៉ាងច្បាស់អំពីឈ្មោះសមាជិកគ្រួសារ និងឪពុកម្តាយគាត់ ក៏ដូចជាឈ្មោះបងប្អូនជីដូនមួយដែលរស់នៅផ្ទះក្បែរគ្នាមួយចំនួនទៀត ។ គាត់បាននិយាយប្រាប់ខ្ញុំលាយឡំនឹងអារម្មណ៍តក់ក្ស្លុតថា បន្ទាប់ពីបានឃើញនូវសំណេរផ្ទាល់ដៃនៃចម្លើយសារភាពរបស់បងប្រុស គាត់យល់ថា បងប្រុសរបស់គាត់ប្រាកដជាត្រូវខ្មែរក្រហមធ្វើទារុណកម្ម និងបង្ខំឲ្យសរសេរនូវចម្លើយទាំងនេះ ហើយគាត់ក៏មិនអាចស្រមៃ និងពណ៌នាបានអំពីទំហំទារុណកម្មដែលបងប្រុសរបស់គាត់ទទួលរងនៅពេលនោះដែរ ។ ឆ្លៀតក្នុងឱកាសនេះ ហ៊ាង ក៏រៀបរាប់អំពីរឿងរ៉ាវគ្រួសាររបស់គាត់ខ្លះៗ ដែលគាត់ចងចាំប្រាប់ដល់ខ្ញុំ ។

**អំពីគ្រួសារ**

ហ៊ាង ជាកូនទីបីក្នុងគ្រួសារកសិករមួយដែលមានបងប្អូនប្រុសស្រី៨នាក់ ។ ឪពុករបស់ ហ៊ាង ឈ្មោះ សៅ ឆេង និងម្តាយឈ្មោះ ស្រ៊ិន យឹន ។ អ្នកទាំងអស់គ្នារស់នៅឃុំពោធិបាន ស្រុក





ឆេង ហ៊ាង នៅការិយាល័យព័ត៌មានសាធារណមជ្ឈមណ្ឌលឯកសារកម្ពុជា

កោះធំ តំបន់២៥ ។

ក្រោយថ្ងៃរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ឆ្នាំ១៩៧០ ភូមិស្រុករបស់ ហ៊ាង ត្រូវបានគ្រប់គ្រងដោយខ្មែរក្រហម ។ នៅពេលនោះ ឪពុកមាររបស់គាត់បានហៅបងប្អូនរបស់គាត់ឲ្យចូលរួមក្នុងចលនាបដិវត្តន៍ ដោយបំផុសអំពីការប្រយុទ្ធប្រឆាំងនឹងវណ្ណៈនាយទុន និងសក្តិភូមិ ។ ហ៊ាង និងបងប្អូនរបស់គាត់៦នាក់ដែលមានវ័យប្រមាណ១៣ទៅ១៤ឆ្នាំ បានចូលរួមតាមការឃោសនារបស់ឪពុកមាគាត់ ។

**ការបែកចេញពីគ្រួសារ**

នៅឆ្នាំ១៩៧២ បន្ទាប់ពីមានការបង្កើតក្រុម កងរួចមក បងប្អូនរបស់ ហ៊ាង ទាំងអស់ដែលបានចូលបដិវត្តន៍ត្រូវថ្នាក់លើបែងចែកឲ្យទៅតាមអង្គភាពរៀងៗខ្លួន ។ បងប្រុសច្បងឈ្មោះ សៅ គា ត្រូវបានចាត់ចូលទៅធ្វើទ័ពតំបន់ ។ បងស្រីឈ្មោះ សៅ គាង ត្រូវចាត់ចូលក្នុងពេទ្យតំបន់ និងប្អូនស្រី សៅ ភាវ ក៏ធ្វើនៅពេទ្យតំបន់ដែរ ។ ប្អូនប្រុសរបស់ ហ៊ាង ម្នាក់ទៀត ត្រូវចាត់ចូលក្នុងកងសិល្បៈតំបន់ និងប្អូនស្រីឈ្មោះ សៅ ភី នៅកងកុមារ ហើយ ហ៊ាង ត្រូវចាត់ឲ្យអ៊ុំអង្ករសម្រាប់ទ័ពនៅសមរភូមិមុខ ។ បងប្អូនពីរនាក់ទៀតដែលនៅតូចៗ បាននៅជាមួយឪពុកម្តាយរបស់គាត់ ។ អ្នកទាំងអស់គ្នាបានបែក និងរស់នៅឆ្ងាយពីគ្នាតាំងពីពេលនោះមក ។

**បងប្រុស សៅ គា**

ចាប់តាំងពីឆ្នាំ១៩៧២មក ហ៊ាង មិនដែលបានជួបមុខគ្រួសារនោះទេ រហូតដល់ឆ្នាំ១៩៧៥ បន្ទាប់ពីខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញ ហ៊ាង បានជួបបងប្រុស សៅ គា ម្តងនៅភ្នំពេញ មុំបឹងទំពុន និងបងស្រីម្នាក់ទៀតនៅមុំឫស្សីកែវ ។ ការជួបនេះក៏ជាការជួបលើកចុងក្រោយរបស់ ហ៊ាង ព្រោះគាត់ត្រូវអង្គការបញ្ជូនឲ្យទៅធ្វើការនៅជ្រៃធំ ព្រំដែនវៀតណាម ។ ហ៊ាង បានរម្លឹកអំពីបងប្រុស សៅ គា ប្រាប់ខ្ញុំថា បងប្រុសរបស់គាត់ជាមនុស្សស្លូតបូត មិនដែលកាចដាក់ប្អូនៗនោះទេ ។ គាត់បានស្ម័គ្រចិត្តចូលធ្វើយោធាខ្មែរក្រហមតាមការណែនាំរបស់ឪពុកមាររបស់គាត់ ។ ហ៊ាង គ្រាន់តែដឹងថា បងប្រុសធ្វើជាយោធា ប៉ុន្តែមិនដឹងថា គាត់មានតួនាទីជាអ្វីនោះទេ ។ គាត់បានជួបបងប្រុសតែម្តងគត់ នៅឆ្នាំ១៩៧៥ ហើយនៅឆ្នាំ១៩៧៧ ក៏ឮដំណឹងថា បងប្រុសរបស់គាត់ និងបងប្អូនប្រុសស្រីមួយចំនួនទៀតត្រូវបានអង្គការចាប់ខ្លួន ដោយចោទថាក្បត់ ប៉ុន្តែគាត់មិនដឹងថា អ្នកទាំងនោះត្រូវបានអង្គការបញ្ជូនទៅទីណានោះទេ ។

**ការលត់ដំ**

បន្ទាប់ពីមានការចាប់ខ្លួនបងប្រុសរបស់ ហ៊ាង រួចមក គាត់មិនត្រូវបានអង្គការធ្វើបាបនោះទេ គ្រាន់តែអង្គការចាត់ឲ្យឈ្លបតាមដាន និងបន្ថែមការងារឲ្យគាត់ធ្វើថែមទៀតប៉ុណ្ណោះ ។ ហ៊ាង បានឲ្យដឹងថា រៀងរាល់ព្រឹក គាត់ និងសមាជិកក្នុងក្រុមត្រូវងើបទៅប្រជុំនៅម៉ោង៤ភ្លឺ និងចាប់ផ្តើមធ្វើការនៅម៉ោង៥ព្រឹក រហូតដល់ម៉ោង៥ល្ងាច ហើយអាចសម្រាកបានតែម៉ោងហូបបាយប៉ុណ្ណោះ ។ ក្រៅពីធ្វើស្រែ ហ៊ាង ត្រូវអង្គការចាត់ឲ្យទៅលើកទំនប់ទៀត ហើយការងារនេះ គឺមិនមែនប្រើបង្គីតែពីរទេ គឺ ហ៊ាង ត្រូវរែកដីជាមួយបង្គីម្នាងពីរ (សរុបទាំងអស់៤បង្គី) ។ ហ៊ាង បានឲ្យដឹងទៀតថា អំឡុងឆ្នាំ១៩៧៧នេះ មានការចាប់ខ្លួនកម្មាភិបាលខ្មែរក្រហមជាច្រើន ហើយអ្នកដែលមានជាប់និន្នាការក្បត់ដូចគាត់ ត្រូវអង្គការយកទៅលត់ដំ និងអ្នកខ្លះទៀតត្រូវបានយកទៅសម្លាប់តែម្តង ។

**បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម**

អំឡុងឆ្នាំ១៩៧៧ ដដែល ហ៊ាង បានច្បាប់មកលេងផ្ទះម្តង តែពេលមកដល់ផ្ទះ គាត់មិនមានឃើញនរណាម្នាក់ឡើយ ។ អ្នករស់នៅជិតខាងបានប្រាប់គាត់ថា ឪពុកម្តាយ និងប្អូនៗរបស់គាត់



ឆេង ហ៊ាង និង ស្វាមី ឯម ហេង កំពុងរកមើលរូបថតបងប្រុស សៅ គា នៅការិយាល័យព័ត៌មានសាធារណៈមជ្ឈមណ្ឌលឯកសារកម្ពុជា

ទាំងពីរ ត្រូវអង្គការចាប់យកទៅដាក់នៅមន្ទីរសន្តិសុខមួយនៅខេត្តតាកែវហើយ ។ ដំណឹងនេះធ្វើឲ្យ ហ៊ាង អស់សង្ឃឹមយ៉ាងខ្លាំង ព្រោះមិនសង្ឃឹមថាអ្នកទាំងអស់នោះនឹងមានជីវិតរស់ទេ ។ ហ៊ាង បានត្រឡប់ទៅការដ្ឋានការងារវិញ និងធ្វើការនៅទីនោះរហូតដល់របបខ្មែរក្រហមដួលរលំ ។

គាត់បានធ្វើដំណើរត្រឡប់មកភូមិកំណើតវិញ ហើយអ្វីដែលជាសេចក្តីរីករាយបំផុតនោះគឺ គាត់បានជួបឪពុកម្តាយ និងប្អូនៗទាំងពីររបស់គាត់វិញពេលដែលគាត់មកដល់ផ្ទះ ។ អ្វីដែលគួរឲ្យសោកស្តាយបំផុតរបស់គាត់ គឺបងប្អូន៥នាក់ ដែលបានចូលបដិវត្តន៍ជាមួយគ្នា មិនមានឱកាសនឹងជួបគ្នាវិញឡើយ ។ គាត់គ្រាន់តែឮតាមអ្នកស្គាល់ប្រាប់ថា អ្នកទាំងអស់ត្រូវអង្គការចាប់ទៅសម្លាប់នៅជើងឯក ហើយអ្នកខ្លះទៀតប្រាប់ថា យកទៅគុកទួលស្លែង ។

## ដំណឹងចុងក្រោយ

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំជាង៤០ឆ្នាំមកនេះ ហ៊ាង និងគ្រួសារនៅតែមិនដឹងពីជោគវាសនាពិតប្រាកដរបស់បងប្អូនទាំង៥របស់គាត់ ។ ក្រុមគ្រួសារតែងតែធ្វើបុណ្យឧទ្ទិសកុសលដល់អ្នកទាំងនោះជានិច្ច ព្រោះអ្នកគ្រប់គ្នាយល់ថា ប្រសិនបើអ្នកទាំង៥នៅមានជីវិត ប្រាកដជានឹងវិលមករកបងប្អូន ឪពុកម្តាយនៅផ្ទះមិនខាន ហើយអ្វីដែលក្រុមគ្រួសាររបស់គាត់ចង់ដឹងនោះគឺថាតើកូន ឬបងប្អូនទាំងអស់ត្រូវបានអង្គការយកទៅសម្លាប់នៅកន្លែងណា?

ទីបំផុត បងប្រុសម្នាក់របស់ ហ៊ាង ឈ្មោះ សៅ គា ត្រូវបានរកឃើញក្នុងឯកសារចម្លើយសារភាពលេខ D០៧០៤៤ នៅក្នុងបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សម្រាប់ ហ៊ាង និងក្រុមគ្រួសារ មានអារម្មណ៍ភ្ញាក់ផ្អើលចំពោះព័ត៌មានដ៏មានតម្លៃនេះ ព្រោះគាត់រង់ចាំ និងស្វែងរកជាង៤០ឆ្នាំមកហើយ ។ ទោះបីជាគាត់បានដឹងថា បងប្អូនទាំង៥នាក់របស់គាត់បានស្លាប់ក៏ដោយ ប៉ុន្តែ យ៉ាងហោចណាស់ពេលនេះ ក្នុងចំណោមអ្នកទាំង៥ ក៏គាត់បានដឹងថា បងប្រុសរបស់គាត់ម្នាក់ ត្រូវបានខ្មែរក្រហមយកមកសម្លាប់នៅគុកទួលស្លែង ។

**ធាច សារៈមុនិន្ទ**

# ហ៊ាន ផាន្នី ៖ ការបាត់បង់ដោយមិនដឹងខ្លួន

អន្លង់វែង មានទីតាំងស្ថិតនៅតាមបណ្តោយជួរភ្នំដងរែក ក្នុងខេត្តឧត្តរមានជ័យ ជាប់ព្រំប្រទល់ប្រទេសថៃ ។ អន្លង់វែងជាកន្លែងប្រមូលផ្តុំរបស់យោធាខ្មែរក្រហមមកពីតំបន់ផ្សេងៗ ដើម្បីតស៊ូប្រឆាំងរដ្ឋាភិបាលភ្នំពេញ បន្ទាប់ពីរបបរបស់ខ្លួនបានដួលរលំនៅឆ្នាំ១៩៧៩ ។ របនាសម្ព័ន្ធគ្រប់គ្រងរបស់ខ្មែរក្រហមនៅតំបន់នេះ បានដួលរលំទាំងស្រុងបន្ទាប់ពីកងកម្លាំងខ្មែរក្រហមបានចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ១៩៩៨ ។ ទោះយ៉ាងណាអន្លង់វែងបានបន្សល់ទុកនូវកេរដំណែលប្រវត្តិសាស្ត្រពីអតីតខ្មែរក្រហម រួមមាន សាលារៀន មន្ទីរពេទ្យ ស្ពាន និងផ្ទះរបស់មេដឹកនាំធំៗ រហូតមកដល់បច្ចុប្បន្ននេះ ។ តាមរយៈការចុះសម្ភាសន៍ប្រជាជននៅក្នុងតំបន់អន្លង់វែង ប្រជាជនបានផ្តល់មកវិញនូវបទពិសោធន៍ផ្ទាល់ខ្លួនក្នុងរយៈកាលនៃការតស៊ូ និងទស្សនៈនៃការយល់ឃើញពីតំបន់អន្លង់វែងក្នុងពេលបច្ចុប្បន្នរួមមាន ព្រៃឈើ និងដីធ្លីជាដើម ។ ជាក់ស្តែង ពូ ហ៊ាន ផាន្នី មានអាយុ៤៨ឆ្នាំ កើតនៅភូមិអូរត្រកួន ស្រុកកងមាស ខេត្តកំពង់ចាម បានផ្លាស់មករស់នៅស្រុកអន្លង់វែងនៅឆ្នាំ១៩៩៨ បានរម្លឹកពីប្រវត្តិរឿងរ៉ាវរបស់គាត់ប្រាប់ខ្ញុំថា ក្រោយថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ គាត់ និងគ្រួសារជាប្រជាជនមូលដ្ឋាន (ជាប្រជាជនចាស់) ប៉ុន្តែវាសនារបស់ក្រុមគ្រួសារគាត់មិនខុសពីប្រជាជនទូទៅដែរ គឺត្រូវខ្មែរក្រហមជម្លៀសចេញពីភូមិឲ្យទៅរស់នៅតំបន់ផ្សេងៗ និងទទួលរងទុក្ខលំបាកដូចប្រជាជនថ្មីដែរ ។ ស្ថិតក្នុងវ័យ៩ឆ្នាំ គាត់ត្រូវអង្គការបំបែកចេញពីឪពុកម្តាយឲ្យទៅធ្វើការនៅកងកុមារ ។ ផាន្នី បានឲ្យដឹងថា ក្រៅពីធ្វើការ កុមារទាំងអស់ត្រូវមករៀនជុំគ្នា ចំណែកការបង្រៀនក៏មិនមានអ្វីច្រើនដែរ គឺគ្រូបង្រៀននិយាយតែពីភាពអស្ចារ្យរបស់អង្គការឲ្យក្មេងៗស្រឡាញ់អង្គការ និងបានបណ្តុះស្មារតីរបស់ក្មេងនៅក្នុងកងកុមារឲ្យស្អប់ឪពុកម្តាយថែមទៀត ។

ឪពុកម្តាយរបស់គាត់ត្រូវបានអង្គការបង្ខំឲ្យធ្វើការជាទម្ងន់ ដោយតម្រូវឲ្យជីកដីចំនួនពី៣ទៅ៤ម៉ែត្រគូប និងធ្វើការលើសពី១២ម៉ោងក្នុងមួយថ្ងៃ ។ នៅចុងឆ្នាំ១៩៧៨ មានការកាប់សម្លាប់ជាបន្តបន្ទាប់នៅក្នុងភូមិ ហើយគាត់ចាំបានថា ស្រះទឹកមួយនៅកណ្តាលភូមិមានសុទ្ធតែសាកសពដែលស្អុយរលួយ និងមានក្លិនអាសោចជុំវិញនោះ ។ ក្រោយរំដោះថ្ងៃ៧ មករា ឆ្នាំ១៩៧៩ ក្រុមគ្រួសាររបស់គាត់ក៏មិនបានផ្លាស់ទៅរស់នៅកន្លែងផ្សេងដែរ គាត់បានចូលរៀនបន្ត ប៉ុន្តែរៀនសូត្របានមួយរយៈប៉ុណ្ណោះក៏ឈប់រៀនមកជួយការងារឪពុកម្តាយវិញ ព្រោះគ្រួសារគាត់មានជីវភាពលំបាក ។


រូបខាងឆ្វេង ៖ ហេង ទីកា សម្ភាស ហ៊ាន ផាន្នី នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

នៅឆ្នាំ១៩៨៧ គាត់បាន

ស្ម័គ្រចិត្តចូលធ្វើទាហានតាមការប្រកាសរបស់រដ្ឋាភិបាលនៃរដ្ឋកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងនឹងខ្មែរក្រហម ។ គាត់បានវាយប្រយុទ្ធតទល់នឹងយោធាខ្មែរក្រហមតាមបណ្តោយព្រំដែនថៃនៅតំបន់ប៉ៃលិន និងអន្លង់វែង ។ គាត់បានចំណាយពេលជាង១០ឆ្នាំក្នុងសង្គ្រាម ហើយគាត់ក៏មិនដែលបានទៅជួបជុំគ្រួសារដែរ ។ នៅឆ្នាំ១៩៩៨ បន្ទាប់ពីមានការចាប់ខ្លួន តាម៉ុក និងការធ្វើសមាហរណកម្មចុងក្រោយរបស់កម្លាំងខ្មែរក្រហមនៅអន្លង់វែង គាត់ក៏សម្រេចចិត្តរស់នៅ និងសាងគ្រួសារនៅស្រុកអន្លង់វែង ។

ក្រោយមកដោយសារនឿយណាយនឹងសង្គ្រាម និងមានជំងឺប្រចាំកាយផង ផាន្នី ក៏បានលាឈប់ពីជួរកងទ័ពនៅក្នុងឆ្នាំ១៩៩៩ ។ គាត់បានបន្តរៀបរាប់ប្រាប់ខ្ញុំថា ពេលដែលគាត់មកដល់អន្លង់វែងដំបូង តំបន់នេះសម្បូរដោយដើមឈើធំៗ និងមានសត្វព្រៃជាច្រើនប្រភេទ ។ ដោយសារព្រៃឈើក្រាស់ ពេលដែលគាត់ដើរចូលក្នុងព្រៃម្តងៗ មិនដែលឃើញពន្លឺថ្ងៃនោះទេ ។ ចំណែកឯអាកាសធាតុក៏មិនសូវក្តៅដែរ ថែមទាំងមានទេសភាពបៃតងស្រស់ទៀតផង ។ ប្រជាជនហាក់មានអារម្មណ៍រីករាយនៅពេលដែលបានមករស់នៅទីនេះ ។ តំបន់នេះពីមុនត្រូវបានកាន់កាប់ដោយកម្លាំងខ្មែរក្រហមដែលមាន តាម៉ុក ជាអ្នកគ្រប់គ្រង ហើយតាមដែលគាត់ដឹង តាម៉ុក មិនអនុញ្ញាតឲ្យមានការបំផ្លាញព្រៃឈើ និងការឈ្លានពានពីសំណាក់ប្រទេសជិតខាងទេ ។ ប្រជាជននៅតំបន់អន្លង់វែងប្រកបរបរចិញ្ចឹមជីវិតដោយធ្វើស្រែចម្ការ និងរកសត្វព្រៃខ្លះ ដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ។ ក្រោយមក មានការប្រែប្រួលដោយភាពខ្វះខាត ដែលតម្រូវឲ្យខ្មែរក្រហមកាប់ឈើមួយចំនួនលក់ទៅឲ្យប្រទេសថៃ ដើម្បីទិញអាវុធ និងស្បៀងមកផ្គត់ផ្គង់ដល់ទាហាន និងប្រជាជននៅអន្លង់វែង ។ ពេលនោះទោះបី ផាន្នី ជាទាហានរដ្ឋាភិបាលក៏ដោយ ក៏គាត់ទទួលស្គាល់ថា ខ្មែរក្រហមពុំបានកាប់បំផ្លាញព្រៃឈើទាំងស្រុងដែរ តែខ្មែរក្រហមមានលក្ខខណ្ឌត្រឹមត្រូវក្នុងការកាប់ដើមឈើធំៗ ដែលជាតម្រូវការយកទៅធ្វើស្ពាន សាលារៀន និងសាងសង់ផ្ទះឲ្យទៅប្រជាពលរដ្ឋក្រីក្រដែលពុំមានលទ្ធភាព ។

តែបច្ចុប្បន្នវាហាក់ខុសប្លែកពីអ្វីដែល ផាន្នី បានជួបកាលពីជាងម្ភៃឆ្នាំមុន ដោយសារព្រៃឈើបច្ចុប្បន្នបាត់បង់ស្ទើរតែទាំងស្រុងទៅហើយ ហើយដីដែលធ្លាប់តែមានព្រៃក្រាស់បានក្លាយទៅជាវាលរហោស្ថាន ។ ការបាត់បង់ទាំងនេះកើតឡើងក្រោយឆ្នាំ១៩៩៨ ក្រោយពេលខ្មែរក្រហមធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាល កំណើនប្រជាជនចំណូលស្រុកមានការកើនឡើងរីឯព្រៃឈើមានការថយចុះជាលំដាប់ ដោយការទន្ទ្រានពីសំណាក់ប្រជាជនដើម្បីយកឈើ និងដីធ្វើជាទីលំនៅផ្ទាល់ខ្លួន ។ ផាន្នី បានបន្តថា ចំណែកខាងរាជរដ្ឋាភិបាលក៏ត្រូវការឈើយកទៅសាងសង់សំណង់ផ្សេងៗនៅក្នុងតំបន់ និងក្រៅតំបន់ដែរ ។ បន្ថែមលើនេះគឺមានប្រជាជនចំណាកស្រុកជាច្រើនចូលមកតំបន់អន្លង់វែងនេះដើម្បីរកស៊ីជួញដូរឈើប្រណិតតែម្តង ។ ដោយសារភាពក្រីក្រអ្នកទាំងនោះបានស៊ីឈ្នួលអារឈើឲ្យឈ្មួញ ទោះដឹងថាវាជាទង្វើខុសច្បាប់ក៏ដោយ ។

បច្ចុប្បន្ន ដោយសារព្រៃឈើថយចុះ នៅក្នុងតំបន់ដែលគាត់រស់នៅកម្តៅមានការកើនឡើងខ្លាំង ដែលធ្វើឲ្យគាត់ពិបាករស់នៅ ចំណែកសត្វព្រៃក៏បានរត់ទៅនៅប្រទេសជិតខាងស្ទើរតែទាំងអស់ ។ គាត់មានប្រសាសន៍លាយឡំនឹងសំណើចថា ក្នុងភូមិគាត់បច្ចុប្បន្នពិបាកនឹងរកឈើមកជួសជុលផ្ទះចាស់ណាស់ ហើយគាត់ក៏មានការសោកស្តាយដែរ ព្រោះកូនចៅជំនាន់ក្រោយនឹងលែងស្គាល់ដើមឈើ ដូចជា បេង ក្រញូង ធ្នង់ ឈើទាល និង នាងនួន ទៀតហើយ ។

ចុងក្រោយ គាត់រម្លឹកទៅដល់អ្នកជំនាន់ក្រោយឲ្យមានការរួបរួមគ្នាដើម្បីកសាងប្រទេស រក្សាសុខសន្តិភាព និងជៀសវាងសង្គ្រាម ព្រោះសង្គ្រាមបានបន្សល់នូវភាពខ្ទេចខ្ទាំ ព្រាត់ប្រាស់បាត់បង់ជីវិត ។ គាត់ក៏អំពាវនាវឲ្យប្រជាពលខ្មែរទាំងអស់ចូលរួមថែរក្សាធនធានធម្មជាតិដែលទទួលរងគ្រោះពីការកាប់បំផ្លាញពីអតីតកាល ហើយនាំគ្នាដាំដើមឈើឡើងវិញដើម្បីឲ្យកូនខ្មែរជំនាន់ក្រោយបានស្គាល់ ពិសេសនៅតំបន់អន្លង់វែងផ្ទាល់តែម្តង ។ គាត់ក៏សង្ឃឹមថា ទាំងរាជរដ្ឋាភិបាល ក្រសួងពាក់ព័ន្ធ និងមន្ទីរទេសចរណ៍នឹងមានគម្រោងការដើម្បីអភិវឌ្ឍន៍អន្លង់វែង ឲ្យទៅជាតំបន់ប្រវត្តិសាស្ត្រដែលអាចទាក់ទាញភ្ញៀវទេសចរណ៍កាន់តែច្រើនឲ្យមកទស្សនា ។

**ហេង ធីតា**

# ជីវិតយាយ យ៉ាត ក្នុងរបបខ្មែរក្រហម

## ជីវប្រវត្តិ

យាយ យ៉ាត មានអាយុ៧៧ឆ្នាំ ជាប្រជាជនម្នាក់ដែលរស់នៅក្នុងឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ យ៉ាត ជាអ្នកដែលមានស្រុកកំណើតនៅឃុំស្វាយស ខេត្តសៀមរាប ។ គាត់បានផ្លាស់មករស់នៅអន្លង់វែងអស់រយៈពេល១៣ឆ្នាំមកហើយ ។ មូលហេតុដែលគាត់មករស់នៅទីនេះ ក៏ដោយសារតែជីវភាពខ្វះខាត ព្រោះគាត់មានកូនប្រុសស្រី៨នាក់ នៅក្នុងបន្ទុក ។ ម្យ៉ាងទៀត ការណ៍ដែលគាត់ផ្លាស់មករស់នៅអន្លង់វែង គឺស្វែងរកមុខរបរថ្មី ដើម្បីចិញ្ចឹមគ្រួសារ ។

## ការរស់នៅក្នុងរបប ប៉ុល ពត (១៩៧៥ - ១៩៧៩)

នៅក្នុងរបប ប៉ុល ពត យ៉ាត ធ្លាប់ធ្វើការនៅក្នុងកងនារីដែលតម្រូវឲ្យជីកប្រឡាយ លើកទំនប់ ធ្វើស្រែ ធ្វើជី បុកស្រូវ និងការងារជាច្រើនទៀត ។ ដោយសារតែភាពភ័យខ្លាចធ្វើឲ្យគាត់ទ្រាំធ្វើការទាំងខ្លួនគាត់ឈឺក៏មាន ហើយក្រោយមកទៀត គាត់ឈឺកាន់តែខ្លាំង រួចក៏ស្នើថ្នាក់លើសុំសម្រាកមួយថ្ងៃ ប៉ុន្តែ ប្រធានកងមិនបានអនុញ្ញាតឲ្យគាត់ឈប់ទេ ។ ប្រធានកងប្រាប់ថា គ្រាន់តែជាជំងឺគ្រុនធម្មតា លេបថ្នាំរួចលែងអីហើយ ។ បន្ទាប់ពីលេបថ្នាំរួច យ៉ាតឈឺកាន់តែខ្លាំងលើសដើម ។ ទោះជាយ៉ាងណា គាត់នៅតែខំធ្វើការទាំងគ្រុនក្ដៅផង ។ យ៉ាត បញ្ជាក់ប្រាប់ខ្ញុំថា ជំងឺគ្រាន់តែជាផ្នែកមួយទេ អ្វីដែលសំខាន់នោះ គឺរបបអាហារប្រចាំថ្ងៃមិនគ្រប់គ្រាន់ទើបបណ្ដាលឲ្យគាត់បាក់កម្លាំងខ្លាំង ។ របបអាហារដែលទទួលបានប្រចាំថ្ងៃ មានតែបបររាវៗប៉ុន្មានវែក ហើយកន្លះខែម្ដងទើបអង្ករដាំបាយឲ្យហូប តែមិនច្រើននោះទេ ។ លើសពីនេះទៀត ឆ្លៀតពេលសម្រាក គាត់តែតែងទៅមើលកូនរបស់គាត់នៅកងកុមារ ដែលមានយាយៗជាអ្នកមើលថែ ពេលដែលឪពុកម្ដាយក្មេងៗទាំងនោះទៅធ្វើការតាមការដ្ឋាន ។

យ៉ាត ខិតខំធ្វើការយ៉ាងយកចិត្តទុកដាក់ ដើម្បីយកចិត្តប្រធានកង ។ គាត់បានឲ្យដឹងថា ប្រធានកងមានសិទ្ធិក្នុងការដាក់ទោសនរណាម្នាក់ដែលប្រព្រឹត្តខុស និងអាចយកទៅសម្លាប់ទៀតផង ។ យ៉ាត ធ្លាប់ឃើញសមាជិកក្នុងកងនារីរបស់គាត់ត្រូវបានអង្គការយកទៅសម្លាប់ ហើយអ្នកខ្លះត្រូវកប់ទាំងរស់តែម្ដង ។

## ជីវភាពក្រោយថ្ងៃ៧ មករា ១៩៧៩

ក្រោយថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ គ្រួសាររបស់យាយបានរស់នៅជួបជុំគ្នា និងបានមករស់នៅតំបន់អន្លង់វែង ជាមួយទ័ពខ្មែរក្រហមដែលនៅសេសសល់ ។ នៅឆ្នាំ១៩៨៦ ប្ដី និងកូនប្រុសរបស់គាត់បានស្ម័គ្រចិត្តចូលធ្វើយោធាខ្មែរក្រហម ហើយការចូលរួមនេះ គឺមកពីជីវភាពគ្រួសារមានការលំបាកពេក ។ គ្រួសារកងទ័ពទទួលបានការផ្គត់ផ្គង់ប្រសើរជាងប្រជាជនធម្មតា ។ បន្ទាប់ពីប្ដី និងកូនរបស់គាត់ចូលបម្រើកងទ័ព គ្រួសាររបស់ យាយ យ៉ាត មានជីវភាពធូរធាជាងមុន ដោយបានទទួលរបបបន្ថែមពីអង្គការមានដូចជា អង្ករ ម្ហូបអាហារ ខោអាវ ជាដើម ។

គ្រួសាររបស់ យ៉ាត មិនមាននរណាម្នាក់បាត់ខ្លួន ឬក៏ស្លាប់ក្នុងរបបខ្មែរក្រហមទេ ។ យ៉ាត បាននិយាយមកកាន់ខ្ញុំដោយញញឹមថា ទោះបីជាក្នុងរបបខ្មែរក្រហមគាត់ត្រូវធ្វើការលំបាកយ៉ាងណា ប៉ុន្តែគាត់ក៏មិនបានស្អប់របបនេះដែរ ព្រោះថា ក្រោយមកប្ដី និងកូនរបស់គាត់បានស្ម័គ្រចិត្តចូលរួមតស៊ូជាមួយនឹងចលនានេះដែរ ។ គាត់បានឲ្យដឹងទៀតថា ការរស់នៅអន្លង់វែង ក្រោមការគ្រប់គ្រង



ភា សាម៉េត កំពុងដាំដើមឈើ នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

របស់ តាម៉ុក គឺមិនសូវលំបាកទេ ។ សម្រាប់ យ៉ាត គឺ តាម៉ុក ជាមនុស្សរួសរាយ ចូលចិត្តលេងសើច ហើយជួយផ្គត់ផ្គង់ប្រជាជននៅពេលដែលប្រជាជនខ្វះខាតទាំងសម្ភារ និងថវិកា ។ ប៉ុន្តែតាម៉ុកក៏ជាមនុស្សម៉ឹងម៉ាត់ ហើយពេលខ្លះ បើនរណាម្នាក់ធ្វើឲ្យគាត់មិនពេញចិត្ត គាត់នឹងដាក់ទោសភ្លាមដោយមិនស្តាប់ហេតុផលអ្វីទាំងអស់ ។ ទោះជាយ៉ាងណា ប្រជាជននៅអន្លង់វែងមានការពេញចិត្ត តាម៉ុក ច្រើន ។

### ស្ថានភាពព្រៃឈើនៅអន្លង់វែង

នៅក្នុងឆ្នាំដំបូងដែល យ៉ាត បានមករស់នៅក្នុងភូមិនេះគឺសម្បូរទៅដោយព្រៃឈើ ដែលស្ថិតនៅជុំវិញផ្ទះរបស់គាត់ ។ ប៉ុន្តែបច្ចុប្បន្នលែងមានព្រៃឈើទៀតហើយ ពីព្រោះមានការបំផ្លាញពីប្រជាពលរដ្ឋ ដែលការកាប់បំផ្លាញនេះគឺជាការធ្វើទាំងបង្ខំចិត្ត ព្រោះតែជីវភាពខ្វះខាត ។ ប្រជាជនទាំងនោះគ្រាន់តែស៊ីឈ្នួលកាប់ព្រៃឈើឲ្យឈ្មួញដើម្បីយកលុយមកផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារប៉ុណ្ណោះ ហើយប្តី និងកូនរបស់គាត់ក៏ធ្លាប់ស៊ីឈ្នួលកាប់ឈើឲ្យឈ្មួញដែរ ។ ទន្ទឹមនឹងនោះ ឈើមួយចំនួនក៏ត្រូវកាប់យកមកធ្វើជាជរំ ផ្ទះ សាលារៀន ឬស្ពាន ដែរ ។

**ឝ៉ា សារ៉េត**

# ដំណឹងស្វែងរកគ្រួសារ


ស៊ីម៉ុន គួន និងកូន

មិត្តភក្តិរបស់ខ្ញុំជាជនជាតិខ្មែរកាត់ចិនរស់នៅសហរដ្ឋអាមេរិក ចង់ស្វែងរកគ្រួសាររបស់គាត់ដែលបានបែកគ្នាជាង៤០ឆ្នាំមកហើយ ។ គាត់មានឈ្មោះអាមេរិកាំងថា ស៊ីម៉ុន គួច ដែលត្រកូលរបស់គាត់ ឡុង ឬ ឡេង ជាភាសាចិន ។ ស៊ីម៉ុន កើតនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៥៥ ។ គាត់បានបែកចេញពីគ្រួសារនៅថ្ងៃទី១៧ ឆ្នាំ១៩៧២ នៅពេលដែលរដ្ឋាភិបាលជ្រើសរើសទាហាន ។ ស៊ីម៉ុនជាកូនច្បងក្នុងចំណោមបងប្អូន៧នាក់ (ស្រី៣នាក់ និងប្រុស៤នាក់) ។ ឪពុករបស់គាត់ជាអ្នកគ្រប់គ្រងរោងភាពយន្តមួយដែលនៅជិតផ្ទះ ។ ស៊ីមុន មិនចាំអាសយដ្ឋានរបស់គាត់ទេ ដោយគាត់គ្រាន់តែដឹងថា ផ្ទះរបស់គាត់នៅជាន់ទី៣ នៃមហាវិថីសាល់ដឺហ្គោល និងមានចម្ងាយដើរប្រមាណ៥នាទីពីរោងភាពយន្ត ។ បើតាមរូបនៅខាងស្តាំ ផ្ទះរបស់គាត់គឺនៅជាន់ទី៣ ពីលើរនាំងពណ៌ក្រហមដែលមានទ្វារសចតនៅខាងមុខ ។



បើបងប្អូនណាបានឮ ឬទទួលដំណឹងនេះហើយ សូមទាក់មកខ្ញុំតាមរយៈអាសយដ្ឋាន ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ, ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥ ។

***សូមអរគុណ!***

# ឈ្លបចោទម្តាយខ្ញុំថា«ចោរ»

កាលពីខែតុលា ឆ្នាំ២០១៦ កន្លងទៅនេះ ខ្ញុំបានចូលរួមដំណើរទស្សនកិច្ចសិក្សាទៅកាន់តំបន់អន្លង់វែង ក្រោមការរៀបចំរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ។ អន្លង់វែង គឺជាតំបន់តស៊ូរឹងមាំចុង និងក្រោយរបស់ខ្មែរក្រហម បន្ទាប់ពីរបបនេះដួលរលំនៅឆ្នាំ១៩៧៩ ។

ខ្ញុំបានទៅទស្សនាតំបន់ប្រវត្តិសាស្ត្រមួយចំនួនដូចជា ផ្ទះតាម៉ុក ផ្នូរប៉ុលពត កន្លែងបូជា សុន សេន ជាដើម ។ បន្ទាប់ពីដំណើរទស្សនកិច្ចទៅតាមតំបន់ប្រវត្តិសាស្ត្រនេះហើយ ខ្ញុំក៏ដូចជាក្រុមនិស្សិតស្ម័គ្រចិត្តដែលរួមដំណើរជាមួយគ្នា មានឱកាសចុះសម្ភាសផ្ទាល់ជាមួយប្រជាជនក្នុងសហគមន៍អន្លង់វែង ដើម្បីសួរនាំអំពីបទពិសោធជីវិតរបស់អ្នកទាំងនោះមុន និងក្រោយពេលមកដល់អន្លង់វែង ។ ខ្ញុំបានធ្វើដំណើរមកដល់វត្តមួយឈ្មោះថា ស្រឡៅស្រោង ។ ខ្ញុំបានដើរទៅដល់សាលាឆាន់ ឃើញដូនចាស់ម្នាក់កំពុងតែមមាញឹកនឹងរៀបចង្ហាន់ប្រគេនព្រះសង្ឃ ហើយឆ្លៀតពេលនោះ ខ្ញុំក៏បានចូលទៅសំណេះសំណាលជាមួយគាត់អំពីរឿងរ៉ាវមួយចំនួនដែលខ្ញុំចង់ដឹង ។ ដូនចាស់រូបរាយម្នាក់នេះឈ្មោះ ឡាញ់ នឹម ។ គាត់មិនមែនជាអ្នកដែលមានដើមកំណើតនៅអន្លង់វែងនេះទេ ។ យាយនឹម និងគ្រួសារជាអ្នកដែលមានស្រុកកំណើត នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម ហើយគាត់បានផ្លាស់មករស់នៅអន្លង់វែងនៅឆ្នាំ ២០០២ ។

បើតាមវ័យរបស់គាត់ ពិតណាស់គាត់ប្រាកដជាធ្លាប់បានឆ្លងកាត់របបខ្មែរក្រហមមិនខាន ។ ខ្ញុំក៏ចាប់ផ្តើមសួរគាត់អំពីជីវិតរបស់គាត់ក្នុងរបបខ្មែរក្រហម ។ រៀបចំចង្ហាន់បណ្តើរ រៀបរាប់ប្រាប់ខ្ញុំបណ្តើរថា គាត់មិនសូវចងចាំប៉ុន្មានទេ ព្រោះសព្វថ្ងៃនេះ គាត់មានវ័យជរាណាស់ហើយ ។ យាយ នឹម គ្រាន់តែប្រាប់ខ្ញុំថា ជីវិតរបស់គាត់ក្នុងរបបខ្មែរក្រហម គឺមិនសូវលំបាកខ្លាំងនោះទេ គឺមានហូបចុកគ្រប់គ្រាន់ ។ ត្រង់ចំណុចនេះធ្វើឲ្យខ្ញុំឆ្ងល់ក្នុងចិត្តថា បើតាមខ្ញុំដឹងពីឪពុកម្តាយ ឬចាស់ទុំប្រាប់ថា ក្នុងរបបខ្មែរក្រហមការរស់នៅរបស់ប្រជាជនមានការលំបាកខ្លាំងណាស់ ជាពិសេស គឺការហូបចុកនេះតែម្តង ដែលផ្ទុយពីអ្វីដែលយាយ នឹម ប្រាប់ខ្ញុំនៅពេលនេះ ។ ខ្ញុំក៏សួរគាត់ថា ហេតុអ្វីបានជាយាយរស់នៅមិនសូវលំបាក? ញញឹមរួចឆ្លើយតបមកខ្ញុំថា គាត់អាចនិយាយថា ជាសំណាងសម្រាប់គាត់ក៏ថាបាន ព្រោះពេលនោះ អង្គការមិនចាត់គាត់ឲ្យធ្វើការនៅតាមកងចល័តទេ គឺឲ្យគាត់នៅកិនអង្ករ និងអុំអង្ករនៅក្នុងភូមិតែម្តង ។ រឿងមួយទៀត យាយ នឹម ប្រាប់ថា គាត់ចេះយកចិត្តប្រធានភូមិ ឬអ្នកគ្រប់គ្រងផ្សេងៗ ហេតុនេះ អ្នកទាំងនោះអាណិតស្រឡាញ់គាត់ និងផ្តល់របបអាហារឲ្យគាត់ជាពិសេស ។ គាត់និយាយថា គាត់មានបាយ និងម្ហូបឆ្ងាញ់ៗរាល់ថ្ងៃ ។ ប៉ុន្តែទោះជាយ៉ាងណា គ្រួសាររបស់គាត់ មិនមានវាសនាល្អដូចគាត់នោះទេ ។ រឿងដែលគាត់បំភ្លេចមិនបាន គឺកើតឡើងចំពោះម្តាយគាត់ ។ ម្តាយគាត់ត្រូវបានអង្គការចាត់តាំងឲ្យមើលថែក្មេងៗ ហើយរបបអាហារដែលទទួលបានក៏មិនគ្រប់គ្រាន់ដែរ ។ ថ្ងៃមួយ យាយ នឹម បានទៅសុំអង្ករប្រធានភូមិយកមកជូនម្តាយគាត់ ។ បន្ទាប់ពីគាត់ជួប និងទុកអង្ករជូនម្តាយហើយ យាយ នឹម បានត្រឡប់ទៅធ្វើការងារវិញ ប៉ុន្តែរឿងដែលនឹកស្មានមិនដល់នោះ គឺឈ្លបក្មេងៗដែលស្ពាយកាំភ្លើងមិនចង់រួចផងនោះ បានឆែកឃើញអង្ករម្តាយគាត់ ហើយចោទម្តាយគាត់ថាជាចោរលួចអង្ករ ។ ឈ្លបក្មេងៗទាំងនោះ បានវាយទាត់ធាក់ម្តាយគាត់យ៉ាងខ្លាំង ហើយមិនត្រឹមតែប៉ុណ្ណោះ ថែមទាំងបានយកអង្ករពីម្តាយគាត់ទៅជាមួយផង ។

ព្រឹត្តិការណ៍ដែលបានកើតឡើងចំពោះម្តាយ នៅតែដិតដាមក្នុងចិត្តរបស់គាត់ជានិច្ច ទោះបីជាហេតុការណ៍នេះ បានកន្លងផុតទៅអស់រយៈពេលជាច្រើនឆ្នាំហើយក៏ដោយ ។ បច្ចុប្បន្ននេះ យាយនឹម តែងតែមកជួយរៀបចង្ហាន់សម្រាប់ព្រះសង្ឃដើម្បីសន្សំកុសលឧទ្ទិសជូនដល់ម្តាយ និងញាតិមិត្តបងប្អូនដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម ។

**ទ៉ាង ពិសិដ្ឋ**

# ការប្រែប្រួលបរិស្ថាននៅអន្លង់វែងក្នុងពេលបច្ចុប្បន្ន

ដំណើរទស្សនកិច្ចទៅកាន់តំបន់អន្លង់វែង បានធ្វើឲ្យខ្ញុំ និងមិត្តភក្តិឯទៀតៗ បានយល់ដឹង និងមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយពីមុនមក ការយល់ឃើញហាក់មានសភាពស្រពិចស្រពិល ព្រោះបានត្រឹមតែឮតាមរយៈការផ្សព្វផ្សាយព័ត៌មាន និងតាមរយៈការអានឯកសារដែលមានរូបថតមួយចំនួន ព្រមទាំងឮការនិយាយតៗគ្នាពីម្នាក់ទៅម្នាក់តែប៉ុណ្ណោះ ។ ឥឡូវនេះ សម្រាប់ខ្ញុំគឺបានឃើញផ្ទាល់ភ្នែកនូវភាពស្រស់បំព្រងនៃតំបន់អន្លង់វែងរបស់ខេត្តឧត្តរមានជ័យ ។ ក្នុងដំណើរទស្សនកិច្ចនៅតំបន់អន្លង់វែង ខ្ញុំបានជួបលោកយាយ ងឹម និងបានសាកសួរគាត់ពីដំណើរជីវិតដែលគាត់ធ្លាប់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហម ៖

លោកយាយ ងឹម មានអាយុ៧០ឆ្នាំ មានស្រុកកំណើតនៅខេត្តកំពង់ចាម ។ យាយ ងឹម បានរំលឹកពីជីវិតរបស់គាត់ និងក្រុមគ្រួសារប្រាប់ខ្ញុំឲ្យបានដឹងថា ខ្មែរក្រហមបានប្រើឲ្យគាត់ត្បាញកន្ទេលរហូតដល់កូននៅក្នុងផ្ទៃពោះរបស់គាត់បាន៨ខែ ទើបឲ្យឈប់សម្រាកពីការងារពលកម្ម ។ លុះដល់ពេលកូនកើតមកបានអាយុមួយខួបកន្លះ អង្គការឲ្យគាត់ទៅជួយធ្វើម្ហូបនៅឯរោងបាយសហករណ៍ ។ ក្រោយមកទៀត ពេលកូនរបស់គាត់ធំបន្តិច អង្គការបានចាត់តាំងឲ្យគាត់ទៅស្ទូង និងបោកស្រូវ ។ ចំណែកប្តីរបស់គាត់ធ្វើការងារដូចជា ឡើងត្នោត ធ្វើស្ករ ចិញ្ចឹមសត្វ ដាំបន្លែ ជាដើម ។ មានពេលមួយនោះ ឈ្លបខ្មែរក្រហមបានចាប់ប្តីរបស់គាត់យកទៅកសាង ដោយចោទប្រកាន់ថា ដាំបន្លែមិនបានល្អ ។ យាយ ងឹម ព្រួយបារម្ភជាខ្លាំង ខ្លាចក្រែងប្តីរបស់គាត់ត្រូវខ្មែរក្រហមសម្លាប់ ។ តែជាសំណាងល្អ ខ្មែរក្រហមបានដោះលែងប្តីរបស់គាត់ឲ្យត្រឡប់មកវិញ ។ និយាយពីការហូបចុកវិញ គឺហូបមិនបានគ្រប់គ្រាន់ ទេ



វាលស្រែ និងព្រៃឈើ ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ នៅពេលបច្ចុប្បន្ន។ ព្រៃឈើមួយចំនួនត្រូវបានប្រជាជនកាប់រានដើម្បីយកដីសាងសង់លំនៅដ្ឋាន និងពង្រីកផ្ទៃដីដាំដុះរបស់ខ្លួន។ ព្រមជាមួយនេះ ក្រុមហ៊ុនឯកជនមួយចំនួនក៏ទទួលបានអាជ្ញាបណ្ណវិនិយោគក្នុងតំបន់នេះដែរ និងបានសម្អាតផ្ទៃដីព្រៃដើម្បីដាំដុះកៅស៊ូ ដំឡូងមី និងដំណាំជាច្រើនប្រភេទទៀត ។



ផ្លូវនៅតាមបណ្តោយព្រំប្រទល់កម្ពុជា និង ថៃ ស្ថិតនៅលើខ្នងភ្នំវែក ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ នៅពេលបច្ចុប្បន្ន ។

រីឯការដាំស្លក៏គ្មានអនាម័យត្រឹមត្រូវដែរ តែដើម្បីជីវិតរស់ត្រូវតែបន្ទុំចិត្តហូប ។ យាយ នឹម ប្រាប់ខ្ញុំដោយហួសចិត្តថា ព្រលិតដែលដកមកពីបឹង មិនទាំងបានលាងសម្អាតផង គឺយកទៅហាន់បង់ចូលដាក់ក្នុងឆ្នាំងខ្ទះសម្លតែម្តង ។ ពេលសុំអំបិលថែមក្នុងសម្លបន្តិចបន្តួច ចុងភៅថាលើសរបបដែលបានកំណត់ហើយ ។ ពេលឈឺគឺមានត្រឹមតែថ្នាំអាចម៍ទន្សាយដែលធ្វើពីម្សៅអង្ករខ្សាយលាយជាមួយរុក្ខជាតិប៉ុណ្ណោះ ។

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ យាយ នឹម និងក្រុមគ្រួសារបានបន្តរស់នៅក្នុងខេត្តកំពង់ចាមដដែល ។ ពេលនោះការងារធ្វើស្រែគឺត្រូវធ្វើរួមគ្នា រីឯផលស្រូវដែលបានមក គឺចែកទៅតាមចំនួនសមាជិកក្នុងគ្រួសារ ។ បន្ទាប់មកទៀត ខាងរដ្ឋអំណាចបានបែងចែកដីដល់ប្រជាជនសម្រាប់ធ្វើស្រែចម្ការតាមគ្រួសាររៀងៗខ្លួន ។ ក្រោយមក យាយ នឹម បានចែកដីទាំងនោះឲ្យទៅកូនៗទុកជាចំណងដៃក្រោយពេលរៀបការ ។ ចំណែករូបគាត់ក៏បានផ្លាស់មករស់នៅក្នុងស្រុកអន្លង់វែង ។ ពេលមកដល់ស្រុកអន្លង់វែងដំបូងក្នុងឆ្នាំ១៩៩៩ គាត់បានចាប់យកដីធ្លីមួយកន្លែងដើម្បីសាងសង់លំនៅដ្ឋាន និងសម្រាប់ធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត ។ យាយ នឹម បានឲ្យដឹងទៀតថា គាត់មានការព្រួយបារម្ភពីបញ្ហាគ្រាប់មីន ដូចនេះគាត់មិនហ៊ានរានដីទៅឆ្ងាយឡើយ ។ កាលពីឆ្នាំ១៩៩៩ នៅតំបន់ស្រឡៅស្រោងនេះ នៅមានព្រៃឈើច្រើនសន្ធឹកសន្ធាប់ណាស់មិនមែនដូចបច្ចុប្បន្ននេះទេ ហើយឈើទាំងនោះជាប្រភេទឈើល្អៗមានដូចជា បេង គគីរ កកោះ ខ្ទាវ ពហូត ពពេលខែល និងស្រឡៅជាដើម ។ ឈើល្អលេខ១ត្រូវបានកាប់បំផ្លាញអស់ នៅសល់តែគល់របស់វាប៉ុណ្ណោះនៅជាប់នឹងដី ។ ការកាប់បំផ្លាញព្រៃឈើមិនមែនមានតែអ្នកដែលរស់នៅក្នុងតំបន់នេះទេ គឺមានមកពីតំបន់ផ្សេងៗដទៃទៀតដែរ ដែលតែងតែមកកាប់ជាបន្តបន្ទាប់ ។ បច្ចុប្បន្ននៅក្នុងភូមិមានបង្កើតជាសហគមន៍ដើម្បីការពារព្រៃឈើដែលមានទីតាំងនៅខាងត្បូងភូមិ ។ យាយ នឹម បានឲ្យដឹងថា ការបាត់បង់ព្រៃឈើធ្វើឲ្យអាកាសធាតុផ្លាស់ប្តូរ និងជាកត្តាធ្វើឲ្យទឹកភ្លៀងមិនគ្រប់គ្រាន់ ដែលបង្កជាភាពរាំងស្ងួតដែលធ្វើឲ្យប៉ះពាល់ដល់ការដាំដុះយ៉ាងខ្លាំង ។ ម្យ៉ាងក្នុងស្រុកគ្មានប្រភពទឹកគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់ដល់ការងារធ្វើកសិកម្មផង ។ ព្រៃឈើមានប្រយោជន៍និងជារបាំងជួយការពារគ្រោះធម្មជាតិ ទោះបីជាដាំបានតិច ឬច្រើន គឺបានចូលរួមចំណែកលើកស្ទួយដល់ផ្នែកបរិស្ថានឲ្យមានភាពល្អប្រសើរឡើងវិញ ។

**ប៉ោ សន្តិភាព**

# ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង៖ តំបន់កាន់កាប់ចុងក្រោយរបស់ចលនាខ្មែរក្រហម

***(តពីលេខមុន)***

***ជំពូក៤***

***បរាជ័យ និងការរត់គេចខ្លួនរបស់ខ្មែរក្រហម***

***ជម្លោះជាមួយវៀតណាម***

ចាប់តាំងពីដំណាក់កាលដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ កងទ័ពខ្មែរក្រហម បានចាប់ផ្តើមប៉ះទង្គិចជាមួយកងទ័ពវៀតណាមកុម្មុយនីស្ត ។ ការប្រទាញប្រទង់គ្នានៅតាមព្រំដែនបានបន្តទៅជាការប៉ះទង្គិចគ្នាកាន់តែញឹកញាប់ឡើងៗរវាងរដ្ឋកុម្មុយនីស្តទាំងពីរ ។ នៅចុងឆ្នាំ១៩៧៧ កម្ពុជាប្រជាធិបតេយ្យបានធ្វើសង្គ្រាម ក្នុងទ្រង់ទ្រាយធំជាមួយនឹងប្រទេសវៀតណាម ។

ការកើនឡើងនូវការប៉ះទង្គិចគ្នាមិនបានកើតឡើងក្នុងពេលតែមួយយប់នោះទេ ។ ជម្លោះរ៉ាំរ៉ៃរវាងប្រទេសទាំងពីរបានកើតឡើងតាំងពីដើមទសវត្សរ៍ឆ្នាំ១៩៧០មកម្ល៉េះ ហើយការប្រយុទ្ធគ្នាក្នុងទ្រង់ទ្រាយធំ អាចបកក្រោយពិនិត្យមើលអំពីព្រឹត្តិការណ៍ទាំងឡាយដែលបានកើតឡើងនៅពាក់កណ្តាលឆ្នាំ១៩៧៧ នៅពេលដែលខ្មែរក្រហមធ្វើការវាយប្រហារទៅលើខេត្តមួយចំនួនរបស់វៀតណាម ។ កងទ័ពខ្មែរក្រហមបានធ្វើការវាយប្រហារខេត្តកៀនយ៉ាង និងខេត្តអានយ៉ាង នៅចុងឆ្នាំ១៩៧៧ និងបានបាញ់ផ្លោងចូលទីរួមខេត្តចូវដុក (ខេត្តមាត់ជ្រូកជាភាសាខ្មែរ) នៅខែខសភា ។ ជាងនេះទៅទៀត នៅខែកញ្ញា ក្រោមបញ្ជារបស់ សុន សេន ខ្មែរក្រហមបានសម្លាប់រង្គាលប្រជាជនស៊ីវិលវៀតណាមប្រមាណជាបីរយនាក់ នៅក្នុងខេត្តតាយនិញ ។

ដោយប្រឈមមុខនឹងការវាយប្រហារនៅតាមបណ្តោយព្រំដែន វៀតណាមបានសម្រេចចិត្តធ្វើការវាយបកវិញ ។ ការ



*រូបឈរ ៖ តាម៉ុក អតីតលេខាភូមិភាគនិរតី បានរត់ភៀសខ្លួនមកតំបន់អន្លង់វែង ក្រោយរបបក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានផ្តួលរំលំដោយកងទ័ពវៀតណាម នៅឆ្នាំ១៩៧៩ ។ ក្រោយមក តាម៉ុក បានប្រមូលផ្តុំប្រជាជន និងកម្លាំងខ្មែរក្រហមនៅតាមអង្គភាពផ្សេងៗដែលរត់ភៀសខ្លួន រួចហើយបង្កើតទៅជាអង្គភាពទ័ព នៅតំបន់អន្លង់វែងដើម្បីប្រឆាំងជាមួយរដ្ឋាភិបាលភ្នំពេញ ដែលគាំដោយវៀតណាម ។*

ប្រយុទ្ធគ្នារវាងកងទ័ពវៀតណាម និងខ្មែរក្រហមបានរីករាលដាលធំឡើងនៅខែតុលា ឆ្នាំ១៩៧៧ នៅពេលកងទ័ពវៀតណាមបានវាយលុកចូលផ្នែកជាច្រើនក្នុងទឹកដីកម្ពុជា ។ ទោះជាយ៉ាងនេះក្តី មកត្រឹមខែមករា ឆ្នាំ១៩៧៨ វៀតណាមបានដកកងទ័ពរបស់ខ្លួនចេញទៅវិញ ។

ឆ្លើយតបទៅនឹងការលុកលុយរបស់វៀតណាម និងដោយមានការភ័យខ្លាចចំពោះអំពើក្បត់ខាងក្នុងរដ្ឋាភិបាលរបស់ ប៉ុល ពត បានធ្វើសង្គ្រាមជាមួយកម្មាភិបាលក្នុងភូមិភាគបូព៌ា ដែលស្ថិតនៅជាប់ព្រំដែនវៀតណាមដែលជា "កន្លែងដែលកងទ័ពវៀតណាមបានលុកលុយចូលយ៉ាងជ្រៅ" ។ កម្មាភិបាលភូមិភាគបូព៌ាជាច្រើនបានរត់ភៀសខ្លួនទៅវៀតណាមដែលនៅទីនោះកម្មាភិបាលទាំងនេះ ទទួលបានការគាំទ្រពីវៀតណាម ហើយនៅទីបំផុតវៀតណាមបានជួយផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅខែធ្នូឆ្នាំ១៩៧៨ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាត្រូវបានបង្កើតឡើង ដែលនឹងជំនួសកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពីរបបនេះត្រូវបានផ្តួលរំលំ ។ នៅខែមិថុនា ឆ្នាំ១៩៧៨ វៀតណាមចាប់ផ្តើមទម្លាក់គ្រាប់បែកមកលើកម្ពុជា ហើយនៅខែតុលា វៀតណាមចាប់ផ្តើមរៀបចំសម្រាប់ការវាយប្រហារក្នុងទ្រង់ទ្រាយធំ ។ ជាចុងក្រោយនៅចុងខែធ្នូ ឆ្នាំ១៩៧៨ វៀតណាម បានបើកការវាយប្រហារក្នុងទ្រង់ទ្រាយធំមកលើកម្ពុជាប្រជាធិបតេយ្យ ។

## បរាជ័យរបស់ខ្មែរក្រហម

របបកម្ពុជាប្រជាធិបតេយ្យត្រូវបានបញ្ចប់ ដូចគ្នាទៅនឹងការចាប់ផ្តើមនៃរបបនេះដែរ គឺស្ថិតនៅក្នុងស្ថានភាពសង្គ្រាម និងភាពចលាចលនៅក្នុងសង្គម ។ កម្ពុជាប្រជាធិបតេយ្យត្រូវបានផ្តួលរំលំដោយកងទ័ពវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ។

កងទ័ពវៀតណាមបានវាយសន្ធាប់យ៉ាងខ្លាំងក្លាចូលក្នុងប្រទេសកម្ពុជាជាមួយនឹងចំនួនកងទ័ពដ៏ច្រើនក្នុងល្បឿនលឿន និងកាំភ្លើងធំធុនធ្ងន់ ជាមួយនឹងការវាយប្រហារជាច្រើនដំណាក់កាល ។ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨ កងវរសេនាតូចរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាចំនួន៩កង និងកងទ័ពប្រជាជនវៀតណាមចំនួន១២កងពល បានធ្វើការវាយប្រហារយ៉ាងខ្លាំង និងព្រមៗគ្នា មកលើកម្ពុជាប្រជាធិបតេយ្យ ។ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានវាយលុកចូលកម្ពុជាប្រជាធិបតេយ្យនៅទីតាំងបីផ្សេងៗគ្នា ។ បីកងវរសេនាតូចបានវាយលុកចូលខេត្តស្វាយរៀង តាមបណ្តោយផ្លូវជាតិលេខ១ ពាកងវរសេនាតូចទៀតវាយលុកចូលតាមខេត្តកំពង់ចាម និង៣កងវរសេនាតូចចុងក្រោយវាយលុកចូលតាមស្រុកស្នួល ខេត្តក្រចេះ ។

កងទ័ពប្រជាជនវៀតណាមបានប្រើប្រាស់កម្លាំងរបស់ខ្លួនចំនួន១២កងពល (ដែលមានចំនួនប្រហែល ១សែន ២ម៉ឺននាក់) ដោយមានការគាំទ្រពីកងទ័ពជើងទឹក កងរថក្រោះ កងកាំភ្លើងធំ និងកងទ័ពជើងអាកាស ។ កងទ័ពវៀតណាម និងកងទ័ពរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដណ្តើមកាន់កាប់បានទីក្រុងភ្នំពេញតែក្នុងរយៈពេលបីសប្តាហ៍ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ នៅក្នុងអំឡុងពេលដប់ថ្ងៃបន្ទាប់មកទៀត កងទ័ពទាំងពីរដណ្តើមកាន់កាប់បានប្រទេសកម្ពុជាស្ទើរតែទាំងស្រុង ។ វៀតណាមបានជួយបង្កើតរបបថ្មី មួយដែលមានឈ្មោះថា សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលត្រូវបានប្រកាសជាផ្លូវការនៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៧៩ ដែលមានសមមិត្ត ហេង សំរិន ជាប្រធាន និង សមមិត្ត ប៉ែន សុវណ្ណ ជាប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី (នាយករដ្ឋមន្ត្រី) និងជារដ្ឋមន្ត្រីការពារជាតិ ។

## ការរត់គេចខ្លួនទៅភ្នំដងរែក

ជាមួយនឹងការវាយប្រហារពីសំណាក់កងទ័ពវៀតណាម និងកងទ័ពរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាចូលមកកម្ពុជា កងទ័ព និងកម្មាភិបាលខ្មែរក្រហម ព្រមទាំងប្រជាជនដែលកំពុងតែភ័យញាប់ញ័រ បានចាប់ផ្តើមរត់បែកខ្ញែកគ្នា និងបានភៀសខ្លួនទៅពួនសម្ងំនៅក្នុងព្រៃ និងបានរត់ទៅព្រំដែនថៃ ។ ជាទូទៅ អង្គភាពរបស់ខ្មែរក្រហមទាំងអស់បានបាត់បង់ទំនាក់ទំនងជាមួយមេបញ្ជាការរបស់ខ្លួន និងបានបោះបង់ចោលប្រតិបត្តិការសឹក ដើម្បីស្វែងរកកន្លែងលាក់ខ្លួនរៀងៗខ្លួន ។ នៅក្នុងអំឡុងពេលរត់ភៀសខ្លួន ខ្មែរក្រហមបានកេណ្ឌប្រជាជនរាប់ម៉ឺននាក់ទៅជាមួយខ្លួន ក្នុងគោលបំណងរៀបចំចលនាតស៊ូបដិវត្តន៍សាជាថ្មីម្តងទៀត ។ ប្រជាជនក្នុងភូមិភាគឦសាន ភូមិភាគឧត្តរ និងភូមិភាគកណ្តាល ត្រូវបានជម្លៀសទៅកាន់ព្រំដែនភាគខាងជើង ហើយត្រូវបានប្រមូលផ្តុំឡើងវិញ នៅលើផ្លូវ

ភ្នំដងរែក(ដែលស្ថិតនៅក្នុងខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ) ។ ប្រជាជនដែលរស់នៅភូមិភាគបូព៌ា ភូមិភាគបស្ចិម ភូមិភាគនិរតី និងភូមិភាគពាយ័ព្យ ត្រូវដើរដោយថ្មើរជើង ឬត្រូវបានដឹកជញ្ជូនទៅភាគខាងលិចនិងពាយ័ព្យនៃព្រំដែនប្រទេសកម្ពុជា ដែលស្ថិតនៅក្នុងខេត្តកោះកុង ពោធិ៍សាត់ និងបាត់ដំបង ។ ចំណែកឯប្រជាជននៅក្នុងទីក្រុងភ្នំពេញត្រូវបានបញ្ជូនតាមរថភ្លើងទៅកាន់ខេត្តពោធិ៍សាត់ និងបាត់ដំបង ។ បន្ទាប់ពីធ្វើដំណើរដល់ខេត្តទាំងពីរនេះ ប្រជាជនត្រូវបានតម្រូវឲ្យធ្វើដំណើរបន្តដោយថ្មើរជើងដែលជាដំណើរដ៏វែងឆ្ងាយទៅកាន់ព្រំដែនថៃ ។

នៅតាមផ្លូវដ៏វែង និងប្រកបដោយគ្រោះថ្នាក់ឆ្ពោះទៅព្រំដែនថៃ ប្រជាជន និងកងទ័ពភៀសខ្លួនមានស្បៀងអាហារតិចតួចណាស់ ។ ដូច្នេះប្រជាជនភៀសខ្លួនទាំងអស់នោះត្រូវដើរបេះស្លឹកឈើព្រៃ មើមឈើព្រៃ និងចាប់សត្វព្រៃទាំងឡាយដែលអាចរកបាននៅតាមផ្លូវមកធ្វើជាអាហារ ។ ប្រជាជនភៀសខ្លួនមួយចំនួនទទួលបានស្បៀងអាហារពីអ្នកភូមិ ។ ប៉ុន្តែ ជាទូទៅប្រជាជនភៀសខ្លួនត្រូវបង្ខំចិត្តធ្វើដំណើរដោយអត់បាយ និងទឹកបរិភោគអស់រយៈពេលជាច្រើនថ្ងៃ ។ នៅក្នុងករណីមួយចំនួនប្រជាជនភៀសខ្លួនបាននិយាយថា ខ្លួនបានផឹកទឹកនោមខ្លួនឯង ដោយសារតែមិនអាចទៅរកទឹកមកហូបបាន ពីព្រោះតំបន់ដែលមានទឹកត្រូវបានកងទ័ពវៀតណាមយាមល្បាត ។ កងទ័ព និងប្រជាជនភៀសខ្លួនមួយចំនួនបាននិយាយថា ខ្លួនបានផឹកទឹកដែលមានជាតិពុលដែលបានបណ្តាលឲ្យស្លាប់បន្ទាប់ពីបរិភោគរួច ។ ការពិតអំពីការរាយការណ៍ទាំងនេះមិនត្រូវបានដឹងទេ ហើយការស្លាប់ក៏អាចបណ្តាលមកពីការហូបទឹកកខ្វក់ ដែលមានសារធាតុគីមី ឬ មានមេរោគបង្កជំងឺ ។

ប្រជាជនដែលរត់ទៅកាន់ព្រំដែនថៃ ជួបប្រទះបញ្ហាលំបាកជាច្រើនដូចជា កង្វះខាត ស្បៀងអាហារ និងជម្រក ។ ជាងនេះទៅទៀត ប្រជាជនភៀសខ្លួនទាំងនោះ មិនហ៊ានចូលទៅក្នុងភូមិដ្ឋានរបស់អ្នកភូមិទេ ដោយសារតែខ្លាចកងទ័ពវៀតណាមចាប់ខ្លួន ។

ប្រជាជននៅភូមិភាគឦសាន ដែលរួមមានខេត្តរតនគិរី ស្ទឹងត្រែង មណ្ឌលគិរី និងក្រចេះ ត្រូវឆ្លងទន្លេមេគង្គទៅកាន់ខេត្តព្រះវិហារ ដើម្បីធ្វើដំណើរទៅកាន់ព្រំដែនថៃ ។ ប្រជាជនទាំងអស់នោះភាគច្រើនជាសមាជិកកងពល៨០១ និងកងពល៩២០ ដែលជាកងពលមជ្ឈិមរបស់ខ្មែរក្រហម ក្រោមការគ្រប់គ្រងរបស់ សូ សារឿន (ហៅ តា០៥) និង មៀច សាន (ហៅ តា០៦) ។ ទោះបីជាប្រជាជនមួយចំនួនឆ្លងទន្លេមេគង្គនៅខេត្តក្រចេះ និងស្ទឹងត្រែងក្តី ប្រជាជនមួយចំនួនទៀតត្រូវឆ្លងទន្លេមេគង្គនៅក្នុងទឹកដីឡាវ ដោយសារតែការវាយប្រហាររបស់កងទ័ពវៀតណាមនៅក្នុងទឹកដីកម្ពុជា ។ ខណៈពេលដែលប្រជាជនមួយចំនួនឆ្លងទន្លេដោយទូក ប្រជាជនមួយចំនួនទៀតឆ្លងទន្លេដោយប្រើដើមឫស្សីពីរបីដើមចងផ្ដោបគ្នាតែប៉ុណ្ណោះ ។ ប្រជាជនត្រូវធ្វើដំណើរនៅពេលថ្ងៃ និងសម្រាកនៅពេលយប់ ។ ប្រជាជនមួយចំនួនបានស្លាប់នៅតាមផ្លូវដោយសារតែដាច់បាយ ។ មិនមានអ្នកណាគិតអំពីអ្នកណានោះទេ ។ ម្នាក់ៗប្រឹងធ្វើយ៉ាងណាឲ្យតែខ្លួនបានរួចរស់ជីវិត ។ ដូចដែលអ្នករស់រានមានជីវិតម្នាក់បានលើកឡើងថា ដើម្បីរស់ម្នាក់ៗក្លាយទៅជាមនុស្សអាត្មានិយម ។ សាំង ថាញ់ អតីតនីរសារកងពល២៨០របស់ខ្មែរក្រហមដែលមានទីតាំងនៅភូមិភាគបូព៌ាបានរៀបរាប់អំពីបទពិសោធរបស់ខ្លួននៅពេលរត់ទៅភ្នំ១០០១ ថា៖

នៅឆ្នាំ១៩៨០ ខ្ញុំបានដឹកនាំកងទ័ព៧នាក់រត់ទៅមុំបី ។ នៅតាមផ្លូវ ខ្ញុំបានជួបកងទ័ពខ្មែរក្រហម និងប្រជាជនជាច្រើនក្រុមដែលកំពុងធ្វើដំណើរទៅមុំបីដែរ ។ ទោះជាយ៉ាងនេះក្តី ក្រុមនីមួយត្រូវមានភាពឯករាជ្យ ពោលគឺធ្វើយ៉ាងណាឲ្យទៅដល់មុំបី ដើម្បីជួបជុំជាមួយអង្គការ ។ ខ្ញុំបានយកមាសទៅដូរយកអង្ករនឹងអំបិលពីអ្នកភូមិ ។ យើងបានរំលែកអំបិលដាក់ទៅក្នុងកូនថង់តូចៗ ហើយទុកនៅក្នុងកាបូបរៀងៗខ្លួន ។ ខ្ញុំបានឃើញមនុស្សជាច្រើនបានស្លាប់ ហើយសាកសពហើមស្អុយនៅតាមផ្លូវ ។ ស្ត្រីមួយចំនួនបានដេកស្លាប់នៅក្នុងអង្រឹង ។ ស្ត្រីមួយចំនួនបានស្រែកហៅឲ្យខ្ញុំជួយ «សមមិត្ត! សូមជួយផង! សូមយកខ្ញុំទៅជាមួយផង!» ខ្ញុំបានសួរខ្លួនឯងថា «តើខ្ញុំអាចជួយពួកគាត់យ៉ាងម៉េច បើខ្ញុំជួយខ្លួនឯងមិនទាំងបានផង?» ជាងនេះទៅទៀត កងទ័ពវៀតណាមបានដេញតាមយើងពីក្រោយជាប់រហូត ។ កងទ័ពបានសម្លាប់មនុស្សដែលជិតស្លាប់ ។ ពេលមកដល់ស្រុកឆែប យើងបានកាប់ដើមចេក ហើយបេះផ្លែចេកខ្ចីយកមកហូបដូចដំរី ។ យើងបានចំណាយពេលមួយខែកន្លះទើបធ្វើដំណើរមកដល់មុំបី ។ ពេលទៅដល់មុំបី យើងរកបានអង្ករយ៉ាងច្រើន ហើយម្នាក់ៗកំពុងតែឃ្លានខ្លាំង ។ ម្នាក់ៗហូបច្រើន

ហួសហេតុ ។ ប្រជាជនមួយចំនួនបានស្លាប់ដោយសារតែហូបអង្ករឆៅច្រើនជ្រុល ។ ដូច្នេះ មេៗ បានឲ្យយើងហូបបាយដំណើបជំនួស ។

កងទ័ពខ្មែរក្រហម និងសមាជិកក្រុមគ្រួសារបានចំណាយពេលជាច្រើនថ្ងៃ (ហើយសម្រាប់ប្រជាជនជាច្រើនផ្សេងទៀតត្រូវចំណាយពេលជាច្រើនខែ) ដើម្បីដើរទៅព្រំដែនថៃ ។ ឈឿន ដែលជាកងទ័ពម្នាក់នៅក្នុងកងពល៩២០ បានធ្វើដំណើរដោយថ្មើរជើងជាមួយកងទ័ពខ្មែរក្រហមចំនួន១.៥០០នាក់ ផ្សេងទៀតអស់រយៈពេល២ខែ និង១០ថ្ងៃដើម្បីទៅដល់ខេត្តបាត់ដំបង ដែលនៅទីនោះ មេបញ្ជាការកងពល មៀច សាន បានមកទទួលហើយនាំផ្លូវឆ្ពោះទៅកាន់ភ្នំដងរែក ។ យឹម ផាន់ណា ដែលជាអតីតកងទ័ពនៅក្នុងកងពល៨០១ បានរត់ភៀសខ្លួនទៅកាន់ព្រំដែនថៃជាមួយនឹងកងទ័ព និងកម្មាភិបាលខ្មែរក្រហមដទៃទៀត ។ ផាន់ណា បានរំឭកអំពីដំណើរដ៏វែង និងលំបាកថា៖

យើងចាប់ផ្តើមធ្វើដំណើរខែមីនា ឆ្នាំ១៩៧៩ ។ អាកាសធាតុនៅពេលនោះក្តៅខ្លាំងណាស់ ។ តំបន់ដែលមានទឹកត្រូវបានកងទ័ពវៀតណាមគ្រប់គ្រង ។ ជារឿយៗ ការប្រយុទ្ធគ្នាតែងតែកើតឡើងនៅតាមតំបន់ទាំងនោះ ។ មនុស្សជាច្រើនបានស្លាប់ និងរបួស ។ ដៃជើងរបស់ខ្ញុំចាប់ផ្តើមហើមដែលធ្វើឲ្យខ្ញុំមិនអាចដើរទៅមុខបាន ។ ខ្ញុំបានវង្វេងពីក្រុមរបស់ខ្ញុំ នៅពេលរត់គេចពីកងទ័ពវៀតណាម ។ នៅទីបំផុតខ្ញុំត្រូវផឹកទឹកនោមខ្លួនឯងដើម្បីរស់ ។ ជួនកាល កងទ័ពវៀតណាមវាយប្រហារយើងនៅពេលដែលយើងកំពុងដាំបាយ ។ យើងត្រូវរត់បែកផ្លូវគ្នា ដោយទុកបាយចោល ។ ពីមួយពេលទៅមួយពេលក្រុមរបស់យើងកាន់តែតូចទៅៗ ។ ឪ ធិន គឺជាមេក្រុមរបស់យើងនៅពេលនោះ ។ នៅពេលយើងធ្វើដំណើរមកដល់ស្រុកឆែប ខ្ញុំត្រូវបានបង្ខំឲ្យចូលទៅក្នុងភូមិដើម្បីទទួលការព្យាបាល ព្រោះដៃជើងរបស់ខ្ញុំកាន់តែហើមខ្លាំងឡើង ។ ថែមទាំងគ្រុនក្តៅទៀត ។ ប្រសិនបើខ្ញុំបន្តនៅជាមួយក្រុម ដំណើរទៅមុខរបស់យើងនឹងត្រូវយឺតដោយសារតែជំងឺរបស់ខ្ញុំ ។ ដូច្នេះ ក្រុមរបស់ខ្ញុំបានដកហូតកាំភ្លើងរបស់ខ្ញុំ និងបង្ខំឲ្យខ្ញុំចូលសារភាពជាមួយសត្រូវ ។ មិនចង់ទៅទេ ប៉ុន្តែគ្មានជម្រើស ។ ពេលមកដល់ក្នុងភូមិ ខ្ញុំត្រូវបានកងទ័ពវៀតណាមចាប់ខ្លួន ហើយបញ្ជូនទៅក្នុងគុក ។ នៅទីនោះ បានជួបមិត្តភក្តិរបស់ខ្ញុំជាច្រើន ។

គីម ណាន ដែលជាអតីតកងទ័ពខ្មែរក្រហមប្រចាំនៅតំបន់សៀមរាប-ឧត្តរមានជ័យ (តំបន់១០៦) ស្ថិតនៅក្នុងកងកាំភ្លើង



អតីតយោធាខ្មែរក្រហមនៅតំបន់អន្លង់វែង បានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅឆ្នាំ១៩៩៨ ក្រោយពេល តាម៉ុក ត្រូវបានចាប់ខ្លួន

ធំនៃតំបន់នេះ ។ នៅឆ្នាំ១៩៧៩ នៅពេលដែលកងទ័ពវៀតណាមវាយចូលកម្ពុជា ណន និងកងរបស់ខ្លួន ត្រូវបានបញ្ជូនទៅស្រុកថាឡាបរិវ៉ាត់ (ខេត្តស្ទឹងត្រែង) ដើម្បីជួយវាយសមរភូមិនៅទីនោះ ។ ណន បានរៀបរាប់អំពីដំណើរភៀសខ្លួនដ៏លំបាកទៅកាន់ព្រំដែនថៃ ថា៖

ពេលមកដល់ស្រុកថាឡាបរិវ៉ាត់ ខ្ញុំមិនអាចបែងចែកបានអ្នកណាជាខ្មែរ អ្នកណាជាយួនបានទេ ។ ព្រឹកឡើងខ្ញុំបានឃើញកងទ័ពវៀតណាមជាច្រើន ដូចផ្សិតដែលដុសចេញពីដី ។ ការប្រយុទ្ធគ្នាបានកើតឡើងជាច្រើនថ្ងៃ ។ យើងចាញ់កងទ័ពវៀតណាម ហើយបានដកថយចូលទៅក្នុងព្រៃ ដែលនៅទីនោះមានសត្វព្រៃជាច្រើនដូចជា ដំរី និងខ្លា ។ ខ្ញុំគិតថា ខ្ញុំប្រាកដជាស្លាប់មិនខាន ។ នៅពេលយប់ ខ្ញុំមិនហ៊ានដេកនៅលើដីទេ ។ ខ្ញុំដេកនៅលើដើមឈើ ។ លុះដល់ព្រឹកឡើងខ្ញុំបានវង្វេងទិស ។ ខ្ញុំបានឮសំឡេងបាញ់កាំភ្លើង ហើយក៏សម្រេចដើរតាមទិសដៅសំឡេងនោះ ។ ពេលដើរទៅដល់ទីវាលមួយ ខ្ញុំបានឃើញមនុស្សមួយក្រុមអត់ពាក់អាវ ប៉ុន្តែមិនអាចមើលស្គាល់ថាជាអ្នកណា ។ ខ្ញុំបានស្រែកហៅពួកគេ ប៉ុន្តែដោយសារពួកគេជាកងទ័ពវៀតណាម ដូច្នេះ ពួកគេមិនអាចស្តាប់ខ្ញុំយល់ទេ ។ កងទ័ពទាំងនោះបានបក់ដៃឲ្យខ្ញុំដើរទៅរកគេ ។ ខ្ញុំបានដើរទៅរកពួកគេ ប៉ុន្តែនៅពេលដែលមើលឃើញថា ជាពួកកងទ័ពវៀតណាម ខ្ញុំបានរត់គេចចេញ ។ ខ្ញុំបានវង្វេងនៅក្នុងព្រៃអស់រយៈពេលពីរថ្ងៃទៀត ដោយគ្មានអាហារ ។ ពេលដើរតាមផ្លូវ ខ្ញុំបានឮសំឡេងឡានមួយ ។ ខ្ញុំបានដឹងថា វាជាឡានរបស់ខ្មែរក្រហម ដូច្នេះខ្ញុំបានរត់សំដៅទៅរកឡាននោះ រួចហើយសុំជិះជាមួយ ។ កងទ័ពខ្មែរក្រហមទាំងនោះយល់ព្រមឲ្យខ្ញុំជិះជាមួយ ។ កងទ័ពវៀតណាមនៅតែបន្តដេញយើងពីក្រោយរហូតដល់ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ។

ប្រជាជនជ្រើសរើសការរត់ភៀសខ្លួនទៅកាន់ព្រំដែនកម្ពុជាថៃ ដោយសារហេតុផលជាច្រើន ។ ប្រជាជននៅតែមានជំនឿលើការឃោសនារបស់ខ្មែរក្រហមដែលថា វៀតណាមគឺជាសត្វចម្លែក ។ ខ្មែរក្រហមបានឃោសនាប្រាប់ប្រជាជនថា កងទ័ពវៀតណាមនឹងអារកមនុស្ស ឬដាក់ចូលទៅក្នុងទឹកក្តៅ ។ ខ្មែរក្រហមក៏បានប្រាប់ប្រជាជនដែរថា វៀតណាមចូលចិត្តវះពោះមនុស្ស ហើយញាត់ស្មៅចូល ។ ប្រជាជនជាច្រើនយល់ឃើញថា ជីវិតនឹងវេទនាជាងស្លាប់ទៅទៀត ប្រសិនបើកងទ័ពវៀតណាមចាប់បាន ។ ដូច្នេះប្រជាជនសុខចិត្តប្រើមធ្យោបាយគ្រប់បែបយ៉ាងដើម្បីរត់គេចខ្លួន ។ ប្រជាជនមួយចំនួនទៀតយល់ឃើញថា ប្រទេសកម្ពុជាបានធ្លាក់ក្រោមការគ្រប់គ្រងរបស់វៀតណាមហើយ ជម្រើសតែមួយគត់គឺការរកសាងជីវិតសាជាថ្មីនៅក្នុងប្រទេសមួយទៀត ។ ប្រជាជនមួយចំនួនទៀតបានដឹងថា អង្គការសហប្រជាជាតិកំពុងផ្តល់អាហារដល់ជនភៀសខ្លួននៅជំរំជនភៀសខ្លួន នៅភ្នំឆត្រ និងជំរំជនភៀសខ្លួនដទៃទៀតនៅក្នុងប្រទេសថៃ ។ ទោះជាយ៉ាងនេះក្តី ប្រជាជនមួយចំនួនគឺជាសមាជិករបស់របបកម្ពុជាប្រជាធិបតេយ្យ ។

ឡេង ដេង ដែលជាអតីតកងទ័ពនៅក្នុងកងពល៨០១ បានរំឭកពីការគេចខ្លួនរបស់គាត់ពីខេត្តរតនគិរី ទៅកាន់ទន្លេរពៅ ថា៖

នៅពេលដែលវៀតណាមចូលមកដល់កម្ពុជានៅឆ្នាំ១៩៧៩ ខ្ញុំបានរត់ចូល និងរស់នៅក្នុងព្រៃខេត្តរតនគិរី ។ បន្ទាប់មក នៅឆ្នាំ១៩៨១ ខ្ញុំបានរត់ទៅភ្នំដងរែក ដោយសារតែមានការលំបាកផ្នែកសេដ្ឋកិច្ច ។ យើងបានធ្វើដំណើរចេញពីខេត្តរតនគិរី ឆ្លងកាត់តាមប្រទេសឡាវ ពីព្រោះកងទ័ពវៀតណាមបានឈរជើងនៅតាមព្រំដែនក្នុងទឹកដីកម្ពុជា ។ពេលមកដល់ខេត្តស្ទឹងត្រែង យើងបានធ្វើក្បូនឫស្សី ដើម្បីឆ្លងទន្លេមេគង្គទៅខេត្តព្រះវិហារ ។ នៅពេលដែលខ្ញុំកំពុងហែលឆ្លងទន្លេ ជើងរបស់ខ្ញុំបានរមួលក្រពើ ។ ខ្ញុំក៏អង្គុយសម្រាកនៅច្រាំងទន្លេ ដោយសារតែខ្ញុំមិនអាចដើរទៅមុខបាន ។ សមាជិកផ្សេងទៀតនៅក្នុងអង្គភាពរបស់ខ្ញុំបានឆ្លងទន្លេ និងបានបន្តដំណើរទៅមុំបីមុនខ្ញុំ ។ ខ្ញុំបានចំណាយពេលអស់៩ថ្ងៃ មុននឹងធ្វើដំណើរទៅដល់ទន្លេរពៅ ឬមុំបី ។ ចំណែកឯមិត្តភក្តិរបស់ខ្ញុំចំណាយពេលតែ៣ថ្ងៃប៉ុណ្ណោះ ។

ឯម សារិន ដែលជាសមាជិកគណៈតំបន់ក្រចេះចុងក្រោយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានគ្រប់គ្រងការរត់គេចខ្លួនរបស់កម្មាភិបាលកងទ័ព និងប្រជាជនស៊ីវិល ពីខេត្តក្រចេះទៅកាន់ព្រំដែនថៃ ។ សារិន បានដឹកនាំប្រជាជន និងកងទ័ពឆ្លងទន្លេមេគង្គនៅស្រុកព្រែកប្រសព្វ ហើយបន្តដំណើរទៅខេត្តកំពង់ធំ និងធ្វើដំណើរបន្តទៀតទៅកាន់ខេត្តព្រះវិហារ ។ ប្រជាជនជាច្រើនផ្សេងទៀតបានធ្វើដំណើរតាមឡានទៅខេត្តស្ទឹងត្រែង និងបានឆ្លងទន្លេមេគង្គទៅស្រុកថាឡាបរិវ៉ាត់ ហើយបន្តដំណើរឆ្ពោះទៅខេត្តព្រះវិហារ ។

*សម្រាប់ដំណើរដ៏វែងឆ្ងាយនេះ សារិន បានត្រៀមឡាន ចំនួន៤៧ គ្រឿង ដោយមានសាំងពេញ ព្រមទាំងស្បៀងអាហារ និងសម្ភារសំខាន់ៗផ្សេងទៀត ។ ដោយសារតែប្រជាជននៅភូមិភាគឦសានមានចំនួនច្រើនលើសលប់ សារិន មិនអាចដឹកជញ្ជូនប្រជាជន និងឡានទាំងអស់ឆ្លងទន្លេបានទេ ។ ដោយមានជំនួយពី ខេង ដែលជាលេខាតំបន់ស្ទឹងត្រែង សារិន អាចចម្លងបានតែឡានចំនួន១៧គ្រឿង និងសម្ភារសំខាន់ៗមួយចំនួនតែប៉ុណ្ណោះ ដែលមានដូចជា សាំង អង្ករ និងសម្លៀកបំពាក់ ។ សារិន បានបញ្ជាឲ្យដុតឡានដែលនៅសេសសល់ចោលទាំងអស់ ដើម្បីកុំឲ្យកងទ័ពវៀតណាមប្រើប្រាស់បាន ។ ប្រជាជនដែលឆ្លងស្រឡាងមិនទាន់ ត្រូវហែលឆ្លងទន្លេមកគ្គ ឬរត់ចូលព្រៃ ។ ស្ថានភាពនៅពេលនោះ មានសភាពតានតឹង និងជ្រួលច្របល់យ៉ាងខ្លាំងដោយសារកងទ័ពវៀតណាមបានវាយចូលកាន់តែជិតដល់តំបន់នេះ ហើយប្រជាជនបាននាំគ្នារត់គេចខ្លួនទៅតាមទិសដៅផ្សេងៗគ្នា ។*

*ដោយបែកពីប្រពន្ធ សារិន បានសម្រេចចិត្តមិនធ្វើដំណើរទៅព្រំដែនថៃភ្លាមៗទេ ។ សារិន បានសម្រេចចិត្តដើរបកក្រោយវិញដើម្បីស្វែងរកប្រពន្ធរបស់គាត់ ។ បន្ទាប់ពី បានជួបប្រពន្ធរបស់គាត់នៅខេត្តកំពង់ចាម សារិន បានទៅរស់នៅក្នុងព្រៃជាមួយកងទ័ពខ្មែរក្រហមមួយក្រុមទៀតរហូតដល់ឆ្នាំ១៩៨៣ ។ ក្រោយមក សារិន បានធ្វើដំណើរមកចូលរួមជាមួយចលនាខ្មែរក្រហមនៅលើភ្នំដងរែក ។ សារិន បានរៀបរាប់អំពីជីវិតរបស់គាត់នៅក្នុងព្រៃថា៖*

*ខ្ញុំបានបររទេះគោទៅភ្នំដី ។ ក្រុមរបស់ខ្ញុំមានគ្នាចំនួន១៥នាក់ ដែលក្នុងនោះមានស្ត្រី២នាក់ ។ យើងបានលាក់ខ្លួននៅក្នុងព្រៃកាប់ឆ្ការព្រៃយកដី និងធ្វើស្រែចម្ការសម្រាប់ចិញ្ចឹមជីវិត ។ កងទ័ពខ្មែរក្រហមជាច្រើនអង្គភាពផ្សេងទៀត កំពុងធ្វើប្រតិបត្តិការនៅខាងមុខ ។ អង្គភាពមួយចំនួនខ្វះខាតអំបិល និងស្បៀងអាហារ ។ ជាសំណាងល្អក្រុមរបស់ខ្ញុំបានរកឃើញអំបិលមួយពាង និងស្ករមួយពាង ដែលត្រូវបានកប់លាក់ទុកនៅក្នុងដីដែលជាអតីតទីតាំងមួយរបស់កងទ័ពខ្មែរក្រហម ។ យើងបានដាំ និងសម្ងួតអំបិល ហើយលាក់ទុកសម្រាប់ប្រើឲ្យបានយូរ ។ យើងមានអំបិល ពូថៅ និងកាំបិតជាច្រើន ដែលអាចឲ្យយើងធ្វើស្រែចម្ការបានល្អ ។ យើងដាំស្រូវ និងបន្លែជាច្រើន ដែលរួមមានពោត ឪឡឹក ត្រកួន ត្រសក់ល្ពៅ និងត្រសក់ស្រូវ ។ បន្ទាប់ពីរស់នៅទីនេះអស់រយៈពេលពីរបីឆ្នាំ យើងបានសម្រេចចិត្តធ្វើដំណើរឡើងភ្នំដងរែកនៅឆ្នាំ១៩៨៣ ។*

*ដើម្បីសម្រួលដល់ការរត់ភៀសខ្លួនរបស់កងទ័ព និងប្រជាជនស៊ីវិល ទៅកាន់ព្រំដែនថៃ និងតំបន់ផ្សេងៗទៀតនៅតាមព្រំដែនដែលគ្រប់គ្រងដោយខ្មែរក្រហម ខ្មែរក្រហមបានដាក់អង្គភាពកងទ័ពតូចៗជាច្រើននៅតាមផ្លូវ ។ អង្គភាពទាំងនេះ ទទួលខុសត្រូវយាមល្បាតតាមផ្លូវនិងចង្អុលបង្ហាញទិសដៅដល់ប្រជាជនភៀសខ្លួន ។ នៅក្នុងករណីខ្លះអង្គភាព ទាំងនេះដឹកនាំប្រជាជនទៅកាន់ជំរំកងទ័ពនៅលើភ្នំដងរែក ។ ប្រសិនបើពុំមានជំនួយពីអង្គភាពទាំងអស់នេះទេ កងទ័ពខ្មែរក្រហម និងប្រជាជនភៀសខ្លួនប្រាកដជាមានការលំបាកក្នុងការរត់គេចពីកងទ័ពវៀតណាម ដែលបានគ្រប់គ្រងស្ទើរគ្រប់ឃុំស្រុកទាំងអស់នៅទូទាំងប្រទេស ។*

*ប្រជាជនដែលធ្វើដំណើរចាកចេញពីប្រទេសកម្ពុជាមានការហត់នឿយយ៉ាងខ្លាំង និងទទួលរងគ្រោះពីការខ្វះជីវជាតិយ៉ាងធ្ងន់ ។ ប្រជាជនជាច្រើនបានធ្វើដំណើរច្រើនជាងមួយខែដោយគ្មានអាហារ ។ មេដឹកនាំខ្មែរក្រហមបានអនុញ្ញាតឲ្យប្រជាជនទាំងនោះសម្រាករយៈពេលមួយឬពីរខែដោយបានផ្គត់ផ្គង់សម្ភារជាច្រើនដូចជាថ្នាំសង្កូវសម្លៀកបំពាក់ អាហារ និងសម្ភារចាំបាច់ផ្សេងៗទៀតសម្រាប់ការរស់នៅ ។ បន្ទាប់មក មេដឹកនាំ ខ្មែរក្រហមបានរៀបចំចាត់តាំងកម្លាំងប្រយុទ្ធឡើងវិញដោយបែងចែកប្រជាជនទៅតាមអតីតតំបន់ និងអង្គភាពរៀងៗខ្លួនឡើងវិញ ។*

**(តទៅលេខក្រោយ)** **គ្រីស្តូហ្វ័រ ឌឿរិច និង ឌី ខាំបូលី**


## អានទស្សនាវដ្ដីតាមគេហទំព័រ

*ទស្សនាវដ្ដីស្វែងរកការពិតត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm ។ ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០ ១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។*

# «ខ្ញុំចាប់ផ្តើមវាយប្រហារ ប៉ុល ពត» សាក្សីបាននិយាយថា លោកព្យាយាមផ្តួលរំលំការដឹកនាំ

*អតីតមេបញ្ជាការកងវរសេនាធំ លោក អៀង ផាន បានផ្តល់សក្ខីកម្មថ្ងៃនេះ ។ លោកត្រូវបានត្រូវបានសាកសួរពីសំណាក់មេធាវីការពារក្តីអំពីតួនាទីថ្មីៗរបស់មន្ត្រីរាជរដ្ឋាភិបាលក៏ដូចជាភាពអសមត្ថភាពក្នុងការលុកលុយចូលទឹកដីវៀតណាម ។*

*នាពេលរសៀល មានសាក្សីមិនបង្ហាញអត្តសញ្ញាណមួយរូបដែលមានរហស្សនាម* ***2-TCW-1065*** *បានប្រាប់តុលាការថា លោកបានចាប់ផ្តើមរៀបចំផែនការដើម្បីប្រឆាំងនឹង ប៉ុល ពត ក្រោយពេលដែលសាក្សីបានឃើញផ្ទាល់ភ្នែកថា “ប៉ុល ពត” បានក្បត់តាមរយៈការសម្លាប់កម្មាភិបាល និងទាហានគ្រង់កន្លែងដែលលោកបានឈរជើង ។*

## មន្ត្រីរាជរដ្ឋាភិបាលថ្មីៗ និងបច្ចុប្បន្ន

*ពេជ្យ អគ្គ មិនបានបង្ហាញវត្តមានដោយសារបញ្ហាផ្ទាល់ខ្លួន ។ សវនាការត្រូវបានប្រគល់ជូនមេធាវីការពារក្តី ដើម្បីធ្វើការសាកសួរសាក្សី លោក អៀង ផាន ។ លោក វីកទ័រ កូប៉េ សហមេធាវីអន្តរជាតិការពារក្តីឲ្យលោក នួន ជា បានសួរថាតើលោកផាន ចាំបានទេថាវាមានរយៈពេលយូរប៉ុណ្ណាហើយ បន្ទាប់ពីការធ្វើសមាហរណកម្មម្តងទៀតនាឆ្នាំ១៩៩៨ ដែលលោកបាននិយាយអំពីមេទ័ពផ្កាយមួយ ឬមេទ័ពផ្កាយពីរអំពីការហ៊ុកហ៊ឺនរបស់ពួកគេនៅឯប្រទេសវៀតណាម ។ លោក ផាន បានឆ្លើយថា លោកបាននិយាយជាមួយមេទ័ពទាំងនោះក្នុងអំឡុងពេលបរិភោគអាហារ ។ លោកបានតបទៀតថា វាគ្មានហេតុផលសមស្របអ្វីដែលត្រូវប្រាប់ពីឈ្មោះរបស់ពួកគេឡើយ ។ ពួកគេទាំងនោះបាន*




*សាលសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (រូបថត : អ.វ.ត.ក)*

ប្រាប់លោកថា ពួកគេមកពីភូមិភាគខាងកើតពីខេត្តស្វាយរៀងទៅកាន់ប្រទេសវៀតណាម ។

លោកមិនបានដឹងច្បាស់ពីតំបន់ណាមួយក្នុងប្រទេសវៀតណាមដែលពួកគេត្រូវបានហ្វឹកហ្វឺននោះទេ ។ ពួកគេមកពីកងពលធំផ្សេងៗគ្នា៖ កងពលធំលេខ៣៣០ លេខ៣៣៩ និងលេខ៧ ។ លោក ផាន មិនបានដឹងទេថា ពួកគេស្ថិតនៅភូមិភាគ៧ មែនឬមិនមែន ។ លោកមេធាវី កូប៉េ បានធ្វើការសាកសួរថា លោកមេទ័ព ដាង វ៉ាន់គួង ធ្លាប់ត្រូវបានរម្លឹកពីអ្វីដែលសាក្សីមិនអាចចងចាំបាន ។

លោកមេធាវី កូប៉េ បានអានការដកស្រង់ពីសៀវភៅមួយក្បាលរបស់លោក ណាយ៉ាន់ ចាន់ដា ត្រង់ចំណុចដែលលោកមេធាវីសំដៅទៅលើការជួបប្រជុំមួយដែលបានធ្វើឡើងលើទឹកដីកម្ពុជាក្នុងខែធ្នូ ឆ្នាំ១៩៧៨ ។ លោកមេធាវី កូប៉េ បានសាកសួរលោក ផាន ថាតើលោកនៅចាំដែរឬទេ ។ លោក ផាន បានឆ្លើយថា គាត់មិនដឹងនោះទេ ។ លោកមេធាវីបានសួរពីលោក ប៉ែន សុវណ្ណ ។ លោកមេធាវី កូប៉េ បានសួរថា តើពួកគេធ្លាប់រម្លឹកពីអ្វីដែលលោក ប៉ែន សុវណ្ណ ធ្លាប់ធ្វើដែរឬទេ ។ សាក្សីបានធ្វើការបដិសេធ ។ មេធាវីការពារក្តីរូបនេះបានថ្លែងថា លោកបានសង្ស័យថាសាក្សីបានដឹងអ្វីម្យ៉ាងពីរឿងនេះ ដោយសារតែ «តុលាការបានធ្វើការបដិសេធក្នុងការកោះហៅប្រជាជនដែលធ្លាប់មានវត្តមាន» ។ បន្ទាប់មកលោកមេធាវីបានសួរថាលោក ផាន នៅចាំការប្រយុទ្ធរវាងទ័ពកុម្មុយនីស្តវៀតណាម និងទ័ពកុម្មុយនីស្តកម្ពុជាមុនឆ្នាំ១៩៧៥ ដែរឬទេ ។ លោក ផាន បានតបថា លោកមិនដឹងពីរឿងនេះទេ ។ លោក កូប៉េ ក៏បានអានការដកស្រង់ពីរបាយការណ៍នៃការសម្ភាសន៍របស់ ឈូក រិន ត្រង់ចំណុចដែលលោកបាននិយាយថា មានជម្លោះរវាងទ័ពកុម្មុយនីស្តកម្ពុជា និងទ័ពវៀតកុង ។ លោកមេធាវី បានសាកសួរលោក ផាន ថា លោកធ្លាប់បានចូលរួមក្នុងជម្លោះជាមួយទ័ពវៀតកុង នាទិសនិរតីដែរឬទេ ។ លោក ផាន បានឆ្លើយថា នាពេលនោះ ឈូក រិន នៅខេត្តកំពត ចំណែកឯលោកនៅខេត្តតាកែវ ។ ឈូក រិន បានដឹងមុននៃហេតុការណ៍ទាំងនោះ ប៉ុន្តែរូបលោកមិនបានដឹងនោះឡើយ ។ លោកក៏មិនដឹងដែរថាជម្លោះនោះកើតឡើងញឹកញាប់យ៉ាងណានោះទេ ។

**សារទូរលេខ និងរបាយការណ៍**

លោកមេធាវី កូប៉េ បាននិយាយថា សហមេធាវីការពារក្តីឲ្យ នួន ជា បានផ្ញើសារអេឡិចត្រូនិចមកលោកកាលពីព្រឹកនេះ ដោយពួកគេមានបំណងចង់ប្រើប្រាស់ឯកសារដែលមានឈ្មោះ រិន ។ លោកស្រី ម៉ារី ហ្គីរ៉ូដ មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានជំទាស់ ហើយបាននិយាយថា សាក្សីមិនធ្លាប់ឃើញឯកសារនេះពីមុនទេ ។

លោកមេធាវី កូប៉េ បានដកស្រង់ឯកសារដែលបានធ្វើឡើងនាខែតុលា ឆ្នាំ១៩៧៧ និងត្រូវបានចុះហត្ថលេខាដោយ រិន ។ លោក ផាន បានឆ្លើយថា មានមនុស្សពីរនាក់ ឈ្មោះ រិន ហើយប្រកបក៏ដូចគ្នាដែរ ។ មេធាវី កូប៉េ ថា តើលោក រិន តែងតែត្រូវគេផ្ញើឯកសារឲ្យឬ ។ សាក្សីបានឆ្លើយថា ខ្លួនលោកផ្ទាល់មិនដែលទទួលបានឯកសារទាំងនោះឡើយ ដូច្នេះលោកមិនដឹងទេ ។ «ខ្ញុំមិនចេះដឹងពូរឿងអ្នកដទៃទេ» ហើយលោកបានប្រកាន់យ៉ាងខ្ជាប់នូវគោលការណ៍នៃការរក្សាការសម្ងាត់ ។ លោកមេធាវី កូប៉េ បានសួរថាលោក ផាន មានឯកសារ ថ្ងៃទី៣០ ខែ តុលា ឆ្នាំ ១៩៧៧ នៅចំពោះមុខលោក ដែលត្រូវបានចុះហត្ថលេខាដោយ រិន ។ សាក្សីបាននិយាយថា លោកមិនដឹងពីការកម្ទេចបុគ្គលណាម្នាក់ឡើយ ប៉ុន្តែឯកសារនេះវាហាក់បីដូចជាបញ្ជាក់ថាបុគ្គលភាគច្រើនដែលមានឈ្មោះក្នុងឯកសារនេះត្រូវបានចាប់ខ្លួន ។ នៅពេលលោកមេធាវី កូប៉េ បានធ្វើការសាកសួរពីសុន្ទរកថាដែលធ្វើការបង្ហាញតាមរយៈសារទូរលេខ លោក អេនខ្វេ ប៊ិយ ជំនួយការសហព្រះរាជអាជ្ញា បានធ្វើការបដិសេធ និងបាននិយាយថាសារទូរលេខមិនមានការជាប់ពាក់ព័ន្ធទៅនឹងសុន្ទរកថាឡើយ ។

លោកចៅក្រម ហ៊ុន បានណែនាំលោកមេធាវីឲ្យសួរអំពីផ្នែកទាំងបីនៃខ្ទាំងតាមរយៈសំណួរចំហ ដូចដែលលោកមេធាវី កូប៉េ បានធ្វើ ។ លោក ផាន បានឆ្លើយថាលោកមិនដឹងពីផ្នែកទាំងអស់នោះឡើយ ។ ជាមួយគ្នានោះ លោកមេធាវី កូប៉េ បានសរុបសេចក្តីក្នុងការសាកសួររបស់លោក ។

លោកចៅក្រម ហ្សង់ម៉ាក ឡាវែញ បានសាកសួរថាតើលោក ផាន ស្គាល់មនុស្សម្នាក់មានឈ្មោះថា រុំ ដែរឬទេ ។ លោក ផាន បានឆ្លើយថា លោកនៅកងពលធំលេខ១១៧ ក្នុងភូមិភាគឧត្តរ ។ ក្នុងឆ្នាំ១៩៧៨ កងពលធំលេខ ១១៧ មានទីតាំងស្ថិតនៅ

ភូមិភាគឧត្តរ ក្នុងតំបន់អន្លង់វែង ។

**ជម្លោះនៅភ្នំពេញ**

សវនាការត្រូវបានប្រគល់ទៅឲ្យ លោកស្រី អានតា ហ្គីស្សេ មេធាវីការពារក្តីឲ្យ ខៀវ សំផន ដើម្បីសាកសួរពីជម្លោះនៅខេត្តតាកែវ ។ លោក ផាន បានឆ្លើយថា កាលពីឆ្នាំ១៩៧៧ មានជម្លោះប្រដាប់អាវុធនៅទល់មុខនៃភ្នំដិន ។ ទីតាំងនៃបញ្ជាការដ្ឋានកងវរសេនាធំស្ថិតនៅក្នុងការិយាល័យស្រុកចូវដុក ។ កងវរសេនាធំផ្សេងទៀត លេខ១៣ និងលេខ១៤ មានទីតាំងស្ថិតនៅកន្លែងដទៃទៀត ។ កងវរសេនាធំលេខ១១ បានចូលរួមក្នុងការវាយលុកលើកដំបូង ។ លោកបាននិយាយថា កាលពីដំបូងគ្មានបញ្ហាចោទសំខាន់ៗនោះឡើយ ។ ប៉ុន្តែពេលខ្លះ "ពួកគេបានព្យាយាមជីកលេណដ្ឋានក្នុងដី" ។ "ការវាយប្រហារ" លើកទី៣ វៀតណាមបានបង្កើគ្រាប់បែកដៃតាមច្រកប៉ុស្តិ៍ព្រំដែនក្នុងទឹកដីកម្ពុជា ។ នៅពេលដែលទាហានខ្មែរក្រហមព្យាយាមដោះគ្រាប់បែកចេញ គ្រាប់ទាំងនោះក៏បានផ្ទុះឡើង ។ យោធាខ្មែរក្រហមព្យាយាមធ្វើការចរចាជាមួយទាហានវៀតណាម ។ ប៉ុន្តែទាហានទាំងនោះមិនព្រមស្តាប់ ។ លោកបាននិយាយថា "នេះហើយគឺជាបុសគល់នៃជម្លោះប្រដាប់អាវុធ" ។

**កម្មាភិបាលជាន់ខ្ពស់**

លោក ផាន បាននិយាយថា កងពលតូចលេខ២ មានកងវរសេនាតូចចំនួនបួន ១១, ១២, ១៣ និង ១៤ ។ ការប្រជុំនឹងត្រូវធ្វើឡើងជាប្រចាំ ។ ប្រសិនបើមាន "ករណីពិសេស" ណាមួយ ពួកគេនឹងធ្វើការប្រជុំជាពិសេស ។ លោក ផាន បានជួប តាម៉ុក ញឹកញាប់ណាស់នៅពេលដែលលោកបម្រើការក្នុងកងពលតូចពិសេស ។ លោកបានទៅខេត្តស្វាយរៀង ក្នុងឆ្នាំ១៩៧៨ ។ តាម៉ុកបានជ្រើសរើសទ័ពដើម្បីបញ្ជូនទៅខេត្តស្វាយរៀង ។ លោក ផាន បានជួប តាម៉ុក លើកទីមួយមុនឆ្នាំ១៩៧៥ ។

ខ្ញុំចាំបានថា តាម៉ុក មានការប្រុងប្រយ័ត្ននឹងពាក្យសម្តីរបស់គាត់ណាស់ ។ នៅពេលដែលគាត់និយាយពាក្យពេចន៍របស់គាត់គឺចំៗ ។ ពួកគេបាននិយាយថា លើក្បាល ម៉ុក មានមួក លើមួកម៉ុក មានមេឃ ។ លោក ផាន បាននិយាយថា នេះមានន័យថា គ្មាននរណាម្នាក់អាចបញ្ជា តាម៉ុក បានឡើយ ។

នៅពេលដែលលោក ផាន មកដល់ខេត្តស្វាយរៀង តាម៉ុកស្ថិតនៅឯខេត្តតាកែវ ។ វិន មានកាតព្វកិច្ចបញ្ជាទ័ព ។ ថ្នាក់លើរបស់វិនគឺ សុន សេន ដែលជាអ្នកគ្រប់គ្រងការបញ្ជា ។

លោកស្រីមេធាវី ហ្គីស្សេ បានដកស្រង់សេចក្តីថ្លែងការណ៍ និងបានសាកសួរថា តើលោក ផាន នៅចាំខែកក្កដា ឆ្នាំ១៩៧៧ ហើយលោកធ្លាប់ឃើញខិតបណ្ណដែលត្រូវបានផ្សព្វផ្សាយដោយទាហានវៀតណាមនាពេលនោះដែរឬទេ ។ លោកបានឆ្លើយថា លោកមិនដឹងពីរឿងខិតបណ្ណទាំងអស់នោះទេ ។ លោកបានតបថា ប៉ុន្តែបើរឿងជីករណ្តៅត្រង់សេនៅត្រង់ព្រំប្រទល់នៃខេត្តតាកែវ និងខេត្តកំពត កម្ពុជា និងវៀតណាម មានរណ្តៅត្រង់សេរៀងខ្លួន ។ រណ្តៅត្រង់សេខាងភាគីវៀតណាម គឺត្រូវបានសាងសង់ដោយប្រើបេតុង ។ ខាងកម្ពុជាវិញគឺត្រូវបានសាងសង់ដោយប្រើឈើ ។



អៀង ផាន ផ្តល់សក្ខីកម្មនៅមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទាក់ទងទៅនឹងសំណុំរឿង០០២ វគ្គ១ ដែលមានជនជាប់ចោទ នួន ជា និង ខៀវ សំផន

លោកស្រីមេធាវី ហ្គីស្សេ បានសាកសួរថា តើពួកគេបានទទួលការសង្ខេបស្ថានការណ៍ពី តាម៉ុក ដែលគេត្រូវប្រឈមមុខនៅក្នុងខេត្តស្វាយរៀងដែរឬទេ ។ លោក ផាន បាននិយាយថា ទាហានខ្មែរក្រហមត្រូវបានផ្តល់ដំណឹងថា វៀតណាមមិនបានធ្វើការលុកលុយទឹកដីកម្ពុជានៅឡើយ ប៉ុន្តែការពិតវៀតណាមបានធ្វើការលុកលុយដល់តំបន់ប្រាសាទបាត់

*ទៅហើយ ។ ពេលនោះ ទាហានកម្ពុជាខ្លះត្រូវបានសម្លាប់ ។ ឡានចំនួន៣៥ បានដឹកកងទ័ព ។ ទាហានមានចំនួន៤ក្រុមមកពីកងវរសេនាធំ ។ ឡានចំនួនបី បានបញ្ជូនទាហានពីខេត្តតាកែវ ទៅប្រាសាទ ។ ពួកគេចាំបាច់ត្រូវតែរៀបចំកងកម្លាំង ។ ពាក់កណ្តាលឆ្នាំ១៩៧៧ មានការប្រជុំមួយ ។ លោកដាន មិនចាំច្បាស់ទេថាក្នុងខែណាឲ្យប្រាកដ ។*

*លោកស្រីមេធាវី ហ្គីស្បេ បានសាកសួរពីកាតព្វកិច្ចយោធារបស់លោក ដាន មុនពេលលោកទៅកាន់ខេត្តស្វាយរៀង ។ លោកស្រីមេធាវី បានធ្វើការបង្ហាញឯកសារមួយទៅលោក ដាន ដែលបញ្ជាក់ថា ព្រះទន្លេ និង ស្ពានធ្នូក អាចឲ្យលោកចាំថា ជាកន្លែងដែលការប្រយុទ្ធគ្នាបានកើតឡើងក្រោយឆ្នាំ១៩៧៨ ដែរឬទេ ។*

## ***ជម្លោះជាមួយទាហានវៀតណាម***

*លោកស្រីមេធាវី ហ្គីស្បេ បានបង្ហាញឯកសារមួយទៀតទៅកាន់សាក្សី ។ លោក ដាន បាននិយាយថា លោកមិនបានដឹងពីឯកសារនោះទេ ។ មុនពេលដែលលោកចាកចេញ ថ្នាក់លើបានពន្យល់ប្រាប់ពីការទំនុកបម្រុងនានាដើម្បីផ្គត់ផ្គង់តម្រូវការ ។ កងយោធាបានឈរជើងការពារនៅឃុំប្រាសាទ ។ ឡានខ្លះបានមកដល់មុនក្នុងខេត្តស្វាយរៀង ។ ពួកគេចាំបាច់ត្រូវតែចាកចេញនាពេលយប់ ។ ដូច្នេះ ឡានខ្លះត្រូវបានកម្ទេចចោល ។ លោកស្រីមេធាវី ហ្គីស្បេ បានសួរថាតើលោក ដាន បានជួបកងពលតូចផ្សេងទៀតទេនៅពេលដែលលោកដាក់ពង្រាយកងទ័ព ។ លោក ដាន បាននិយាយថា គ្មានអ្វីលើសពីការរៀបចំទេដោយសារតែសភាពបន្ទាន់នៃបញ្ហាទាំងនោះ ។*

*យោធាខ្មែរក្រហមគ្មានលទ្ធភាពដេញទ័ពវៀតណាមទៅកាន់ប្រទេសរបស់គេវិញទេ ។ យោធាខ្មែរក្រហមបានព្យាយាមទប់ស្កាត់ ក៏ប៉ុន្តែវាគ្មានប្រសិទ្ធភាពឡើយ ។ «វៀតណាមមានបទពិសោធច្រើនជាងយើង» ។ កងកម្លាំងប្រដាប់អាវុធរបស់ពួកគេ (ខ្មែរក្រហម) មិនមានភាពខ្លាំងខ្លាគ្រប់គ្រាន់នោះទេ ។ ក្នុងហេតុផលនេះហើយដែលយើងគ្មានលទ្ធភាពក្នុងការលុកលុយ ។*

*បន្ទាប់មក លោកស្រីមេធាវី ហ្គីស្បេ បានធ្វើការសាកសួរលោក ដាន ដើម្បីឲ្យលោកមានប្រតិកម្មទៅកាន់សេចក្តីថ្លែងការណ៍របស់អនុបញ្ជាការរបស់គាត់គឺ សុខ ឈាន ដែលបាននិយាយថាទ័ពវៀតណាមបានបង្កប់មីនក្នុងវាលស្រែ ។ លោក ដាន បានយល់ស្រប ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី លោកមិនបានដឹងច្បាស់ទេថាគ្រាប់មីនទាំងនោះត្រូវបានបង្កប់ដោយទាហានវៀតណាម ឬយោធាខ្មែរក្រហម ។ ពួកគេបានដាក់មីនក្នុងវាលស្រែ ។ មនុស្សម្នាក់នៅខាងមុខបានស្លាប់ ។ ភាគីទាំងសងខាងបានបង្កប់មីនពេលយប់ ។ «នៅពេលដែលពួកគេមិនច្បាស់ជាមួយទីតាំងភូមិសាស្ត្រ ពួកគេនឹងបង្កប់មីននៅពេលយប់» ។ ពួកគេនឹងដោះមីនទាំងនោះចេញនៅពេលព្រឹក ។*

*លោក ដាន បានចូលរួមការប្រជុំជាមួយ សុន សេន នៅក្រោលគោ ។ លោកបានឮគេនិយាយពីឈ្មោះ កែ ពក ប៉ុន្តែលោកមិនបានជួបគាត់ទេដោយសារតែលោកស្ថិតនៅភូមិភាគឦសាន្តពេលនោះ ។*

*លោកបានបញ្ជាក់ថា លោកស្គាល់មនុស្សក្នុងរបាយការណ៍សរសេរនៃបទសម្ភាសន៍ដែលបានផ្តល់ឲ្យលោក ។ លោកដាន បានស្គាល់ កែ ពក ក្រោយឆ្នាំ១៩៧៨ តែលោកមិនដែលបានឃើញកែពកក្នុងខេត្តស្វាយរៀងទេ ។ លោកដាន ទើបបានស្គាល់ កែពកនាពេលនេះ ។ លោកស្រីមេធាវី ហ្គីស្បេ បានសួរ សាក្សីអំពីការចូលរួមរបស់ កែ ពក ក្នុងភូមិភាគបូព៌ា ហើយលោកស្រីក៏ចង់ដឹងថាលោក ដាន ធ្លាប់ឮពីរឿងនេះដែរឬទេ ។ លោកបានឆ្លើយថាលោកបានឮតែ សុន សេន ក្នុងភូមិភាគបូព៌ាតែប៉ុណ្ណោះ ។ លោកបានឮតាមរយៈការប្រជុំថា សុន សេន និងត្រូវកាន់កាប់ភូមិភាគឦសានដែលមាន ដូចជា ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី និងខេត្តក្រចេះ ។*

*លោកស្រីមេធាវី ហ្គីស្បេ បានធ្វើការសរុបនៃការសាកសួរ ។ លោកប្រធានបានធ្វើការអរគុណសាក្សី មុនពេលប្រកាសផ្អាកការស្តាប់ ដើម្បីសម្រាក ។*

## ***សាក្សី 2-TCW-1065***

*សាក្សី 2-TCW-1065 នៅតែបន្តលាក់អត្តសញ្ញាណដោយសារតែការបន្តក្នុងការស៊ើបអង្កេតក្នុងសំណុំរឿងផ្សេងទៀត ។*

*សាក្សីរូបនេះបានចូលរួមបដិវត្តន៍ក្នុងឆ្នាំ១៩៧០ ដោយសារតែការអំពាវនាវរបស់អតីតព្រះមហាក្សត្រ សម្តេច សីហនុ ។ លោកបានចូលជាទាហាន ។ លោកបានបម្រើការជាទាហានអស់*

រយៈពេលមួយឆ្នាំ មុនពេលចូលរៀនផ្នែកវេជ្ជសាស្ត្រ ។ លោកគឺជាពេទ្យទាហានពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៦ នៅសមរភូមិមុខ ។ លោកគឺជាពេទ្យទាហានថ្នាក់ស្រុក ។ លោកបានក្លាយជាប្រធានមន្ទីរពេទ្យក្នុងឆ្នាំ១៩៧៦ ។ ចុងឆ្នាំ១៩៧៧ កម្ពុជា និងវៀតណាមបានចាប់ផ្តើមមានជម្លោះ ។ ទាហានរបស់លោកដែលមកពីទីបញ្ជាការនៃកងពលធំរហូតដល់កងអនុសេនាតូចត្រូវបានកោះហៅទៅប្រជុំ ។ «ខ្ញុំមិនបានចូលរួមនោះទេ ហេតុអ្វី? ខ្ញុំត្រូវឈរជើងនៅសមរភូមិមុខ» ។ ថ្ងៃមួយ ម៉ោងប្រមាណជា៤ល្ងាច កម្មាភិបាលត្រូវបានចាប់ខ្លួន ហើយមានម្នាក់បានរត់គេច ។ មានមនុស្សម្នាក់ដឹកនាំពួកគេ ។ មានកម្មាភិបាលម្នាក់បានលោតរំលង ក្រោយពីឃើញអណ្តូង ។ «គាត់ត្រូវបានបាញ់ដោយកាំភ្លើង និងរងរបួសត្រង់ដៃរបស់គាត់» ។

## ផែនការប្រឆាំងនឹង ប៉ុល ពត

កម្មាភិបាលរងរបួសបានប្រាប់លោកថា មនុស្សទាំងអស់ដែលត្រូវបានកោះហៅមកប្រជុំត្រូវបានចាប់ខ្លួន ។ ខ្ញុំដឹងថា ប៉ុល ពត កំពុងមានផែនការក្បត់ ។

លោកបានហៅកម្មាភិបាលពីកងលេខ១៥៦ និងបានធ្វើការប្រជុំ ។ ពេលនោះ ជាពេលដែលពួកយើងធ្វើការពិភាក្សាថា ពួកយើងគួរធ្វើអ្វីខ្លះ ។ ខ្ញុំមានផែនការវាយប្រហារ ប៉ុល ពត ។ ពេលនោះ ទាហានរបស់ខ្ញុំមិនត្រឹមតែរងការវាយប្រហារពីទ័ពវៀតណាមប៉ុណ្ណោះទេ ក៏ប៉ុន្តែរងការវាយប្រហារពីទ័ព ប៉ុល ពត ដែរ ។ ខ្ញុំត្រូវប្រឈមមុខជាមួយបក្សពីរផ្សេងគ្នា ។

ពេលនោះ លោកគ្មានស្បៀង និងអំបិលឡើយ ។ ប៉ុន្តែលោកត្រូវតែនៅមានជីវិត ។ ខ្ញុំបានបន្ថែមបន្ទុកក្នុងការវាយប្រហារប្រឆាំងនឹង ប៉ុល ពត ពីរពេលក្នុងមួយថ្ងៃ ។ លោកបានវាយលុកយកថ្នាំពេទ្យ អង្ករ និង អាវុធ របស់ ប៉ុល ពត ។ «ពេលនោះ ពួកគេទាំងអស់គឺជាសត្រូវរបស់ខ្ញុំ» ។ ក្រោយមក លោកបានសម្រេចក្នុងការប្រមូលអាវុធ អង្រឹង និង ស្បៀង ។

ពេលនោះមានតែខ្ញុំទេដែលមានទ័ពដើម្បីវាយប្រហារ ប៉ុល ពត ។ ក្នុងឆ្នាំ១៩៧៨ ខ្ញុំបានរៀបចំក្រុមចារកិច្ចដើម្បីស៊ើបព័ត៌មាន ។ ពួកគេមានឧបករណ៍ទំនាក់ទំនង ។ ពួកគេមិនស្ថិតនៅកន្លែងតែមួយនោះទេ ។ ថ្ងៃមួយ ពួកគេបានរកឃើញលិខិតដែលបានចារទឹកប៊ិចក្រហម ។ លិខិតនោះបានសរសេរថា ពួកគេចង់ទាក់ទងយើង ។

លោកបានសួរទាហានលោកថា តើអ្នកណាចង់ទាក់ទងលោក ។ អតីតយោធាខ្មែររូបនោះបាននិយាយថា ពួកគេចង់សហការជាមួយក្រុមចារកិច្ច ។ លោកមិនទាន់មានការជឿទុកចិត្តនោះទេ ។ លោកបានពិភាក្សាពីបញ្ហានេះជាមួយសមាជិករបស់លោកចំនួន១២នាក់ ។

## ការសហការជាមួយវៀតណាម

លោកបានចរចាជាមួយវៀតណាម ហើយបានអញ្ជើញពួកគេឲ្យមកយកគ្រឿងសព្វាវុធ ។ លោកបានដឹកនាំទាហាន៦០នាក់ដើម្បីទទួលយកគ្រាប់រំសេវ ។ «ខ្ញុំសហការជាមួយវៀតណាមដើម្បីកេណ្ឌប្រជាជន១.០០០នាក់មកវិញ» ។ លោកបានបន្ត ៖ «ពួកយើងបានចាប់ផ្តើមធ្វើការវាយប្រហារលើខ្មែរក្រហម ។ ខ្មែរក្រហមមានភាពវង្វេងវង្វាន់ ។ ក្នុងពេលប្រយុទ្ធជាមួយខ្មែរក្រហម ខ្ញុំដើរលើផ្លូវម្ខាង ហើយទាហានវៀតណាមដើរលើផ្លូវម្ខាងទៀត» ។ ក្រោយមកសាក្សីបានធ្លាក់ខ្លួនឈឺ ហើយវៀតណាមបានស្នើឲ្យលោករៀបចំទ័ពជួរមុខ ប៉ុន្តែលោកប្រាប់ពួកគេថា មិនអាចធ្វើបានឡើយ ។ មានឧទ្ធម្ភាគចក្រមួយបានដឹកលោកទៅកាន់ទីក្រុងហូជីមិញ ជាកន្លែងដែលលោកបានទៅដល់ម៉ោង៥ល្ងាច ហើយបានស្នាក់នៅទីនោះប្រមាណជាមួយសប្តាហ៍ ។

មានការសម្រេចចិត្តមួយក្នុងការផ្លាស់ប្តូរមុខងារ និងតួនាទីរបស់លោក ។ «ខ្ញុំត្រូវបានផ្ទេរឲ្យក្លាយជាគណៈកម្មការរៀបចំជាមួយប្រទេសវៀតណាម ។ កិច្ចការទាក់ទងនឹងវៀតណាមត្រូវតែឆ្លងកាត់ខ្ញុំ ។ គាឈុន ក៏ជាផ្នែកមួយនៃការរៀបចំគណៈកម្មការសម្រាប់កម្ពុជាផងដែរ» ។ មានវគ្គបណ្តុះបណ្តាលបីថ្ងៃសិក្សាពីធនធានរបស់កម្ពុជា ។

លោកបានទៅខេត្តឡុងអាន ហើយស្នាក់នៅជាមួយមេបញ្ជាការនៃតំបន់លេខ៧ ។

យើងចាំបាច់ត្រូវរកយុទ្ធសាស្ត្រក្នុងការវាយបក ពីព្រោះពេលនោះ ប៉ុល ពត បានវាយប្រហារ និងធ្វើបាបប្រជាជន ។

ក្នុងឆ្នាំ១៩៧៩ លោកត្រូវបានចាត់តាំងជាថ្មីឲ្យកាន់កាប់ក្នុងតំបន់២ ។ «ពួកគេបានរៀបចំខ្មែរចំនួន៣០នាក់ និងវៀតណាមចំនួន៣០នាក់ដើម្បីការពារខ្ញុំ ។

### *កម្មាភិបាល*

*លោក និល ណុន ប្រធានចៅក្រម បានកាត់សម្តីសាក្សី ហើយបានសាកសួរថា សាក្សីបានស្ថិតនៅកងទាហានភាគីមួយណា ។ សាក្សីបាននិយាយថា ជម្លោះបានកើតឡើងនាខែធ្នូ ឆ្នាំ ១៩៧៧ លោកត្រូវបានចាត់ឲ្យធ្វើការនៅមន្ទីរពេទ្យ១៥៧ ដែលស្ថិតក្រោមកងពលធំ ។ ដំបូងឡើយមេបញ្ជាការកងពលធំគឺ តាផន ហើយ ហេង សំរិន កាន់កាប់ទ័ព ។ ខ្ញុំ និង ត្រី គឺជាតំណាង ។ មេបញ្ជាការគឺនៅសមរភូមិមុខ ប៉ុន្តែត្រូវបានកោះហៅមកប្រជុំ ។ ហេង សំរិន ត្រូវបានចាត់តាំងជាបុគ្គលិកការិយាល័យកន្លែងផ្សេង ។ អ្នកផ្សេងក្រៅពីនេះត្រូវបានចាប់ខ្លួន ហើយ ផន ក៏បានបាត់ខ្លួន ។*

*មានដើមចមចំនួនពីរដែលបង្កឲ្យមានជម្លោះ ។ «ជម្លោះដំបូងត្រូវបានកើតឡើងក្នុងឆ្នាំ១៩៧៣ ។ វាបណ្តាលមកពីសម្ភារដែលប្រទេសមហាអំណាចផ្តល់ឲ្យប្រទេសទាំងនេះ មានភាពមិនស្មើគ្នា ។ ចំណែកកត្តាទី២ ដែលនាំឲ្យមានសង្គ្រាមនោះ គឺជម្លោះព្រំដែនដោយសារតែការខណ្ឌចែកព្រំប្រទល់មិនច្បាស់លាស់» ។*

*យោងតាមជម្លោះក្នុងឆ្នាំ ១៩៧៣ សាក្សីបាននិយាយថា សម្ភារមានប្រភពតែមួយ គឺពីប្រទេសចិន ។ សម្ភារទាំងនោះត្រូវបានផ្គត់ផ្គង់តាមរយៈវៀតណាម ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី កងទ័ពខ្មែរក្រហមមិនបានទទួលសម្ភារដែលចិនបានបញ្ជូនឲ្យពួកគេនោះឡើយ ។ «មានការប្រជុំមួយបានធ្វើឡើងនាពេលដែលពួកយើងលែងធ្វើការជាមួយគ្នា ។ ប្រជាជនខ្មែរគួរតែស្ថិតនៅខាងភាគីខ្មែរ ហើយប្រជាជនវៀតណាមគួរតែស្ថិតនៅខាងភាគីវៀតណាម» ។*

### *ជម្លោះជាមួយវៀតណាមៈ ការវាយប្រហារ និងការវាយបក*

*បន្ទាប់មក លោកប្រធានបានសាកសួរថាអ្នកណាជាអ្នកចាប់ផ្តើមរំលោភបូរណភាពដែនដីនៃប្រទេស ។ អ្នកភូមិខ្លះបានព្យាយាមថា «មានអារម្មណ៍ថាបរាជ័យ ដោយសារតែពួកគេស្ថិតនៅខាងភាគីវៀតណាម» ។ អ្នកស៊ើបអង្កេតបានចាប់ផ្តើមសិក្សាពីស្ថានភាពពេលនោះ ។*

*បើទោះបីជាយ៉ាងនេះក្តី ពួកគេមិនអាចដោះស្រាយបញ្ហាបានឡើយ ។ ការប្រជុំគឺត្រូវបានធ្វើឡើង តែគ្មានដំណោះស្រាយ ។*

*ដូច្នេះ លោកបាននិយាយថា «រឿងតែមួយដែលពួកយើងអាចធ្វើបាននោះគឺដោះស្រាយជម្លោះប្រដាប់អាវុធ» លោកបាននិយាយថា ជម្លោះគឺកើតចេញពីភាគីទាំងសងខាង ។*

*លោកមិនបានដឹងពីចម្ងាយជាក់លាក់ទេ ។ ពួកគេបានឈានដិតដល់វិមានមួយដែលបច្ចុប្បន្នជាវិមានរដ្ឋសភាជាតិ ហើយពួកគេក៏បានបាត់ខ្លួន ។ នោះហើយគឺជាដើមចមនៃជម្លោះ ។ ប្រសិនបើអ្នកមិនជឿខ្ញុំ អ្នកអាចទៅមើលស្ថានភាពនៅទីនោះផ្ទាល់ ។ លោកប្រធានបានពន្យល់ថា ជម្លោះកើតឡើងនាផ្នែកខ្លះនៃភូមិភាគខាងបូព៌ា មិនសូវមានភាពតានតឹងដូចជម្លោះនៅភូមិភាគផ្សេងនោះឡើយ ។*

*កងពលធំលេខ៤ បានឈរជើងលើផ្លូវជាតិលេខ៧ ហើយកងពលធំលេខ៥ ត្រូវបានបង្កើតឡើងថ្មីៗ ។ មានកងពលធំផ្សេងមួយទៀត ដូច្នេះក្នុងភូមិភាគខាងកើតមានកងពលធំចំនួន៣ ។ ក្នុងមួយកងអនុសេនាធំមានទាហាន១២០រូប ហើយក្នុងមួយកងវរសេនាតូចមានទាហានប្រមាណជា៥០០រូប ។*

*ជឿន គឺជាមេបញ្ជាការក្នុងកងពលធំលេខ៣ ។ ហេង សំរិន គឺជាមេបញ្ជាការក្នុងកងពលធំលេខ៤ ។ ទីបញ្ជាការដ្ឋានកងពលធំមានទីតាំងស្ថិតនៅក្នុងខេត្តស្វាយរៀង ប៉ុន្តែលោកមិនដឹងច្បាស់ថា វាស្ថិតនៅទីណាឲ្យប្រាកដនោះទេ ។ កងពលធំលេខ៤ មានទីតាំងស្ថិតលើផ្លូវជាតិលេខ៧ ក្រោយពីវៀតណាមបានវាយលុក ។ ជឿន បានឈរជើងជាមួយលោកក្នុងកងពលធំលេខ១៥៧ ។ លោកបានថ្លែងថា មុនឆ្នាំ១៩៧៧ គ្មានទាហានភូមិភាគកណ្តាលនោះឡើយ ហើយមានតែទាហាននៃភូមិភាគបូព៌ាប៉ុណ្ណោះដែលកាន់កាប់ភូមិភាគ ។*

*បន្ទាប់មក លោកប្រធានចៅក្រមបានសាកសួរថា ពេលណាខ្លះដែលភាគីកម្ពុជាបានប្រើប្រាស់កម្លាំងទ័ពដើម្បីលុកលុយទឹកដីវៀតណាម ។ សាក្សីបានឆ្លើយថា លោកមិនអាចផ្តល់សក្ខីកម្មអំពីភូមិភាគបានទេ ប៉ុន្តែមានការវាយបកទៅវិញទៅមក ។ ក្នុងឆ្នាំ ១៩៧៧ ក្រោយមក ពួកគេមិនមានកម្លាំងរុញច្រានទ័ពវៀតណាមទៅវិញទេ ។ ពួកយើងមិនអាចវាយប្រឆាំងនឹងទ័ពវៀតណាមបានឡើយ ។ មានកងផ្សេងៗគ្នាបានចូលទឹកដីយើង ។ លោកបាននិយាយថា ក្នុងកងរបស់លោក គោលដៅគឺវាយលុកបន្ទាយទាហានលេខ២៧ ។ យើងត្រូវតែកម្ទេចបន្ទាយទាហាននោះ ។ ទោះបីជាយ៉ាងណាក្តី កងទ័ពកម្ពុជាត្រូវបានរុញច្រានទៅវិញឲ្យ*

ធ្វើការដកថយ ។ ទាហានវង់របួសត្រូវបានបញ្ជូនចេញតាមរយៈផ្លូវក្រោមដី ។ ពួកយើងមិនអាចបញ្ជូនពួកគេតាមទីវាលបានឡើយ ។ រឿងនេះកើតឡើងលើភាគីទាំងសងខាង ។ ពួកយើងមិនបានប្រយុទ្ធគ្នាក្នុងរយៈចម្ងាយឆ្ងាយនោះទេ ។ បន្ទាយលេខ២៧ មិនស្ថិតនៅឆ្ងាយពីស្ពានដែកនោះឡើយ ។

ប្រធានចៅក្រម និល ណុន បានសួរថា ភាគីវៀតណាមបានចូលទឹកដីកម្ពុជាចម្ងាយណា? សាក្សីបានឆ្លើយថា លោកមិនអាចចាំថ្ងៃខែជាក់លាក់នោះទេ ប៉ុន្តែទាហានវៀតណាមបានវាយលុកពួកគេតាមរយៈផ្លូវលេខ៧ ចុងឆ្នាំ១៩៧៧ ។ ពួកគេបានចូលមកក្នុងទឹកដីយើងប្រហែលជា២០គីឡូម៉ែត្រ ។ ពួកគេបានមកដល់ភូមិខ្នារ ក្នុងឃុំស្រឡប់ ក្នុងស្រុកត្បូងឃ្មុំ ។ ពួកគេព្យាយាមចូលទៅឲ្យកាន់តែជ្រៅក្នុងប៉ែកខាងលិច ប៉ុន្តែពួកគេមិនអាចធ្វើបានឡើយ ។

ភាគីវៀតណាមមានកាំភ្លើងធំ យន្តហោះចម្បាំង និងរថក្រោះ ។ ទោះជាយ៉ាងនេះក្តី នៅពេលដែលពួកគេចូលមកកាន់ទឹកដីរបស់យើង ពួកគេគ្មានយន្តហោះចម្បាំងនោះឡើយ ។ កងយោធារបស់លោកបានទទួលជោគជ័យក្នុងការដុតកម្ទេចរថក្រោះរបស់វៀតណាម ។ ក្រោយពីភូមិភាគបានធ្វើការសម្រេចចិត្តកងពលធំបានដាក់កងវរសេនាតូចដើម្បីវាយលុក ។

ក្រោយមក ប្រធានចៅក្រមបានសាកសួរថា វៀតណាមបានចូលទឹកដីកម្ពុជាប៉ុន្មានដង ហើយការកម្ទេចមួយលើកៗមានសភាពធ្ងន់ប៉ុណ្ណា ។ សាក្សីបានតបថា ការប្រយុទ្ធគ្នាមាន២ប្រភេទ ។ មួយគឺ ប្រភេទវាយលុកនៅនឹងកន្លែង និងមួយប្រភេទទៀត គឺការវាយបកដើម្បីរំដោះប្រទេស ។ ក្នុងឆ្នាំ១៩៧៧ កងទ័ពវៀតណាមបានធ្វើការវាយប្រហារមកលើទឹកដីកម្ពុជា ។ កងពលធំលេខ២ពីភូមិភាគកណ្តាលត្រូវបានបញ្ជូនមកជួយកងរបស់លោក ។ នេះមានភាពស៊ីគ្នាជាមួយ «ការធ្វើរដ្ឋប្រហារផ្ទៃក្នុង» ។ ចាប់តាំងពីពេលនោះមក កម្មាភិបាលត្រូវក្លាយជាមុខសញ្ញាដើម្បីប្រហារជីវិត ។ សាក្សីបានពន្យល់ថា ពេលនោះ ជាពេលដែល ប៉ុល ពត មានជម្លោះនៅក្នុងស្រុកផង និងជម្លោះជាមួយវៀតណាមផង ។ កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ ១៩៧៧ ខ្ញុំបានចាប់ផ្តើមវាយប្រហារ ប៉ុល ពត ។

**ការដឹកនាំភូមិភាគបូព៌ា ៖ សោ ភឹម**

ត្រឡប់ទៅប្រធានបទបន្ទាប់ ប្រធានចៅក្រម បានសួរថា សាក្សីបានដឹងពីការដឹកនាំនៃភូមិភាគបូព៌ាដែរឬទេ ។ សាក្សីបានឆ្លើយថា លោកស្គាល់តែបុគ្គលម្នាក់ឈ្មោះ ភឹម មានរហស្សនាមថា យ៉ាន ។ យាយរបស់លោក និងយាយរបស់ សោ ភឹម គឺជាបងប្អូនជីដូនមួយនឹងគ្នា ដូច្នេះ សោ ភឹម មានទំនាក់ទំនងជាមួយលោក ។ សោ ភឹម មិនបានក្បត់យើងទាំងអស់គ្នានោះឡើយ ប៉ុន្តែខ្ញុំនិយាយថា "ប៉ុល ពត" បានក្បត់ពួកយើង ដោយសារតែ ប៉ុល ពត បានសម្លាប់មនុស្សជាច្រើន ។ លោកប្រធានចៅក្រមបានសួរសាក្សីថា ប្រសិនបើ ប៉ុល ពត ក្បត់ពួកគេ ហេតុអ្វី សោ ភឹម មិនប្រាប់លោក ។ សោ ភឹម ផ្ទាល់មិនច្បាស់ក្នុងចិត្ត ហេតុដូចនេះហើយ គាត់បានទៅដើម្បីសុំការបកស្រាយបំភ្លឺ ។

សាក្សីមិនដឹងពីថ្ងៃខែកំណើត សោ ភឹម នោះទេ ប៉ុន្តែលោកដឹងថា ភឹម បានកើតនៅស្រុកស្វាយទាប ខេត្តស្វាយរៀង ។ ពួកគេជាប់សាច់ឈាមនឹងគ្នា ។ ក្រុមគ្រួសារសាច់ញាតិនៃសាក្សីធ្លាប់ធ្វើការនៅក្រសួងកសិកម្ម ។ ពេលនោះ យាយខាងប្រពន្ធរបស់លោកបានស្លាប់ ។ លោកគ្មានផែនការដើម្បីជួប សោ ភឹម ឡើយ ប៉ុន្តែលោកនឹងជួប សោ ភឹម ប្រសិនបើលោកមានឱកាស ។ ពេលខ្លះសាក្សីបានទៅលេងក្រុមគ្រួសារនៅឯក្រសួងកសិកម្ម ជាកន្លែងដែលម្តាយបង្កើត យាយ និងសាច់ញាតិផ្សេងទៀតរបស់លោកធ្វើការ ។ លោកប្រធានចៅក្រមបានសួរថា ទីបញ្ជាការភូមិភាគបូព៌ាស្ថិតនៅទីណា ។ លោកបានឆ្លើយថា ដើមឡើយវាមានទីតាំងនៅសួង ក្នុងតំបន់២១ ភាគខាងជើងនៃផ្លូវជាតិទៅកាន់សំរោង ហើយក្រោយមក ទីបញ្ជាការក៏បានផ្លាស់ទៅសំរោង ដែលស្ថិតនៅភាគខាងកើតនៃភូមិដូនតី «ទួលសំរោង» ឃុំទួលគគីរ ។ នៅទីនោះមានផ្ទះជាច្រើន និងមានមន្ទីរពេទ្យមួយ ។

ក្រោយពីសម្រាក សាក្សីបាននិយាយថា លោកបានជួប សោ ភឹម ប្រហែលជាពីរបីឆ្នាំក្រោយពេលសង្គ្រាមបានចាប់ផ្តើម ប៉ុន្តែពួកយើងមិនដែលពិភាក្សាកិច្ចការប្រទេសជាតិឡើយ ។

លោកប្រធានបានសួរសាក្សីថា នៅពេលណា និងនៅទីកន្លែងណាដែលការជួបជុំក្នុងពេលដែលសាក្សី បានពិភាក្សាពីផែនការក្បត់របស់ ប៉ុល ពត ជាមួយ សោ ភឹម ។ សាក្សីបានឆ្លើយថា វាកើតឡើងក្នុងឆ្នាំ១៩៧៧ ។ សាក្សីបានជួប សោ ភឹម នាល្ងាចមួយ

ហើយ សោ ភឹម បានសួរលោកពីស្ថានការណ៍យ៉ាងដូចម្តេចខ្លះ ។ លោកបានឆ្លើយថា ស្ថានការណ៍មិនល្អទេ ។ ដើមឈើដែលមិនមានខ្យល់បក់ប៉ះប្រាកដជាដួលរលំជាមិនខាន ។ សោ ភឹម បាននិយាយថា មានព្យុះនៅឯប្រទេសចិន ប៉ុន្តែផលប៉ះពាល់បែរជាធ្លាក់លើកម្ពុជាទៅវិញ ។ សោ ភឹម បានបន្តថា លោកបានសាងសង់ផ្ទះមួយដើម្បីទទួលភ្ញៀវជនជាតិចិន ។ បញ្ហានោះគឺយើងចាប់ផ្តើមវាយជាមួយវៀតណាម ។ ពេលនោះ វៀតណាមមិនបានវាយប្រហារយើងនោះឡើយ ។ សាក្សីបានគិតថា មានអ្នកខ្លះក្បត់ ហើយលោកបានប្រាប់ សោ ភឹម ថា ប៉ុល ពត ប្រហែលជាក្បត់ ។ សោ ភឹម បានតបថា ប៉ុល ពត បានប្រាប់លោកនូវអ្វីដែលលោកមិនជឿ ។ វាគឺជាការវិភាគរបស់លោកដែលថា សុន សេន ផ្តើមរដ្ឋប្រហារ ។

វាជាគំនិតផ្ទាល់ខ្លួនរបស់សាក្សីដែលថា សោ ភឹម បានអស់សង្ឃឹម ។ ក្នុងឆ្នាំ១៩៧៨ នេះគឺជាហេតុផលដែល ភឹម បានបញ្ជូននីរសារដើម្បីសាកសួរ ហេតុអ្វីបានជា ប៉ុល ពត បញ្ជូនកម្មាភិបាលទៅកាន់ភូមិភាគបូព៌ាដើម្បីសម្លាប់យោធាទាំងនោះ ។ ប្រសិនបើជឿខ្ញុំ សោ ភឹម ប្រហែលជាអាចគេចខ្លួនបាន ហើយគាត់ក៏ប្រហែលជាត្រូវទទួលបានការការពារ ។ ដូចនេះ សោ ភឹម បានទៅជាមួយនីរសាររបស់លោក ហើយនីរសាររបស់លោកម្នាក់ក្នុងចំណោមអ្នកដទៃទៀតត្រូវបានចាប់ខ្លួន ។ ក្រោយមក ទាហានបានបើករថក្រោះមកឡោមព័ទ្ធលោក ដើម្បីចាប់ខ្លួនលោក ។ វាគឺជាជោគវាសនារបស់លោក ។ សោ ភឹម គ្មានជម្រើសក្រៅពីសម្លាប់ខ្លួន ។ មុនពេលលោកស្លាប់ លោកបានប្រាប់អ្នកនៅជុំវិញលោកថាឲ្យក្រោកឈរតតាំង ។

សាក្សីមិនបានដឹងច្បាស់ពីទីតាំងពិតប្រាកដរបស់ សោ ភឹម ឡើយ ប៉ុន្តែនីរសារបានប្រាប់លោកថា សោ ភឹម បានបាញ់សម្លាប់ខ្លួននៅអរិយក្សត្រ ។ នីរសាររបស់លោកក៏ត្រូវបានយោធាបាញ់រះពីប៉ែកនិរតី ប៉ុន្តែបានរួចជីវិតដោយលាក់ខ្លួនក្នុងបឹងមួយ ។ ក្មួយប្រុសរបស់ សោ ភឹម ដែលមានឈ្មោះថា អ៊ឹង សព្វថ្ងៃធ្វើការនៅឯប្រទេសថៃ ។ ប្រធានចៅក្រមបានសួរថា វាពិតជាត្រឹមត្រូវមែនឬទេ ដែល សោ ភឹម បានធ្លាក់ខ្លួនក្នុងភាពអស់សង្ឃឹម ហើយបានបាញ់សម្លាប់នីរសាររបស់ខ្លួន មុនពេលបាញ់សម្លាប់ខ្លួន ដូចអ្វីដែលសាក្សីបានបកស្រាយ ។ សាក្សីមិនដឹងថាមានរឿងអ្វីកើតឡើងចំពោះអ្នកបើកបរនោះទេ ។

សាក្សីមិនស្គាល់ឈ្មោះពិតរបស់ប្រពន្ធ សោ ភឹម នោះទេ ប៉ុន្តែលោកដឹងអ្នកស្រីមានរហស្សនាមថា យាយ ការ៉ូ ។ ពួកគេមានកូនប្រុសម្នាក់ និងស្រីម្នាក់ ។ កូនស្រីម្នាក់ក្នុងចំណោមកូនរបស់ពួកគេមានឈ្មោះថា កាស៊ី ហើយប្តីរបស់នាងគឺជាកូនរបស់ រស់ ញឹម ។ សាក្សីមិនដឹងពីអ្វីផ្សេងទៀតនោះឡើយ ។

ណាត ដែលជាកូនប្រុសគឺជាប្រធានមន្ទីរពេទ្យព-២ ។ កាស៊ី គឺជាកូនស្រី ។ យាយ ការ៉ូ បានស្លាប់ ប៉ុន្តែលោកមិនដឹងថានៅទីណាទេ ។ លោកបានឮថាអ្នកស្រីត្រូវបានចាប់យកទៅសម្លាប់ ។

បន្ទាប់មក ប្រធានចៅក្រម និល ណុន ចង់ដឹងថា តើសាក្សីស្គាល់ រស់ ញឹម ដែរឬទេ ។ សាក្សីបានឆ្លើយថា លោកមិនស្គាល់គាត់ជិតដិតទេ ប៉ុន្តែលោកដឹងថា រស់ ញឹម គឺជាលេខាភូមិភាគពាយ័ព្យ ហើយកូនប្រុសរបស់លោកបានរៀបការជាមួយកូន សោ ភឹម ។

សាក្សីមិនស្គាល់ឈ្មោះ សួស នៅ ដែលមានរហស្សនាមថា ឈូក ជាមនុស្សដែលសាក្សីបដិសេធទេ ។ សាក្សីបានឮពីឈ្មោះ ចាន់ សីហុង មានរហស្សនាមថា ចាន់ ប៉ុន្តែសាក្សីមិនបានជួបលោកផ្ទាល់នោះទេ ។

បន្ទាប់មកសាក្សីបានងាកទៅបញ្ហានៃការបះបោរ ដែលសាក្សីបានពិភាក្សាជាមួយ សោ ភឹម ដែលជាលេខាភូមិភាគបូព៌ា ។ សាក្សីមិនដឹងថាតើ សោ ភឹម មានទំនាក់ទំនងជាមួយក្រុមបះបោរឬយ៉ាងណាទេ ។

## សារទូរលេខ និង របាយការណ៍

បន្ទាប់មក លោកប្រធានបានងាកទៅមើលឯកសារមួយចំនួនដែលអាចកំណត់អត្តសញ្ញាណបុគ្គលខ្លះបាន ។ ប្រធានចៅក្រម និល ណុន បានសំដៅទៅលើទូរលេខនាថ្ងៃ៦ ខែវិច្ឆិកា ឆ្នាំ ១៩៧៧ ដែលត្រូវបានចុះហត្ថលេខាដោយ ឆុន ។ សាក្សីបាននិយាយថា លោកមិនស្គាល់ ឆុន នោះឡើយ ។ ប្រធានចៅក្រមបានដកស្រង់ហេតុការណ៍មួយ ដែលមនុស្សម្នាក់បានបាត់បង់ស្មារតី ហើយធ្លាក់ពីលើកៅអីនៅពេលដែលបានឃើញឯកសារនោះ ។ ប្រធានចៅក្រមបានសួរថា តើរឿងនេះពិតជាកើតមានមែនឬទេ ប៉ុន្តែសាក្សីបានបដិសេធ ។ សាក្សីមិនដែលបានឮពីនរណាម្នាក់បានធ្លាក់ពីលើកៅ

អីពេលប្រជុំទេ ។

បន្ទាប់មកលោកបានសួរថាតើ សោ ភីម មានរហស្សនាមអ្វីផ្សេងទៀតទេ ។ សាក្សីបានឆ្លើយថាលោកស្គាល់តែរហស្សនាម សោ យ៉ាន ។ សាក្សីក៏មិនដែលធ្លាប់ឮពីនរណាម្នាក់ឈ្មោះ ឆុន ដែរ ។

សាក្សីបានចង្អុលទៅសារទូរលេខចុះថ្ងៃទី១០ ខែធ្នូឆ្នាំ១៩៧៧ ដែលបានដកស្រង់ថា វៀតណាមបានពង្រីកការវាយលុកនៅខេត្តស្វាយរៀង ហើយបានបង្ខំឲ្យដកទ័ពចេញ ។ ប្រធានចៅក្រមបានសួរថាតើសាក្សីស្គាល់ទីតាំងនោះឬទេ? តែសាក្សីបានឆ្លើយថាលោកធ្លាប់ឮពីឯកសារ ប៉ុន្តែគ្មាននរណាម្នាក់មានឈ្មោះ ឆុន នោះទេ ។ ការវាយប្រហារត្រូវបានផ្ទុះឡើងរវាងទាហាន ។ ក្រុមទាំងនោះបានធ្វើបដិវត្តន៍ ហើយវាយលុកកងកម្លាំងរបស់សាក្សីវិញ ។

ពេលនោះ មានស្ថានភាពពីរកើតមានឡើង ។ ពួកគេបានវាយលុកវៀតណាមក្នុងឆ្នាំ១៩៧៧ ក្រោយពេលដែលវៀតណាមបណ្តេញកងទ័ពចេញ ហើយចូលប្រទេស ។ កែ ពក ត្រូវបានបញ្ជូនដើម្បីការពារពួកគេ ប៉ុន្តែ កែ ពក បែរជាធ្វើការវាយប្រហារទៅវិញ ។ ប្រធានចៅក្រមបាននិយាយថា មេបញ្ជាការម្នាក់ត្រូវបានកម្ទេច នេះបើយោងតាមរបាយការណ៍ ។ សាក្សីបាននិយាយថាលោកមិនជឿទេថា មានហេតុការណ៍នេះកើតឡើង ។ គ្មានមេបញ្ជាការណាម្នាក់ត្រូវបានកម្ទេចឡើយ ។

ប្រធានចៅក្រម និល ណុន បានបង្ហាញឯកសារចំនួនពីរទៀតទៅកាន់សាក្សី ដែលបានរំឭកពីការវាយប្រហារ និងរថក្រោះដែលបានចូលមកក្នុងទឹកដីកម្ពុជា ។ សាក្សីបានតបថា លោកនៅចាំពីឯកសារនេះ ហើយវាត្រូវបានផ្ញើសម្រាប់ សោ ភីម ។ សារទូរលេខទី២ មានការជាប់ពាក់ព័ន្ធទៅនឹងទីតាំងនៃកោះ និងការវាយប្រហារពីសំណាក់ទាហានវៀតណាម ។ តុលាការបានសាកសួរថាសាក្សីបានដឹងពីហេតុការណ៍ ឬមនុស្សឈ្មោះ ភួង ដែលបានបញ្ជូនសារទូរលេខដែរឬទេ ។ សាក្សីបានតបថាស្ថានភាពគឺបានកើតឡើងដូច្នេះ ទូរលេខមានប្រភពមកពីភូមិភាគបូព៌ា ។ សាក្សីបាននិយាយថា លោកមិនស្គាល់ ភួង ច្បាស់ទេ ។ លោកមិនដឹងពីឋានៈរបស់ ភួង ។ ក្នុងនាមជាមន្ត្រីស៊ីវិលត្រូវធ្វើកិច្ចការទីទៃពីគ្នាដែលចាត់តាំងពីមន្ត្រីយោធា ពួកយើងមានកិច្ចការផ្សេងៗដែលត្រូវធ្វើ ។

ប្រធានចៅក្រមបានអានរបាយការណ៍ផ្សេងទៀតដែលបង្ហាញថារថក្រោះត្រូវបានបញ្ជាដោយជនពិការមកពីគ្រប់ទិសទី ។ ពួកគេបានដុតបំផ្លាញផ្ទះនៅភូមិភាគបូព៌ា ។ ប្រធានចៅក្រមបានសួរថាតើសាក្សីអាចធ្វើការបញ្ជាក់ថា ព័ត៌មានដែលត្រូវបានរំឭកក្នុងសារទូរលេខពិតជាកើតឡើងមែនដែរឬទេ ។ សាក្សីបាននិយាយថា វាពិតជាបានកើតឡើងពិតមែន ។

បន្ទាប់មក លោកប្រធានចៅក្រម និល ណុន បានសាកសួរពីការវាយប្រហារមួយទៀតដែលប្រជាជនត្រូវបានចាប់ខ្លួនយកមកធ្វើបាប ហើយគ្រាប់រំសេវត្រូវបានរឹបអូសដោយ «ខ្មាំង» ។ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៧៧ ។ ភួង ធ្វើការនៅផ្នែកចម្ការកៅស៊ូ ហើយគាត់មិននៅក្នុងជួរកងទ័ពទេ ។ យោងតាមឯកសារមុនដែលបង្ហាញថា ការវាយប្រហារក្នុងតំបន់លេខ២១ ត្រូវបានរំពឹងថា នឹងកើតមានឡើង ដូច្នេះលោកប្រធានបានធ្វើការចង្អុលបង្ហាញអំពីសារទូរលេខផ្សេងទៀត ហើយបានសួរសាក្សីថា លោកបានដឹងពីស្ថានភាពនោះដែរឬទេ ។

សាក្សីបាននិយាយថា លោកនៅចាំពីរបាយការណ៍នេះ ហើយវាជារបាយការណ៍ក្នុងភូមិភាគ ។ ទោះជាយ៉ាងនេះក្តី សាក្សីមិនបានឃើញពីព្រឹត្តិការណ៍ផ្ទាល់ភ្នែកនោះឡើយ ដោយសារតែវាបានកើតឡើងក្នុងរយៈចម្ងាយប្រហែលជា៣០គីឡូម៉ែត្រពីលោក ។

បន្ទាប់មក ប្រធានចៅក្រមបានសួរពីទំហំនៃការបំផ្លិចបំផ្លាញក្នុងការប្រយុទ្ធជាមួយវៀតណាម ។ សាក្សីបានតបថា បើតាមបទពិសោធន៍របស់លោកក្នុងទ័ពស្រួចលេខ១៥៦ មានចំនួនអ្នករបួសនិងស្លាប់ជាច្រើន ពួកគេមិនអាចនិយាយពីចំនួនអ្នករបួស និងស្លាប់ផ្សេងទៀតទេ ។ សាក្សីបាននិយាយថា ពួកគេមិនបានបាត់បង់ទ្រព្យសម្បត្តិអ្វីឡើយ ប៉ុន្តែខាងវៀតណាមបានបាត់បង់ ។ ពួកយើងបានកម្ទេចរថក្រោះប៉ុន្មានគ្រឿង ។ ពួកយើងបានទទួលព័ត៌មានតាមរយៈការទាក់ទងតាមវិទ្យុ ។ ពួកគេបានប្រើ ព-១០៥ និងព-១៣០ ។

សាក្សីបាននិយាយថា ពួកយើងមានចំនួនអ្នករបួស និងស្លាប់ជាច្រើន ចំណែកឯខាងវៀតណាមក៏ដូចគ្នា ។

**លីអូនី គីវេស្តី**

# អង្គជំនុំជម្រះតុលាការកំពូលតម្កល់ការផ្តន្ទាទោសឱ្យជាប់ឃុំមួយជីវិត និងបដិសេធលើការដាក់ពិរុទ្ធភាពដោយផ្នែក

នាព្រឹកថ្ងៃច័ន្ទ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានប្រកាសសាលដីកាលើសំណុំរឿង០០២ ដំណាក់កាលទី១ ដែលមានវត្តមានរបស់ ខៀវ សំផន និង នួន ជា ក្នុងអង្គសវនាការ ។ អង្គជំនុំជម្រះតុលាការកំពូលប្រកាសតម្កល់ការផ្តន្ទាទោសឲ្យជាប់ឃុំមួយជីវិតលើជនជាប់ចោទទាំងពីររូប ដែលត្រូវបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែតុលាការបានធ្វើការឆ្លើយតបជាវិជ្ជមានលើបណ្តឹងសារទុក្ខរបស់មេធាវីការពារក្តី ហើយបដិសេធចោលលើការដាក់ពិរុទ្ធភាពលើជនជាប់ចោទទាំងពីររូប ។

ការប្រកាសសាលដីកានេះបានទាក់ទាញឲ្យមានអ្នកចូលរួមទស្សនាយ៉ាងច្រើនកុះករ ។ អ្នកការទូត, អ្នកតំណាងឲ្យរាជរដ្ឋាភិបាល, អ្នកកាសែត, ព្រះសង្ឃ, យាយជី និងសាធារណជនជាច្រើនបានចូលទស្សនាក្នុងបន្ទប់សវនាការ ។ ក្នុងបន្ទប់សារព័ត៌មានមានអ្នកតំណាងពីស្ថានីយ៍ទូរទស្សន៍ វិទ្យុ កាសែតជាតិ និងអន្តរជាតិ ។ បរិយាកាសពោរពេញទៅដោយភាពរំភើប ខណៈពេលសាលក្រមជិតត្រូវបានប្រកាស ។

ម៉ោង ៨:៥៥នាទី ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលបានប្រកាសបទបញ្ជាផ្ទៃក្នុងនៃការហាមឃាត់ និងបទបញ្ជាទាក់ទងនឹងការចូលរួមក្នុងសាលសវនាការ ដែលមានដូចជា បម្រាមមិនឲ្យស្រែកកងរំពង សើច និងការណែនាំឲ្យស្លៀកពាក់សមរម្យជាដើម ។

នាម៉ោង ៩:០៦នាទី ចៅក្រមបានចូលក្នុងបន្ទប់សវនាការ ។ ប្រធាននៃអង្គជំនុំជម្រះតុលាការកំពូល អមដោយចៅក្រម *Agnieszka Klonowecka-Milart* និង ម៉ុង មុន្នីចរិយា បានជម្រាបគ្រប់ភាគីថា សាលក្រមនឹងត្រូវប្រកាស ។ គ្រប់ភាគី រួមទាំងជនជាប់ចោទទាំង២ មានវត្តមាន ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំង១០ មានវត្តមានក្នុងតុលាការរួមមាន៖ លោកស្រីសុត នី, លោកស្រី ស៊ូ សុធាវី, លោក ឆាវ នី, លោកស្រី គីម ហួន, លោកស្រី សុផាន សូវ៉ានី, លោកស្រី យឹម សុវណ្ណ, លោកស្រី នាង សាខន, លោកស្រី គីង



រូបភា[illegible] ជនជាប់ចោទ នួន ជា និង ខៀវ សំផន កំពុងស្តាប់សាលក្រមស្ថាពរដែលប្រកាសដោយអង្គជំនុំជម្រះតុលាការកំពូលកាត់ទោសឲ្យជាប់គុកអស់មួយជីវិត កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧

*សុខា, លោកស្រី សេង ស៊ីវុធថា និង លោក យឹម រំដួល ។*

***បញ្ហាបឋម***

*នាថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រម និងរកឃើញថា ជនជាប់ចោទទាំងពីរមានពិរុទ្ធភាពលើបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានដូចជា ការសម្លាប់រង្គាល (រួមបញ្ចូលទាំងការធ្វើមនុស្សឃាត), ការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ, អំពើអមនុស្សធម៌ផ្សេងៗទៀតក្នុងរូបភាពនៃការជម្លៀសដោយបង្ខំ, ការបាត់ខ្លួនដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិក្នុងអំឡុងពេលព្រឹត្តិការណ៍បីដូចជា ៖ ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ (ដែលជាការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញភ្លាមៗនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥) ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ (ដែលជាប់ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៧) និងហេតុការណ៍ដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ ។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ជនជាប់ចោទទាំងពីរត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌលើបទឧក្រិដ្ឋទាំងនេះដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវដែលហៅថា សហឧក្រិដ្ឋរួម ព្រមទាំងដោយសារជនជាប់ចោទបានរៀបចំផែនការ, ញុះញង់, ជួយ និងជំរុញ (និងចំពោះជនជាប់ចោទ នួន ជា តែម្នាក់ទាក់ទងនឹងការបញ្ជានៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ) ។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចផ្តន្ទាទោសជនជាប់ចោទទាំងពីរឲ្យជាប់ទោសមួយជីវិត និងប្រកាសបន្ទាប់ឲ្យផ្តល់សំណងសមូហភាពតាមសេចក្តីស្នើចំនួន ១១ករណី ។ មេធាវីការពារក្តីក៏ដូចជាសហព្រះរាជអាជ្ញាបានដាក់សារណាបណ្តឹងសារទុក្ខជំទាស់លើការសម្រេចចិត្ត ។ មេធាវីការពារក្តីឲ្យ នួន ជា មានមូលដ្ឋានជំទាស់ចំនួន២២៣ នៃបណ្តឹងសារទុក្ខ ចំណែកឯមេធាវីការពារក្តីឲ្យ ខៀវ សំផន មានមូលដ្ឋានជំទាស់ចំនួន ១៤៨ ។ លោកប្រធានបានប្រកាសថា បណ្តឹងសារទុក្ខទាំងពីរនឹងត្រូវពិចារណារួមគ្នាដោយសារតែមានភាពត្រួតគ្នាជាច្រើន ។ ចំពោះបណ្តឹងសារទុក្ខរបស់សហព្រះរាជអាជ្ញា និងត្រូវសន្ទេបដាច់ដោយឡែក ។*

***ការពិចារណាលើបណ្តឹងសារទុក្ខរបស់មេធាវីការពារក្តី នួន ជា និង ខៀវ សំផន***

*លោក គង់ ស្រ៊ីម ប្រធានអង្គជំនុំជម្រះតុលាការកំពូលបានបង្ហាញថា ប៉ុន្មានចំណុចទាំងនេះដែលជាចំណុចដ៏ចម្រូងចម្រាស់ ហើយក៏ជាចំណាប់អារម្មណ៍របស់សាធារណជនផងដែរ និងត្រូវបានសន្ទេបនាថ្ងៃនេះ និងបែងចែកជាប្រាំផ្នែកធំៗ ៖ ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី, វិធីសាស្រ្តទទួលយកភស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូង, ការរកឃើញពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋដែលជនជាប់ចោទបានប្រព្រឹត្ត, ការទទួលខុសត្រូវលើឧក្រិដ្ឋកម្មដោយបុគ្គល និងការកាត់ទោស ។*

***១) ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី***

*ត្រង់ចំណុចកណ្តាលនៃសារណាបណ្តឹងសារទុក្ខរបស់មេធាវីការពារក្តីគឺជាអំណះអំណាងគ្មានភស្តុតាងដែលថា សិទ្ធិក្នុងការតវ៉ារបស់ជនជាប់ចោទទៅលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្នុងតុលាការឯករាជ្យឥតលម្អៀងត្រូវបានរំលោភបំពាន ។ ចំណុចនេះ ត្រូវបានសរុបសេចក្តីក្នុងផ្នែកនៃសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានអង្គជំនុំជម្រះឯករាជ្យឥតលម្អៀង និងសិទ្ធិក្នុងការទទួលបានការការពារប្រកបដោយប្រសិទ្ធិភាព ។*

***សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្នុងតុលាការឯករាជ្យឥតលម្អៀង***

*ជនជាប់ចោទបានចោទប្រកាន់ថា សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្នុងតុលាការឯករាជ្យឥតលម្អៀងរបស់ពួកគេ ត្រូវបានរំលោភបំពាន ។ លោកចៅក្រម គង់ ស្រ៊ីម បានប្រកាសថា អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញការរកឃើញដោយភាពភាន់ច្រឡំ និងភាពពុំសមហេតុផលឡើយ ។ មតិដែលត្រូវបានបញ្ចេញដោយលោកស្រីចៅក្រម ខាតរ៉ៃយ៍ (Cartwright) ឬការស៊ើបអង្កេតរបស់លោកចៅ ក្រម ម៉ាសែល ឡឺម៉ុង (Marcel Lemonde) ពុំបានធ្វើឲ្យអង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងមានកង្វះខាតឯករាជភាពនោះទេ ។*

*បន្ទាប់មកលោកចៅក្រមបានក្រឡេកមកបញ្ហាដែលមានជាយូរមកហើយ និងបញ្ហាដែលត្រូវបានពិភាក្សា មានដូចជា ការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកោះហៅសាក្សី*

*ហេង សំរិន ។ មេធាវីការពារក្តីឲ្យ នួន ជា បានស្នើសុំម្តងហើយម្តងទៀតឲ្យមានការកោះហៅបុគ្គលនយោបាយដ៏សំខាន់មួយរូបនេះ ។ ថេត សម្បត្តិ (ជាអ្នកនិពន្ធ និងអ្នកផលិតភាពយន្ត) បានចោទប្រកាន់ថា សាក្សីជាក់ស្តែងមួយចំនួនមិនត្រូវបានកោះហៅដោយសារបញ្ហាសន្តិសុខ ។ លោកបានបន្តថា អង្គជំនុំជម្រះសាលាដំបូងបានចាត់ថា "ជាការចោទប្រកាន់ដោយគ្មានភស្តុតាងមានទម្ងន់" ប៉ុន្តែបានចាត់ទុកថា "មិនជាប់ពាក់ព័ន្ធនឹងសំណួរដែលចោទថាតើតុលាការមានកង្វះឯករាជភាពបុយ៉ាងណាទេ" ។ ក្នុងន័យដូចគ្នានេះ អង្គជំនុំជម្រះតុលាការកំពូល បាននិយាយថា វាពុំមានភាពច្បាស់ទេដែលថាជា (ការកង្វះឯករាជភាព) ហើយនេះជាសេចក្តីសន្និដ្ឋានតែប៉ុណ្ណោះនៅក្នុងការខកខានដើម្បីកោះហៅសាក្សី ហេង សំរិន ។*

***សិទ្ធិក្នុងការទទួលបានការគាំពារ ការការពារប្រកបដោយប្រសិទ្ធភាព***

*ការបដិសេធក្នុងការកោះហៅសាក្សី ហេង សំរិន ក៏ជាប់ពាក់ព័ន្ធជាមួយនឹងមូលដ្ឋានជំទាស់ដែលមានអំណះអំណាងថា សិទ្ធិក្នុងការទទួលបានការគាំពារ ការការពារប្រកបដោយប្រសិទ្ធភាពត្រូវបានចោទសួរ ។ ចៅក្រមបីនាក់ក្នុងចៅក្រមប្រាំនាក់របស់អង្គជំនុំជម្រះសាលាដំបូងបានអះអាងថា ការកោះហៅសាក្សី ហេង សំរិន អាចធ្វើឲ្យមានការពន្យារពេលយ៉ាងច្រើនដូច្នេះសាក្សីរូបនេះពុំគប្បីកោះហៅឡើយ ។ អង្គជំនុំជម្រះសាលាកំពូលបានចាត់ទុកថាការបដិសេធក្នុងការកោះហៅនេះ គឺមិនមានហេតុផល ដោយសារតែគ្មានការចង្អុលបង្ហាញនៃបាយការណ៍ណាដែលថា សាក្សី ហេង សំរិន និងមិនបង្ហាញវត្តមានទេ ប្រសិនបើលោកត្រូវបានតុលាការកោះហៅ ។ លើសពីនេះទៅទៀត សាក្សីបានធ្វើការស្នើសុំតាំងពីវគ្គដំបូងក្នុងដំណើរការអង្គសវនាការមកម្ល៉េះ ។ អង្គជំនុំជម្រះតុលាការកំពូលបានឈានដល់សេចក្តីសន្និដ្ឋានពាក់ព័ន្ធជាមួយសាក្សី អ៊ុក ប៊ុនឈឿន ។ យ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលបានចាត់ទុកថា តុលាការមិនបានធ្វើបុរេវិនិច្ឆ័យលើជនជាប់ចោទ ដោយសារតែសាក្សីទាំងពីរមិនបានបង្ហាញអង្គហេតុ ឬភស្តុតាងដែលអាចឲ្យជនជាប់ចោទទាំងពីររូបរួចពីការចោទប្រកាន់ដែលសាក្សីផ្សេងទៀតមិនបានផ្តល់ក្នុងសក្ខីកម្មឡើយ ។ ហេតុដូចនេះ ពុំមានកសេចក្តីសម្រេចមិនសមហេតុផលក្នុងការមិនកោះហៅសាក្សីទាំងពីររូបនេះ ដែលអាចបណ្តាលឲ្យមានលទ្ធផលខុសឆ្គងធ្ងន់នៅក្នុងកិច្ចដំណើរការនីតិវិធីដែលតម្រូវឲ្យមានការបដិសេធលើការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទឡើយ ។*

*អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបដិសេធអំណះអំណាងរបស់មេធាវីការពារក្តីដែលថា បទបញ្ញត្តិផ្ទៃក្នុងមានភាពផ្ទុយពីរដ្ឋធម្មនុញ្ញដោយមានសម្អាងហេតុលើភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី (មើលសាលដីកាពេញលេញ) ។*

***២) វិធីសាស្ត្រទទួលយកភស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូង***

*មេធាវីការពារក្តីរបស់ជនជាប់ចោទទាំងពីររូបបានចោទសួរពីសុពលភាពនៃវិធីសាស្ត្រទទួលយកភស្តុតាងរបស់សាលាដំបូង ។ មូលដ្ឋានជំទាស់នៃសារណាបណ្តឹងសាទុក្ខរបស់ពួកគេត្រូវបានបែងចែកជា៤ក្រុមធំៗ ។*

***ការកំណត់ការស៊ើបអង្កេតនៅអង្គសវនាការ***

*ដោយសារតែអង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា ជនជាប់ចោទមិនមានសិទ្ធិក្នុងការស៊ើបអង្កេត ជនជាប់ចោទបានអះអាងថាពួកគេត្រូវបានរឹតត្បិតជ្រុលហួសហេតុក្នុងការស៊ើបអង្កេតក្នុងតុលាការ ។ អង្គជំនុំជម្រះតុលាការកំពូលបានថ្លែងថា បើទោះជាការស៊ើបអង្កេតពេញលេញមិនត្រូវបានគ្រោងទុក ក៏គ្មានហេតុផលរឹតត្បិតមេធាវីការពារក្តីមិនឲ្យធ្វើការស៊ើបអង្កេតដោយខ្លួនឯងនោះឡើយ ។ ជាធម្មតា តុលាការអនុញ្ញាតឲ្យមេធាវីការពារក្តីឲ្យធ្វើការស្នើសុំ ។ មានការអះអាងថា អង្គជំនុំជម្រះតុលាការកំពូលមិនបានរកឃើញភាពមិនសមហេតុផលក្នុងការច្រានចោលការស្នើសុំដើម្បីស៊ើបអង្កេតឡើយ ។*

***ការអនុញ្ញាតសាក្សីឲ្យពិនិត្យឡើងវិញមុនពេលធ្វើសេចក្តីថ្លែងការណ៍ និងធ្វើការបញ្ជាក់អំពីខ្លឹមសាររបស់អត្ថបទទាំងនោះ***

*ទាក់ទិននឹងអំណះអំណាងដែលអនុញ្ញាតឲ្យសាក្សីពិនិត្យឡើងវិញ មុនពេលធ្វើសេចក្តីថ្លែងការណ៍ អង្គជំនុំជម្រះតុលាការកំពូលបានមានប្រសាសន៍ថា "វាប្រហែលជាមានភាពស៊ីសង្វាក់គ្នាជាមួយការអនុវត្តរបស់ជនជាតិកម្ពុជាដែលមិនអនុលោមនីតិវិធីនេះ ។ ប៉ុន្តែវាមិនត្រូវបានរកឃើញថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភឆន្ទានុសិទ្ធិរបស់ខ្លួនឡើយពាក់ព័ន្ធនឹងរឿងនេះ" ។*

### ការទទួលយកសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរជំនួសឲ្យសេចក្តីថ្លែងការណ៍ផ្ទាល់មាត់

លោកប្រធាន គង់ ស្រ៊ីម បានបង្ហាញថា សិទ្ធិក្នុងការប្រឈមមុខជាមួយសាក្សីគឺមិនមានភាពដាច់ខាតឡើយ ។ សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរគឺអាចទទួលយកបាន បើទោះជាមេធាវីការពារក្តីមិនអាចស៊ើបអង្កេតក៏ដោយ ។ សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ និង ប្រតិចារឹក ចំនួន ១.១២៤ ច្បាប់ ត្រូវបានទទួលស្គាល់ ។ អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា ពួកគេបានប្រកាន់យកគោលការណ៍ក្នុងការដាក់បន្ទុកទម្ងន់ស្រាលទៅក្នុងការពិចារណា ។ ដូច្នេះ វាមិនត្រូវបានចាត់ទុកជាមូលដ្ឋានជំទាស់ស្របច្បាប់នៃបណ្តឹងសារទុក្ខនោះទេ ។

### ការពឹងផ្អែកលើភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណី

អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា វិធីសាស្រ្តទទួលយកភស្តុតាងរបស់សាលាដំបូងគឺមានភាពខុសឆ្គងបើផ្អែកទៅលើសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តល់សក្ខីកម្ម ហើយក៏មានការបន្ថែមបន្ទុកលើសេចក្តីថ្លែងការណ៍របស់ពួកគេក្នុងមួយសំណុំរឿងម្តងៗ ។ដូច្នេះ សាលក្រមអាចមានការប៉ះពាល់ ។

### ៣) ការរកឃើញពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែលជនជាប់ចោទបានប្រព្រឹត្ត

អង្គជំនុំជម្រះតុលាការកំពូល បានបែងចែកការទទួលខុសត្រូវផ្អែកព្រហ្មទណ្ឌជាពីរផ្នែកធំៗ ៖ ទីមួយជនដែលប្រព្រឹត្តអំពើឧក្រិដ្ឋកម្មផ្ទាល់ និង ទីពីរជនដែលមានជាប់ពាក់ព័ន្ធនឹងការទទួលខុសក្នុងអំពើទាំងនោះ ។ បន្ទាប់មក លោកចៅក្រមបានធ្វើការវិនិច្ឆ័យលើអំពើឧក្រិដ្ឋក្នុងផ្នែកនីមួយៗ ។

### បទមនុស្សឃាត

អង្គជំនុំជម្រះសាលាដំបូងបានកំណត់ធាតុផ្សំអត្តនោម័តិនៃការសម្លាប់ដែលរួមមានចេតនាផ្ទាល់ និងចេតនាប្រយោល ។ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសឆ្គងឡើយ ដោយសារតែការធ្វេសប្រហែសក្នុងការរួមបញ្ចូលទម្រង់នៃបំណងឧក្រិដ្ឋឲ្យហួសពីវិមតិសង្ស័យ ។ ដូចអង្គហេតុដែលបានរកឃើញ ដែលសម្អាងហេតុមនុស្សឃាតបានកើតមាន ។ អង្គជំនុំជម្រះបានរកឃើញថាដោយសារតែគ្មានការរកឃើញនៃអំពើមនុស្សឃាត ប៉ុន្តែចំនួនប្រជាជនជាច្រើនត្រូវបានជម្លៀសចេញពីភ្នំពេញ និងនៅទួលពោធិ៍ជ្រៃ ។ ដូច្នេះ នេះអាចចាត់ទុកថាអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានកើតមានឡើង ។

### បទសម្លាប់រង្គាល

ផ្ទុយពីនិយមន័យនៃការសម្លាប់ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលតម្រូវឲ្យមានចេតនាប្រយោលក្នុងធាតុផ្សំអត្តនោម័តិ ។ ក្នុងការប្រព្រឹត្តការសម្លាប់រង្គាល ចេតនាផ្ទាល់ត្រូវតែមាន ។ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមានភាពមិនត្រឹមត្រូវដោយផ្នែក ។ អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធទឡ្ហីករណ៍របស់ជនជាប់ចោទដែលថា ពុំមានការបង្ហាញថាក្នុងអំឡុងពេលជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញចំនួននៃការស្លាប់លើសពីអត្រាកំណត់មរណភាពធម្មតាឡើយ ។ ទោះបីជាយ៉ាងនេះក្តី យោងតាមអង្គជំនុំជម្រះតុលាការកំពូល វាជាការពុំសមហេតុផលក្នុងការសន្និដ្ឋានថាធាតុផ្សំសត្យានុម័តិអំពីទំហំធំនៃការសម្លាប់រង្គាលត្រូវបានបង្ហាញថាមានអត្ថិភាពទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនចេញពីក្រុងភ្នំពេញឡើយ ដោយសារមានតែការស្លាប់មួយចំនួនតូចប៉ុណ្ណោះដែលអាចចាត់ទុកថាត្រូវបានបង្ហាញថាហួសពីវិមតិសង្ស័យ ។ ដូចនេះ ពុំមានភស្តុតាងក្នុងការបង្កើតឲ្យមានការសម្លាប់រង្គាលទ្រង់ទ្រាយធំក្នុងអំឡុងពេលជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញឡើយ ។ អង្គជំនុំជម្រះតុលាការកំពូលក៏មិនអាចបង្ហាញពីអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងបទសម្លាប់រង្គាលក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅរបស់ប្រជាជនក្នុងដំណាក់កាលទី២ដែរ ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងត្រង់ចំណុចនេះ ។

ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញភស្តុតាងគ្រប់គ្រាន់ក្នុងបទសម្លាប់ ហើយជនជាប់ចោទត្រូវបានផ្តន្ទាទោសដោយផ្អែកលើមូលដ្ឋាននេះ ។

ទាក់ទងនឹងហេតុការណ៍នៅទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសថាពួកគេមិនយល់ស្របនឹងទឡ្ហីករណ៍របស់ជនជាប់ចោទ ដែលបានបង្ហាញថាមានទាហានយ៉ាងហោចណាស់ ២៥០ នាក់ត្រូវបានសម្លាប់ ។ ពុំមានវិមតិសង្ស័យដែលថា

ជនជាប់ចោទបានប្រព្រឹត្តដោយចេតនាផ្ទាល់ ក្នុងការសម្លាប់ក្នុងទ្រង់ទ្រាយធំដូច្នេះជារួមការសម្លាប់រង្គាលគឺបានកើតមាន ។

## អំពើអមនុស្សធម៌ផ្សេងៗទៀត

អង្គជំនុំជម្រះសាលាដំបូងបានកំណត់ធាតុផ្សំនៃការផ្លាស់ទីលំនៅដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ ។ ប្រសិនបើបទឧក្រិដ្ឋទាំងពីរនេះត្រូវបានបែងចែកដាច់ដោយឡែកពីគ្នា ករណីទាំងពីរនេះគួរតែមានធាតុផ្សំប្រហែលគ្នាដើម្បីកំណត់អំពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ។ ករណីទាំងនេះចាំបាច់ត្រូវតែមានការវិភាគម្តងមួយ ។ លោកចៅក្រម ស្រ៊ឹម បានថ្លែងថា ការរកឃើញពីស្ថានភាពក្នុងអំឡុងពេលជម្លៀសប្រជាជនចេញដំណាក់កាលទី១ ដោយអង្គជំនុំជម្រះសាលាដំបូង ជារួមមានភាពសមហេតុផល ប៉ុន្តែមានផ្នែកខ្លះពុំមានភាពសមហេតុផលឡើយ ។ ជនជាប់ចោទបានបង្ហាញពីការបកស្រាយដ៏តិចតួចនៃព្រឹត្តិការណ៍នោះ ហើយមានការបង្ហាញភាពពុំសមហេតុផលមិនគ្រប់គ្រាន់ដោយអង្គជំនុំជម្រះសាលាដំបូង ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធមូលដ្ឋានជំទាស់នៃបណ្តឹងសារទុក្ខនេះ ។

ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដំណាក់កាលទី២ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា ការរកឃើញជាក់ស្តែងរបស់អង្គជំនុំជម្រះសាលាដំបូង គឺពុំមានភាពសមហេតុផល ដោយសារតែពួកគេពឹងផ្អែកលើសម្អាងភ័ស្តុតាង ប៉ុន្តែជារួមដោយសារតែកត្តាកង្វះស្បៀង កង្វះអនាម័យ និងកង្វះខាតក្នុងការទទួលបានថ្នាំនិងជំនួយផ្នែកវេជ្ជសាស្ត្របានកើតមាន ។ លើសពីនេះទៅទៀតមានភ័ស្តុតាងគ្រប់គ្រាន់ដែលថា ប្រជាជនខ្លះបានបាត់ខ្លួន ហើយខ្លះទៀតបានស្លាប់ដោយសារតែលក្ខខណ្ឌនៃការជម្លៀសនេះ ។ ទោះជាយ៉ាងនេះក្តី ពុំមានភាពសមហេតុផលដែលក្នុងការរកឃើញថាចំនួនដ៏ច្រើនលើសលប់នៃប្រជាជនក្នុងដំណាក់កាលទី២ គឺជាប្រជាជនថ្មី ដោយសារតែប្រជាជនមូលដ្ឋានក៏ត្រូវបានជម្លៀសដែរ ។

អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា លក្ខខណ្ឌនៃការជម្លៀសប្រជាជនដំណាក់កាលទី១ និងដំណាក់កាលទី២មានតម្លៃស្មើនឹងអំពើអមនុស្សធម៌ផ្សេងៗនៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ។ លក្ខខណ្ឌទាំងនេះរួមមានកត្តាផ្សេងៗទៀត បានធ្វើឲ្យមានទស្សនៈធ្ងន់ផ្នែកផ្លូវចិត្ត ដែលមានដូចជា ការព្រាត់ប្រាស់ពីគ្រួសារ លក្ខខណ្ឌមិនសមរម្យពាក់ព័ន្ធនឹងកត្តាស្បៀងអាហារ និងកត្តាសុខភាព ។

## ការធ្វើទុក្ខបុកម្នេញ

អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការកំណត់និយមន័យនៃការធ្វើទុក្ខបុកម្នេញឡើយ ។ តុលាការបានប្រកាសថា ក្រុមប្រជាជនថ្មី បានយល់ដឹងគ្រប់គ្រាន់ និងបានបដិសេធលើទឡ្ហីករណ៍របស់ជនជាប់ចោទដែលថា ប្រជាជនថ្មីពុំបានកំណត់ថាជាគោលដៅ ព្រោះអត្តសញ្ញាណរបស់ពួកគេក្នុងពេលផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទី១មិនអាចកំណត់បាន ។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងក្នុងការរកឃើញថា ការធ្វើទុក្ខបុកម្នេញបានកើតមានក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនដំណាក់កាលទី២ ដោយសារតែទាំងប្រជាជនថ្មីនិងប្រជាជនចាស់ត្រូវបានជម្លៀស ។

អង្គជំនុំជម្រះតុលាការកំពូលបានច្រានចោលមូលដ្ឋានជំទាស់ទាក់ទិននឹងធាតុផ្សំក្នុងបរិបទនៃបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ។ (មើលសាលដីកាពេញលេញ)

## ៤) ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល

បន្ទាប់ពីបានច្រានចោលផ្នែកខ្លះ និងបានអះអាងផ្នែកខ្លះការលេចឡើងនៃឧក្រិដ្ឋកម្ម លោកប្រធានបានក្រឡេកមក ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ហើយឆ្លើយតបនឹងសំណួរដែលថា ជនជាប់ចោទគួរតែត្រូវផ្តន្ទាទោសតាមបទឧក្រិដ្ឋប្កយ៉ាងណា ។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ជនជាប់ចោទមានការទទួលខុសត្រូវតាមរយៈបទសហឧក្រិដ្ឋកម្មរួមទម្រង់មួយ ព្រមទាំងតាមរយៈការជួយជំរុញ និងការញុះញង់ ហើយក្នុងករណី នួន ជា តែម្នាក់នឹងផ្អែកទៅលើការទទួលខុសត្រូវថ្នាក់លើ ។

## បទសហឧក្រិដ្ឋរួម

អង្គជំនុំជម្រះតុលាការកំពូលពុំបានជឿជាក់ថា បទសហឧក្រិដ្ឋរួមមិនបានកើតឡើងព្រោះវាជាការទទួលខុសត្រូវនាពេលនោះឡើយ ។ ដោយសារតែសេចក្តីថែងរបស់តុលាការ ICTY ដែលបញ្ជាក់ថា សញ្ញាណមូលដ្ឋាននេះបានកើតឡើងរួចទៅហើយក្រោយសង្គ្រាមលោកលើកទី២ ។ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិគោលបំណងរួមគឺអាចកំណត់អត្តសញ្ញាណឧក្រិដ្ឋភាពបាន ។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងបានមើលឃើញថា

បទឧក្រិដ្ឋ គឺជាលទ្ធផលនៃគោលបំណងរួម បើទោះជាពួកគេមិនមែនជាផ្នែកមួយនៃផែនការក៏ដោយ ក៏ពួកគេត្រូវបានសរុបសេចក្តីក្រោមច្បាប់នៃតុលាការ សហឧក្រិដ្ឋកម្មរួមទម្រង់មួយ ។ អង្គជំនុំជម្រះតុលាការកំពូលបានច្រានចោលការកំណត់និយមន័យនេះ ហើយកំណត់ថា វាជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួមទម្រង់ពីរ ។ លោកប្រធានបានមានប្រសាសន៍ថា ដោយសារតែគ្មានមូលដ្ឋាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិរបស់សហឧក្រិដ្ឋកម្មរួមទម្រង់ពីរនាពេលនោះ ហេតុដូច្នេះទើបយើងមិនអាចប្រកាន់យកនិយមន័យកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងបាន ។ អង្គជំនុំជម្រះសាលាដំបូងមានធ្វើឲ្យមានកំហុសឆ្គងផ្នែកច្បាប់ ។

ដូច្នេះ វាចាំបាច់ត្រូវតែចូលទៅជិតវត្ថុបំណងចម្បងនៃគោលបំណងរួម ដែលមានការជាប់ពាក់ព័ន្ធជាមួយការប្រព្រឹត្តបទឧក្រិដ្ឋ និងជាសំណួរចម្បងដែលទាក់ទិននឹងផ្នែកអង្គហេតុមិនមែនផ្នែកច្បាប់ ។ គោលបំណងរួមតម្រូវឲ្យមានសភាពជាភាពឧក្រិដ្ឋ ។ លោកប្រធានបាននិយាយថា ការអនុវត្តបដិវត្តន៍សង្គមនិយមដ៏ឆាប់មួយគឺមិនមែនជាភាពឧក្រិដ្ឋនោះទេ ។ ទោះជាយ៉ាងនេះក្តី វាត្រូវបានឃើញថា ក្នុងបរិបទនៃគោលនយោបាយក្នុងការជម្លៀសប្រជាជន និងនយោបាយក្នុងការកំណត់មុខសញ្ញាទាហាន លន់ នល់ ។ អង្គជំនុំជម្រះសាលាដំបូង ហាក់ដូចជាមានកង្វះខាតក្នុងភាពជាក់លាក់ ប៉ុន្តែគោលបំណងភាពឧក្រិដ្ឋគឺនៅតែមាន ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបានច្រានចោលទឡ្ហីករណ៍នៃគោលបំណងមិនមានភាពឧក្រិដ្ឋ ។

អង្គជំនុំជម្រះតុលាការកំពូល មិនបានរកឃើញកំហុសឆ្គងពាក់ព័ន្ធនឹងការបង្កើត និងខ្លឹមសារនៃគោលនយោបាយនៃការផ្លាស់ទីប្រជាជនឡើយ ។ មានភាពប្រទាក់ក្រឡាគ្នានៃការជម្លៀសប្រជាជន ហើយអង្គជំនុំជម្រះសាលាដំបូងមិនបានរកឃើញថា គ្រប់ការជម្លៀសបានធ្វើតាមវិធីសាស្ត្រនៃការជម្លៀសដូចគ្នានោះទេ ។

ដោយសារតែបទឧក្រិដ្ឋស្ថិតក្នុងដែនវិសាលនៃគោលដៅនៃការជម្លៀសប្រជាជនដំណាក់កាលទីមួយ និងដំណាក់កាលទីពីរ លោកប្រធានបានប្រកាសថា សេចក្តីសង្ខេប និងលើកឡើងតែបទឧក្រិដ្ឋមនុស្សឃាតតែប៉ុណ្ណោះ ពីព្រោះវាជាបញ្ហាដ៏ចម្រូងចម្រាសបំផុត ។ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា គោលបំណងរួមស្ថិតក្នុងដែនវិសាលនៃការសម្លាប់អតីតអ្នករដ្ឋការថ្នាក់ជាន់ខ្ពស់ និងអតីតទាហាន ។ លើសពីនេះទៅទៀត ដោយសារតែប្រជាជនងាយរងគ្រោះបំផុតបានស្លាប់ ហើយប្រជាជនក្នុងទីក្រុងទាំងស្រុងត្រូវបានបង្ខំឲ្យជម្លៀសចេញក្នុងអំឡុងរដូវក្តៅបំផុតប្រចាំឆ្នាំ ។ បន្ថែមពីនេះទៀត ការជម្លៀសចេញត្រូវបានធ្វើឡើងក្នុងរយៈពេលដ៏ខ្លីមួយ ហើយត្រូវបានហែហមដោយកងកម្លាំងប្រដាប់អាវុធជាច្រើនដែរ ។ អង្គហេតុនេះសរុបដោយប្រយោលពីគោលបំណងដែលថា កងកម្លាំងប្រដាប់អាវុធអាចមានការប៉ះទង្គិចទៅលើការរើបម្រះណាមួយដែលផ្ទុយពីបទបញ្ជានៃការសម្លាប់ជាក់ស្តែងណាមួយត្រូវបានដាក់ចេញ ។ ដូចនេះ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា បទឧក្រិដ្ឋសម្លាប់ពិតជាបានកើតឡើងក្នុងផ្នែកមួយនៃគោលបំណងរួមស្ថិតក្រោមទម្រង់នៃការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញក្នុងដំណាក់កាលទី១ ។

ដោយសារតែគ្មានការចង្អុលបង្ហាញ មានគោលនយោបាយក្នុងការផ្តល់ការថែទាំគ្រប់គ្រាន់ ឬការការពារប្រជាជន ដូច្នេះការស្លាប់របស់ប្រជាជន គឺអាចកើតមានឡើង ។ ជនជាប់ចោទនៃបទសហឧក្រិដ្ឋរួមក៏នៅតែចូលរួមក្នុងការជម្លៀសដោយបង្ខំ ។

## ការកើតឡើង និងខ្លឹមសារនៃគោលនយោបាយកំណត់មុខសញ្ញា

លើសពីនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងបានរកឃើញពីគោលនយោបាយសម្លាប់អ្នករដ្ឋការ លន់ នល់ នៅឯទួលពោធិ៍ជ្រៃ ។ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញពីការសម្លាប់នៅខេត្ត មុនឆ្នាំ១៩៧៥ ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា ភស្តុតាងមានសភាពខ្សោយពេកដើម្បីអះអាងពីការរកឃើញ លើកលែងតែក្នុងសម្អាងហេតុមួយចំនួន ។ លើសពីនេះទៀត ដោយសារតែជាប់ពាក់ព័ន្ធជាមួយការប៉ុនប៉ងសម្លាប់ ឬមិនមានភាពស៊ីសង្វាក់នៃសេចក្តីថ្លែងការណ៍របស់តុលាការដែលគ្មានការបញ្ជាក់ ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលមិនមានការពេញចិត្តនឹងការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង និងការចាត់ទុកភស្តុតាងថាពុំមានហេតុផលគ្រប់គ្រាន់ដែលថា មានគោលនយោបាយដើម្បីសម្លាប់ទាហាន លន់ នល់ ទាំងអស់មុន និងក្រោយព្រឹត្តិការណ៍ទួលពោធិ៍ជ្រៃ ។

ដោយសារតែវិសាលភាពនៃសំណុំ០០២ដំណាក់កាលទី១ ត្រូវបានរឹតត្បិត និងភ័ស្តុតាងមួយផ្នែកធំ មិនមានការជាប់ពាក់ព័ន្ធ និងដោយសារតែអង្គជំនុំជម្រះសាលាដំបូងមិនអាចបង្ហាញថា ហេតុអ្វីបានជាការណែនាំត្រូវបានអនុវត្ត ក្នុងឆ្នាំ១៩៧៦ ប៉ុន្តែគោលនយោបាយបានកើតមានឡើងក្នុងខែមេសា ឆ្នាំ១៩៧៥ យ៉ាងដូច្នេះ ។

ដូចនេះ អង្គជំនុំជម្រះតុលាការកំពូល បានរកឃើញថា វាពុំមានភាពសមហេតុផលដែលថា គោលនយោបាយពាក់ព័ន្ធ និងទាហាន និងអ្នករដ្ឋការ លន់ នល់ ដែលបានដាក់ចេញនាពេលព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ។ ដូច្នេះ ពាក់ព័ន្ធនឹងរឿងនេះ ជនជាប់ចោទមិនអាចទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌលើបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិបានឡើយ ។

អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសឆ្គងក្នុងការធ្វើការទទួលខុសត្រូវលើព្រឹត្តិការណ៍ប្រព្រឹត្តដោយជនជាប់ចោទដែលមិនមានភាពជាប់ពាក់ព័ន្ធ និងចក្ខុវិស័យដំបូងទៅលើបទឧក្រិដ្ឋទេ ។

**ការចូលរួមចំណែករបស់ នួន ជា និង ខៀវ សំផន ក្នុងការអនុវត្តនៃគោលបំណងរួម**

លោកប្រធានបានប្រកាសថា មូលដ្ឋានជំទាស់នៃបណ្តឹងសារទុក្ខមានអត្ថិភាពទៅលើអង្គហេតុនៃតួនាទីរបស់ជនជាប់ចោទក្នុងការរៀបចំផែនការ ហើយតួនាទីក្នុងយុទ្ធនាការឃោសនាត្រូវបានរំសាយចោល ។ មូលដ្ឋានជំទាស់ទាំងនោះបានផ្តល់ហេតុផលថា នួន ជា បានផ្តល់ការអធិប្បាយទុំបទបន្តិចបន្តួចតែប៉ុណ្ណោះ ។ ស្របពេលជាមួយគ្នានេះភ័ស្តុតាងមិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្ហាញថា នួន ជា មានការទទួលខុសត្រូវលើបទបញ្ញត្តិរបស់អង្គការដែរ ។ បើទោះជាយ៉ាងនេះក្តី ភ័ស្តុតាងនេះមិនមានការប៉ះពាល់ទៅលើសេចក្តីសន្និដ្ឋានដែលថា នួន ជា បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអនុវត្តគោលបំណងរួមនេះទេ ។

ដោយឡែកចំពោះជនជាប់ចោទ ខៀវ សំផន អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចសេចក្តីថា វាជាការពុំសមហេតុផលក្នុងការសរុបសេចក្តីថា ខៀវ សំផន បានចូលរួមការប្រជុំក្នុងឆ្នាំ១៩៧៤ ដែលបានពិភាក្សាពីការជម្លៀសប្រជាជនពីក្រុងភ្នំពេញ ។ លើសពីនេះទៀត សុន្ទរកថា ក្នុងឆ្នាំ១៩៧៦ គឺបានធ្វើលើ ខៀវ សំផន ទាំងសេចក្តីភាន់ច្រលំ ។ ទោះជាយ៉ាងនេះក្តី ការចូលរួមចំណែករបស់ ខៀវ សំផន ទាំងមូលគឺពុំមានភាពសមហេតុផល ដែលពាក់ព័ន្ធជាមួយនឹងការបូករួមសរុបនៃសកម្មភាព (ពាក់ព័ន្ធនឹងការប្រជុំផ្សេងទៀត ការចូលរួមក្នុងបញ្ហាសេដ្ឋកិច្ច សេចក្តីថ្លែងការណ៍សាធារណៈ ក្នុងការគាំទ្រគោលបំណងរួម និងការដើរតួជាអ្នកការទូតក្នុងការកៀងគរកការគាំទ្រពីក្រៅប្រទេស) ។

**ឋានានុក្រមបង្រួបបង្រួមបក្ស**

ជនជាប់ចោទបានស្នើថា បក្សកុម្មុយនីស្តកម្ពុជា គឺបានបែងចែកអំណាចជាភាគ ដូច្នេះមានន័យថា ពួកគេទាំងពីររូបមិនអាចទទួលខុសត្រូវលើសកម្មភាពទាំងអស់នេះបានទេ ។ អង្គជំនុំជម្រះតុលាការកំពូលពុំមានការជឿជាក់លើទឡ្ហីករណ៍នេះឡើយ ដោយសារតែពួកគេបានទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ នេះបើផ្អែកតាមសហឧក្រិដ្ឋកម្មរួម ។ លោកចៅក្រម បានសង្កត់ធ្ងន់ថាបើទោះបីជាមានផែនការសម្ងាត់ ក៏មិនមែនមានន័យថា បទឧក្រិដ្ឋដែលទម្លាក់ការទទួលខុសត្រូវទៅលើជនជាប់ចោទមិនអាចទម្លាក់ទោសទៅលើអ្នកផ្សំគំនិតដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមដែរ ដរាបណានៅតែមានការបង្កើតឡើងពីគោលបំណងរួមដែលបទឧក្រិដ្ឋត្រូវបានកើតមាន ។

**ចេតនាតម្រូវឲ្យមាន**

អង្គជំនុំជម្រះតុលាការកំពូលបានចង្អុលបង្ហាញថា ស្តង់ដារនៃចេតនាមិនត្រូវបានបង្ហាញក្នុងបទសហឧក្រិដ្ឋកម្មរួម ប៉ុន្តែបានបង្ហាញក្នុងបទល្មើសព្រហ្មទណ្ឌដោយឯកឯង ។ ដូច្នេះ ចេតនាផ្ទាល់ ឬចេតនាប្រយោលបានអនុវត្តក្នុងការសម្លាប់ (ផ្ទុយពីបទសម្លាប់រង្គាលដែលមិនអនុញ្ញាតឲ្យមានចេតនាប្រយោល) ។ ក្នុងករណីនៃការស្លាប់របស់ជនរងគ្រោះ វាគ្រប់គ្រាន់ក្នុងការបង្កើតឡើងថា ការស្លាប់ គឺប្រហែលជាលទ្ធផលក្នុងការអនុវត្តនៃគោលបំណងរួមនេះ ដរាបណា អ្នកផ្សំគំនិតក្នុងសហឧក្រិដ្ឋកម្មរួមទទួលស្គាល់ពីការកើតឡើងនៃការស្លាប់ ។

**ចេតនារបស់ នួន ជា និង ខៀវ សំផន**

ពាក់ព័ន្ធនឹងចេតនារបស់ នួន ជា លោកប្រធានបានមានប្រសាសន៍ថា នួន ជា ផ្ទាល់បានទទួលស្គាល់ចេតនាក្នុងការសម្លាប់ជនក្បត់សំខាន់ៗ ហើយជនជាប់ចោទរូបនេះក៏បានចូលរួមក្នុង

ការសម្រេចចិត្តដើម្បីជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញផង ដែរ ។ ការកាប់សម្លាប់ផ្សេងៗទៀត គឺស្ថិតក្នុងចេតនាប្រយោល បើតាមអ្វីដែល នួន ជា បានដឹងក្នុងអំឡុងព្រឹត្តិការណ៍នៃការជម្លៀសប្រជាជនដំណាក់កាលទី១ និងដំណាក់កាលទី២ ។

ក្នុងចក្ខុវិស័យរបស់អង្គជំនុំជម្រះតុលាការកំពូល ខៀវ សំផន បានខកខានក្នុងការចង្អុលបង្ហាញភស្តុតាងទាក់ទិននឹងទឡ្ហីករណ៍របស់លោកដែលថា ជនជាប់ចោទមិនបានដឹងពីស្ថានភាពដោយសារតែ "បទបញ្ញត្តិតឹងរឹងនៃការរក្សាការសម្ងាត់" ។ ខៀវ សំផន ក៏បានប្រឈមមុខជាមួយការរកឃើញពាក់ព័ន្ធទៅនឹងចេតនាផ្ទាល់របស់លោក ប៉ុន្តែលោកបានខកខានក្នុងការបង្កើតឲ្យមានភាពសមហេតុផល ។

ពាក់ព័ន្ធនឹងផ្នែកនៃការទទួលបន្ទុកផ្សេងៗ លោកប្រធានបានជម្រាបគ្រប់ភាគីថា វាពុំមានភាពចាំបាច់ក្នុងការប្រកាសមូលដ្ឋានជំទាស់របស់បណ្តឹងសារទុក្ខទាំងនេះឡើយ ។

## ៥) ការកាត់ទោស

បន្តទៅផ្នែកចុងក្រោយ លោកប្រធានបានប្រកាសថា ការប្រឈមមុខរបស់ នួន ជា ក្នុងការទទួលទោស មិនមានការជំទាស់គ្រប់គ្រាន់លើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ ។ ការធ្វើឲ្យមានបទឧក្រិដ្ឋនេះគួរតែបង្ហាញតាមរយៈការកាត់ទោស និងតាមរយៈបរិបទនៃ "ការពិចារណាដ៏ពេញលេញមួយ" ទៅលើជោគវាសនារបស់ប្រជាជនកម្ពុជា ។ វាពិតជាមានសារសំខាន់ក្នុងការកត់សម្គាល់ថា អង្គហេតុទាំងនោះមិនស្ថិតនៅឆ្ងាយពីព្រឹត្តិការណ៍ទាំងនោះឡើយ ប៉ុន្តែវាបានកើតឡើងក្នុងចន្លោះពេលដ៏យូរមួយ ។ ដូចនេះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចសេចក្តីថា ការដាក់ឲ្យទទួលទោសជាប់ឃុំមួយជីវិតលើជនជាប់ចោទនីមួយៗគឺជាការសមហេតុផល ដូច្នេះហើយ អង្គតុលាការសម្រេចតម្កល់ការកាត់ទោសលើជនជាប់ចោទទាំងពីរ ។

## ការច្រានចោលបណ្តឹងសារទុក្ខដោយសហព្រះរាជអាជ្ញា

លោកចៅក្រម គង់ ស្រ៊ីម បានជូនដំណឹងដល់គ្រប់ភាគី និងសាធារណជនថា សហព្រះរាជអាជ្ញាបានព្រមទទួលថា បណ្តឹងសារទុក្ខពុំបានដោះបន្ទុកលើការដាក់ពិរុទ្ធភាពទៅលើជនជាប់ចោទឡើយ ។ ដោយសារតែបណ្តឹងសារទុក្ខត្រូវតែអះអាងពីកំហុសផ្នែកច្បាប់ ដែលអាចធ្វើឲ្យការសម្រេចចិត្តលែងមានប្រសិទ្ធភាព ។ បណ្តឹងសារទុក្ខរបស់សហព្រះរាជអាជ្ញាត្រូវមិនត្រូវចាត់ទុកថាបានការ ។ បើទោះបីជាយ៉ាងនេះក្តី លោកចៅក្រមបានកត់សម្គាល់ថា បណ្តឹងសារទុក្ខដែលត្រូវបានលើកឡើងដោយជនជាប់ចោទទាំងពីរបានផ្តល់ឱកាសដើម្បីវិភាគផ្នែកនៃសហឧក្រិដ្ឋកម្មរួម និងការវិនិច្ឆ័យលើបទឧក្រិដ្ឋប្រភេទនេះ ។

## ការសម្រេចបញ្ចប់

លោកប្រធានបានប្រកាសថា ផ្នែកខ្លះនៃបណ្តឹងសារទុក្ខរបស់ នួន ជា និង ខៀវ សំផន ត្រូវបានទទួលយក ហើយផ្នែកខ្លះទៀតត្រូវបានច្រានចោល ។

ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដំណាក់កាលទីមួយ តុលាការបដិសេធលើការដាក់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល និងទទួលយកការដាក់ពិរុទ្ធភាពលើបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការធ្វើទុក្ខបុកម្នេញ ក្នុងហេតុផលនយោបាយ និង អំពើអមនុស្សធម៌ផ្សេងទៀត ។

ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដំណាក់កាលទីពីរ តុលាការបដិសេធលើការដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល និងការធ្វើទុកបុកម្នេញក្នុងហេតុផលនយោបាយ ប៉ុន្តែទទួលយកការដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗដែលត្រូវបានកំណត់ដោយអង្គហេតុ និងទទួលយកការដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់ ។

ពាក់ព័ន្ធនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ អង្គតុលាការបដិសេធលើការដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល, បទមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញក្នុងហេតុផលនយោបាយ, ប្រកាសតម្កល់ការកាត់ទោសឲ្យជាប់ឃុំមួយជីវិតលើជនជាប់ចោទទាំងពីរ និងប្រកាសបដិសេធបណ្តឹងសារទុក្ខសហព្រះរាជអាជ្ញា ដោយសារតែអង្គជំនុំជម្រះពុំអាចទទួលយកបាន និងបានបន្ទាប់ថា ជនជាប់ចោទត្រូវតែស្ថិតក្នុងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក រហូតដល់ការផ្ទេរចេញត្រូវបានរៀបចំ ។

**លីអូនី គីរេស្តី**

# ភេរជំណោលផេះផងសល់ពីរបបខ្មែរក្រហម

លោក សាំង ស៊ាន មកពីភូមិមាត់ខ្លានៅជាប់បឹងទន្លេសាប ឡើងទៅរៀននៅវិទ្យាល័យកំពង់ធំ ខេត្តកំពង់ធំតាមដងស្ទឹងសែន ដោយឆ្លងកាត់តាមភូមិផាត់សណ្តាយ ។ ម្តាយរបស់ ស៊ាន មានឈ្មោះថា ភុក ត្រូវជាប្អូនស្រីបង្កើតរបស់យាយយួនដែលចាំជាតិ និងឪពុកជាមេខ្មែរឥស្សរៈ ឈ្មោះលោក សាំង ទ្រី បានចាប់ម្តាយគេកាលពីគាត់មានអាយុទើបតែ១៦ឆ្នាំ ធ្វើជាប្រពន្ធនៅភូមិមាត់ខ្លានាដើមទសវត្សរ៍ឆ្នាំ១៩៥០ គឺ ស៊ាន បាននិយាយប្រាប់ខ្ញុំ ។ សម្លាញ់ សាំង ស៊ាន មានសម្បុរសស្អាត ពាក់ខ្សែចង្កេះមាសមួយខ្សែទម្ងន់១.៥តម្លឹង ជាប្រចាំ ដោយ សាំង ស៊ាន ជាប់និន្នាការយួន ដូច្នេះត្រូវបានខ្មែរក្រហមសម្លាប់នៅឆ្នាំ១៩៧៨ ។ ស៊ាន ធ្លាប់បាននិយាយគាំទ្រអំពីការចាំជាតិរបស់យាយយួន ដែលជាជីដូនរបស់ខ្លួន និងនៅចងចាំបានខ្លះៗដូចខ្ញុំដែរ អំពីប្រវត្តិសាស្ត្រយួនយកដីខ្មែរបាន ហើយប្តូរឈ្មោះដាក់ជាភាសាយួនវិញមានដូចជា ខេត្តពេងដ៏រឺ ឬ តៃនិញ ខេត្តក្រមួនស ឬ រ៉ាត់យ៉ា និង ខេត្តមាត់ជ្រូក ឬ ចូវដុកជាដើម ។ល ។ ពេលដែលស្ងាត់នៅតែពីរនាក់ ស៊ាន ចូលចិត្តច្រៀងចម្រៀង ស៊ិន ស៊ីសាមុត បទជីវិតកម្មករត្បូងឲ្យស្តាប់រហូតដល់ខ្ញុំចាំបទនោះដែរ គឺនិពន្ធទាំងទំនុកច្រៀង និងបទភ្លេងដោយកវី អ៊ុយ ហៃល នៅក្នុងឆ្នាំ១៩៧៤ (ស៊ាន ចាំបទចម្រៀងនេះ ដោយបើកម៉ាញេលួចស្តាប់នៅលើទូកនៅតំបន់រំដោះ) ។ គ្រួសាររបស់សម្លាញ់ ស៊ាន រស់នៅលើទូក ហើយនៅក្នុងឆ្នាំ១៩៧៣-១៩៧៤ បានចេញទូកមកនៅតាមស្ទឹងជីក្រែង ក្នុងស្រុកជីក្រែង ខេត្តសៀមរាប ។ នៅតាមដងស្ទឹងជីក្រែងនេះដើមឡើយនៅរដូវវស្សា កាលបើមានទឹកជន់មកម្តងៗ បណ្តាលឲ្យទឹកហូរចុះមកក្រោមធ្លាក់ទៅកាន់បឹងទន្លេសាប ហើយប្អូនប្រុសពៅរបស់ ស៊ានក៏បានលង់ទឹកស្ទឹងដែលកំពង់ហូរក្តួចខ្លាំងនោះស្លាប់ម្នាក់ ។ ស៊ាន មានរូបរាងសង្ហា ពេលទៅណាមកណាជាមួយគ្នាតែងមានមនុស្សស្រីធ្វើការរាក់ទាក់ និយាយលេងសើចជាមួយមិនដែលខានឡើយ ។ ល្ងាចថ្ងៃមួយក្នុងរដូវប្រាំង យើងដើរទៅដូតទឹកពីរនាក់ ហើយបានជួបនឹងស្ត្រីមេម៉ាយសស្អាតម្នាក់ឈ្មោះ អាន (អ្នកភូមិក្របីរៀល) កំពុងអង្គុយចិតស្វាយចាស់មួយផ្លែបរិភោគ ហើយបានហៅយើងឲ្យចូលហូបជាមួយដែរ ។ ស៊ាន ឆ្លើយតបវិញថា ហូបយ៉ាងដូចម្តេចនឹងកើត បើស្វាយមានតែមួយផ្លែនោះ? ភ្លាមនោះ អ្នកមេម៉ាយ អាន ឆ្លើយតបវិញថា ហូបមួយពីរនាក់បានដែរតើ៎ និយាយមែនទែនណា? ។ល ។

រូបខ្ញុំ រៀននៅអនុវិទ្យាល័យដំដែក ស្រុកសូទ្រនិគម ខេត្តសៀមរាប ។ ក្នុងចំណោមពួកម៉ាកទាំងបួននាក់នេះ មានតែខ្ញុំម្នាក់គត់បានរត់ឆ្លងចូលទៅតំបន់រដ្ឋាភិបាល លន់ នល់ ដោយបានសិក្សារយៈពេលប្រាំឆ្នាំបន្តទៀត នៅក្រុងសៀមរាប និងនៅក្រុងភ្នំពេញ ។ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានដាក់ឈ្មោះឲ្យយើងថា ប្រជាជនថ្មី ឬពួកអា១៧មេសា ។ ជាផលវិបាកគឺចាប់ពីខែមិថុនា ឆ្នាំ១៩៧៧ រហូតដល់ខែកុម្ភៈ ឆ្នាំ១៩៧៨ គឺរយៈពេលប្រាំបីខែ អង្គការខ្មែរក្រហមបានយកខ្ញុំរួមជាមួយយុវជនបួននាក់ទៀតដែលរស់នៅក្នុងភូមិជាមួយគ្នាគឺ៖ លោក ម៉ុក ជន, លោក តុង ហុក, និងលោក អេង ទៅឃុំឃាំងវាស់ដីឲ្យដើរ ព្រមទាំងបង្ខំឲ្យធ្វើការជាទម្ងន់ ១៥ម៉ោងលើ២៤ម៉ោង នៅសំណង់ទ្វារទឹកបង្ហៀរបាក់បែកមួយកន្លែងនៅក្បែរវត្តគីនឹន ឬវត្តថ្មីដែលជាបណ្តាញរបស់ទំនប់ម្កាក់ ក្នុងឃុំគោកធ្លកលើ ស្រុកជីក្រែង ។ អ្វីដែលនឹកស្មានមិនដល់នោះគឺ ក្រោយពេលដែលខ្ញុំរួចទោសចេញផុតពីទំនប់ម្កាក់បានមួយរយៈមក ទាំងបួននាក់ដែលធ្លាប់ធ្វើការរួមរស់ជាមួយខ្ញុំនោះ ត្រូវបានអង្គការយកទៅសម្លាប់ចោលជាបន្តបន្ទាប់ ។ ចាប់ពីឆ្នាំ១៩៧០-១៩៧៩ ខ្ញុំត្រូវប្រឈមនឹងជីវិតបង់ដោយព្រហ្លិខិតតាមគំរាមកំហែងនៅគ្រប់ជំហាន ដោយម្តងសង្រ្គប់ផុតនៅចំពីមុខ និងម្តងទៀត បង្រ្គប់រំលងហួសផុតទៅក្រោយជាបន្តបន្ទាប់គ្នាមានចំនួន៧លើក ដោយរាប់ទាំងការឃុំឃាំងនៅទំនប់បង្ហៀរខាងលើនេះមួយលើកផង ។ មិនអស់ចិត្តព្រហ្មលិខិតកំណាចបានតាមផ្តាច់សង្ខារខ្ញុំបីលើកបន្ថែមទៀត តែជាលក្ខណៈប្រយោល

គឺការដែលខ្ញុំរស់នៅរៀនសូត្រជាមួយនឹងមនុស្សបីគ្រួសារនៅឆ្ងាយពីគ្នាបន្តិចក្នុងទីក្រុងភ្នំពេញ ។ ក្រោយឆ្នាំ១៩៧៩ មនុស្សប្រុសស្រីទាំងតូចទាំងធំសរុបចំនួន១៩នាក់ ក្នុងបីគ្រួសារខាងលើនេះ ត្រូវបានស្លាប់ទាំងអស់គ្នា ។ គ្រួសារដំបូងគេដែលខ្ញុំបានរស់នៅជាមួយមុំស្តាតចាស់ គឺម្តាយមីងបង្កើតឈ្មោះ សៀវ លឿម ប្តីឈ្មោះ លោកគ្រូ ហេង ស្រីជា ព្រមទាំងកូនៗផង សរុបទៅមានចំនួនប្រាំបួននាក់ បានស្លាប់ទាំងអស់គ្នា នៅភូមិវំលង ឃុំទ្រៀល ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ គ្រួសារទី២ គឺគ្រួសារអ្នកគ្រូ អន នៅមុំឃ្លាំងរំសេវ ដែលជាបងស្រីបង្កើតរបស់សម្លាញ់ អុង វិជ្ជោ ហៅ ប៊ុនធឿន ធ្វើគ្រូបង្រៀនទាំងប្តីទាំងប្រពន្ធ មានកូនពីរនាក់ ព្រមទាំងបងប្រុសឈ្មោះប៊ុនថាន និងប្អូនប្រុសពៅ ឈ្មោះប៊ុនថេវ គឺទាំងអស់គ្នាបានស្លាប់នៅភូមិខ្ទីង ស្ថិតនៅខាងលើព្រែកពោធិ៍ ប្រមាណជាដប់គីឡូម៉ែត្រក្នុងខេត្តកណ្តាល ។ គ្រួសារទីបី គឺនិស្សិតចំនួនបីនាក់ ដែលជួលផ្ទះមួយល្វែងរួមគ្នាជាមួយខ្ញុំនៅមុំស្តាតអូរឡាំពិក យើងបានចាកចេញពីពួកគាត់នៅព្រែកឯង (ផ្លូវជាតិលេខមួយ) ក្រោយបែកភ្នំពេញបានបន្តិចដើម្បីវិលត្រឡប់មកកាន់ស្រុកកំណើតវិញពីរនាក់ឪពុកយើង ។ ថ្ងៃសុក្រ ទី៧ ខែកុម្ភៈ ឆ្នាំ ២០១៤ ខ្ញុំបានតាមទៅរកពួកគាត់ទាំងបីនាក់ ១) លោក កាំង ប្រហៅ ឈន់ ថុង (ធ្វើពេទ្យ) , ២) លោក កាំង បួយ (និស្សិតពេទ្យឆ្នាំទី២) ពីរនាក់នេះជាបងប្អូនបង្កើតនឹងគ្នា ៣) លោក លឹម ទ្រី (និស្សិតពេទ្យឆ្នាំទី២) ម្ចាប់ភ្នែកពាក់វ៉ែនតាជាប្រចាំ ហើយក៏ត្រូវជាបងប្អូនជីដូនមួយនឹងអ្នកទាំងពីរដែរ ។ ខ្ញុំបានទៅដល់ស្រុកកំណើតរបស់ពួកគាត់ដែលស្ថិតនៅតាមផ្លូវជាតិលេខ២ មានចម្ងាយ៦៥គីឡូម៉ែត្រពីទីក្រុងភ្នំពេញ មានឈ្មោះថា ផ្សារស្វាយព្រៃនៅក្នុងភូមិលំចង់ ឃុំលំចង់ ស្រុកសំរោង ខេត្តតាកែវ (សល់តែ១២គីឡូម៉ែត្រទៀត ចូលដល់ក្រុងតាកែវ) ជាលទ្ធផលគឺបាត់ដានពុំមានតម្រុយអ្វីបន្តិចឡើយ ។ ក្នុងចំណោមគ្រួសារទាំងបីខាងលើនេះ បើខ្ញុំរស់នៅជាប់ជាមួយដោយមិនធ្វើការចាកចេញពីគ្រួសារណាមួយទេ ខ្ញុំច្បាស់ជាស្លាប់ទៅជាមួយពួកគាត់ជាក់ជាពុំខានឡើយ ។ យប់ខ្លះនៅក្នុងភូមិយើង គេឲ្យយុវជន និងយុវនារីធ្វើការកាប់ដីដំបូកមាត់ថ្នល់ជាតិដាក់រទេះគោ អូសយកទៅលុបជង្ហុកនៅគល់ស្ពានឆ្អាប (ថ្មបាយក្រៀម) ចុងខាងលិច ។ នៅពេលនោះ ក្មេី ហុក សៀង ពុំសូវដើរទៅណាឲ្យឆ្ងាយពីនារីដែលគេស្រឡាញ់ដែលមានឈ្មោះថា ជា ខាត់នី (ប្រពន្ធរបស់ សៀង សព្វថ្ងៃ) នោះទេ ព្រមទាំងឱនខ្សិបដាក់ត្រចៀកខ្ញុំថា ក្មេី ពេលខ្ញុំដើរទៅជិតនាង ក្រអូបក្លិនម្សៅខ្លាំងអស្ចារ្យណាក្មេី ។ នៅពេលខ្ញុំអង្គុយជិត និងចំអន់ សៀង លេងជាមួយ ជា ខាត់ណា ដែលត្រូវជាបងស្រីបង្កើតរបស់ ជា ខាត់នី ក្មេី សៀង បែរមុខចេញដោយស្រដីតបមកវិញថា មិនត្រូវទេក្មេី ជើងគេទាំងសងខាងកើតរមាស់ក្បាលខ្មៅដំបៅឡើងរឡេះ ព្រមទាំងស្មោះទឹកមាត់ចោលមួយដែតទៀតផង ។

នៅព្រឹកថ្ងៃមួយ ប្រជាជនថ្មីអ្នក១៧ មេសា ប្រុសម្នាក់ដែលគេចាប់មកពីល្វាចឃុំឃាំងនៅក្នុងទីស្នាក់ការសង្កាត់មិនទាន់បានសម្លាប់ផង ក៏ត្រូវបានរត់រួចទាំងចំណងៗ ។ កាលនោះមិត្តក្នុងសង្កាត់ គេបានតម្រូវឲ្យយុវជនទាំងអស់នៅក្នុងភូមិថ្នល់តាសិតស្វែងរកចាប់ជនរងគ្រោះមកវិញ នៅក្នុងព្រៃប៉ែកខាងក្រោមថ្នល់ជាតិលេខ៦ ។ ការស្វែងរកចាប់ជនរងគ្រោះនៅក្នុងពេលនោះ គឺដឹកនាំដោយប្រធានយុវជនភូមិឈ្មោះ សាគឿន និងលោកតាន់ ហុកសៀង ដោយគេបំពាក់អាវុធផុនសេកាសេឲ្យម្នាក់មួយដើម ។ ហុក សៀង មិនឲ្យខ្ញុំទៅណាឆ្ងាយពីគេទេ គឺដើរជាប់តាមក្រោយ និងជូនកាល ខ្ញុំជួយយួរស្បែកជើងកង់ឡានមួយសម្រាប់ឲ្យគាត់ ព្រោះដីសើមពាក់មិនកើត ។ ពេលនោះខ្ញុំគិតនៅក្នុងចិត្តថា ទោះជាឃើញជនរងគ្រោះនៅទីណាក៏ដោយ គឺខ្ញុំលើកលែងឲ្យគេជានិច្ច ។ ទីបំផុត យើងទាំងអស់គ្នារកគេរហូតដល់ថ្ងៃរសៀលទៅហើយ ក៏នៅតែរកមិនឃើញ ហើយការរុករកជនរងគ្រោះត្រូវបានបញ្ចប់ ។

ទោះជាយ៉ាងណា ប្រជាជននៅក្នុងភូមិថ្នល់តាសិតទាំងអស់ពុំដែលដាច់ស្បៀងឡើយ ហោចណាស់ក៏បរិភោគបបរខាប់ដែលដាំនៅក្នុងខ្ទះត្នោតនៅក្នុងសហករណ៍ដែរ តែនៅរដូវប្រាំង គឺបរិភោគបាយជានិច្ច ។ នាថ្ងៃមួយ ប្អូនថ្លៃខ្ញុំម្នាក់ឈ្មោះ លោក ប៊ុនគីម បានបររទេះគោទៅដឹកឈើនៅក្នុងព្រៃនៅភូមិទ័ពសៀម ហើយក៏បានឃើញសត្វសំពោចធំមួយដាច់ក្បាលនៅកណ្តាលផ្លូវរទេះ ដែលជារំពាសល់ពីសត្វស៊ីសាច់ជាអាហារ ហើយក៏យកមកផ្ទះនៅភូមិថ្នល់តាសិត ។ នៅមុខផ្ទះក្រោមដើមកន្ទួត យើងដុតរោលកោសសត្វសំពោចមួយក្បាលនោះ ឆ្អើរឡើងក្រៀម រួចយើងទទួលទានដោយ

មានរសជាតិឆ្ងាញ់ពិសា ។ ពួកខ្មែរក្រហមសម្លាប់ខ្មែរក្រហមគ្នាឯងតៗគ្នាទៅតាមខ្សែនោះ មានជាឧទាហរណ៍ដល់សត្វចិញ្ចឹមនៅផ្ទះឪពុកមា សៀវ ជុនឡៃ គឺ ៖ នៅល្ងាចថ្ងៃមួយ មានសត្វមាន់មេមួយក្បាលបានប្រាសទៅលើសត្វទាតែមួយជើងប៉ុណ្ណោះងាប់នៅក្រោមផ្ទះ លុះយប់ឡើងមានសត្វស្ការមួយក្បាលផ្សេងទៀតចេញមកពីព្រៃក្រោយផ្ទះ ឡើងខាំមាន់មេនោះដល់ទ្រុង ហើយក៏ពាំយកទៅស៊ីបាត់ទៅ ។ ល្ងាចថ្ងៃមួយនៅផ្ទះឪពុកមាយើងដដែល មិត្តនារីឈ្មោះ នឹម បាននាំគ្នាមករកផែកឆេរនៅគុម្ពចេកខាងក្រោយផ្ទះក្បែរអណ្ដូងទឹក ដោយយកឈើឆាយចំបើងទៅកកាយរកថ្នាំពេទ្យនៅទីនោះ គឺរកឃើញដបអំបិលតែប៉ុណ្ណោះ ។ ដំណើរការនៃការផាររួមនៅក្នុងសហករណ៍ គឺឈានទៅមុខជានិច្ច គ្មានបុគ្គល ឬគ្រួសារណាមួយផ្ដាច់ខ្លួនចេញមិនចូលទៅក្នុងសហករណ៍នោះឡើយ ។ ប្រជាជនទាំងអស់នៅក្នុងសហករណ៍ ត្រូវបានបែងចែកជាក្រុមៗ និងលម្អិតនូវតួនាទីភារកិច្ច តួនាទីម្នាក់ៗដោយផ្អែកទៅតាមវ័យ មិនឲ្យទំនេរពីការផារបានឡើយ ។ ស្ត្រីវ័យចំណាស់ខ្លះ គេឲ្យមើលក្មេងៗនៅក្នុងរោងសហករណ៍ ដេញមាន់មិនឲ្យស៊ីស្រូវ ឬចាំសេកនៅឯចម្ការស្រូវជាដើម ។ ចំណែកម្ដាយយើងស្ថិតនៅក្រុមដាំបន្លែក្បែរមាត់ត្រពាំងក្បាលស្វានោះដែរ ។ រីឯបុរសវ័យចំណាស់គេឲ្យវេញខ្សែគោ ត្បាញបង្កី កញ្ជើ ល្អី ចង្អេរ ធ្វើត្បាល់កិនស្រូវ ស្ទាចបាចទឹកស្រែ ចំណែកឪពុកយើងត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅឡូត៍នេសាទស្ទឹងជ្រៅក្នុងឃុំអន្លង់សំណរ ។ បងស្រី សៀវ គឹមជៀវ ហៅ សេង សាវត ស្ថិតនៅវ័យកណ្ដាល គេឲ្យនៅក្នុងក្រុមដកស្ទូង ច្រូតកាត់ បោកស្រូវ ឬកិនស្រូវធ្វើអង្ករ ។ល ។ និងប្អូនស្រី សៀវ សុវុត្ថន ជាកុមារនៅក្នុងកងចល័តកុមារប្រចាំភូមិ ។ ចំណែកបងប្រុស គង់ សារី ហៅ លាន ណូ ស្ថិតនៅក្នុងវ័យកណ្ដាលដែរ ជាក្រុមភ្ជួររាស់ ជីកសំណាប ឬ កណ្ដាប់ កាប់ដីស្រែពង្រាប និងជួសជុលភ្លឺស្រែ ឬកាប់ដីដំបូកពង្រាបក្នុងស្រែធ្វើដីជាដើម ។ល ។

រដូវធ្វើស្រែចម្ការបានឈានចូលមកដល់ យើងក៏ផ្ដើមមានទុក្ខកង្វល់ដ៏ធំមួយនៅក្នុងគ្រួសារ ដោយបងស្រី សៀវ សាវ មានជំងឺដំណើរឈឺភ្លឹកដ៏ធ្ងន់រហូតដល់គ្មានសង្ឃឹមថានឹងបានរស់រានមានជីវិតទៀតផង ។ នៅជំនាន់នោះ គ្មានពេទ្យហ្មអីទេ គឺគេដកចោលអស់ ថ្នាំពេទ្យក៏គ្មានទៀត ពេលមានអាសន្នអន់ក្រម្ដងម្កាល ទាំងអស់គ្នាគឺពឹងផ្អែកតែទៅលើគ្រូចូលរូប គ្រូស្ដោះផ្លុំ និងថ្នាំបុសឈើ បុសស្មៅជាដើម ។ល ។ ជាក់ស្ដែង កូនប្រុសតែមួយគត់ឈ្មោះ ផា របស់បងស្រី សីន់ នៅផ្ទះជាប់គ្នាកើតនៅឆ្នាំ១៩៧០ បានចុកពោះស្លាប់ភ្លាមៗ ដោយជំងឺពោះវៀនខ្នែង ។ យ៉ាងដូច្នេះហើយ ប្រសិនបើមានសមាជិកណាម្នាក់នៅក្នុងគ្រួសារមានជំងឺធ្ងន់នោះ ម្នាក់ៗត្រូវប្រឈមនឹងការអត់ងងុយស្ទើរទល់ភ្លឺ ហើយមានពេលខ្លះ នាំគ្នាចុះជី ធ្វើការរុះរើរបងផ្ទះ ទាំងកណ្ដាលអាធ្រាត្រតាមគ្រូទាយថា របងចាក់ផ្ទះទៀតផងក៏មានដែរ ។ នៅល្ងាចថ្ងៃនោះវេលាសត្វក្របីចូលក្រោល បងស្រីយើងគាត់ឈឺកាន់តែធ្ងន់ដល់កម្រិត ពោលគឺក្រោយពេលដែលរូបគាត់ឮសូរសំឡេងសត្វក្អែកស្រែកយំខុកៗ ៗ នៅក្នុងត្រចៀករួចមក បងស្រីក៏លែងដឹងខ្លួនតែម្ដង និងភ្លាមៗនោះ យើងប្រញាប់ប្រញាល់ គ្រាហ៍រូបគាត់ដាក់តម្រេតនៅលើខ្នើយ ។ ផ្អែកតាមសម្ដីរបស់គ្រូខ្មែរម្នាក់នៅក្នុងភូមិមានឈ្មោះថា សុខ សុវណ្ណ ហៅ គួយ បានឲ្យដឹងថា បងស្រីត្រូវបានខ្មោចមនុស្សស្រីម្នាក់ឈ្មោះ ហៀម នៅក្នុងភូមិថ្នល់តាសិតនេះ ដែរ បានជិតប្ដី ហើយទើបតែចងកស្លាប់ថ្មីៗ នៅឯព្រៃខាងត្បូងភូមិ ចូលមកសណ្ឋិតនៅក្នុងខ្លួនបងស្រី ។ មុននោះយើងបានទៅធ្វើការពឹងពាក់គ្រូខ្មែរមានវ័យចំណាស់ម្នាក់ ស្ថិតនៅក្នុងភូមិជាមួយគ្នាឈ្មោះ តាខ្លែប គឺក្រោយពីយើងធ្វើការរៀបរាប់ប្រាប់គាត់អំពីអាការៈជំងឺនោះរួចមក គាត់ក៏បានឆ្លើយតបមកកាន់យើងវិញថា ឈឺដូចនេះ! គឺរកតែចបកាប់ដីទុកឲ្យហើយទៅប្រសើរជាង ។ លុះភ្លឺឡើងយើងបានទៅរកពឹងពាក់គ្រូខ្មែរម្នាក់ទៀត ពីភូមិកំពង់ម្កាក់ ឬភូមិភ្លើងឆេះ មុខផ្កាមខ្លា មានស្លាយថង់យាមពណ៌ប្រផេះមួយនៅលើស្មា ដើម្បីបានមកជួយសង្គ្រោះបងស្រីបន្តទៀត ។ ពេលមកដល់ផ្ទះយើងភ្លាម គ្រូគាត់ឈររទ្រឹងនៅដីទល់មុខកាំជណ្ដើរផ្ទះ រួចហើយគាត់យកជើងធាក់កាំជណ្ដើរកាំទីមួយជាំងៗ ៗ! ផ្ទួនគ្នាចំនួនបីជើង និងសូត្រគាថារួចទើបបានឈានជើងឡើងទៅលើផ្ទះ ។ យើងលើកគ្រាហ៍បងស្រីពីកន្ទេលឲ្យងើបអង្គុយឡើងដើម្បីបានលោកគ្រូគាត់ធ្វើការស្ដោះ និងផ្លុំឮសូរសំឡេងឡើងគ្រលួចរ៉េតៗ ៗ បីដូចជាសំឡេងមនុស្សយើងហួច បើពុំនោះទេ ឮសូរដូចសំឡេងសត្វពស់យំនៅកណ្ដាលយប់ស្ងាត់យ៉ាងដូច្នោះដែរ ។ បន្ទាប់ពីការស្ដោះ និងផ្លុំឮសូរយ៉ាង

ចម្លែកកម្រមាននេះមក គ្រូចនោះ បានយកភ្លើងធូបដែលកំពុងឆេះទៅអុជស្នា ក ត្រចៀក និងមុខមាត់របស់បងស្រីរលាកឡើងក្រហម ប្រមាណជាពី៧-៨ កន្លែងឯណោះ ។ ការអុជដោយប្រើភ្លើងធូបនេះ បណ្ដាលឲ្យបងស្រីមានអារម្មណ៍ឈឺចាប់ដោយស្រែកអួយៗ ព្ទុសូរឡូលៗមិនច្បាស់ ព្រោះបងស្រីកំពុងស្ថិតនៅក្នុងសភាពពុំដឹងខ្លួនសោះ ។ កាលនោះបងស្រី សៀវ សាវត បាននិងកំពុងមានកូនប្រុសតូចម្នាក់ (គង់ សូនិន) ត្រូវបានប្អូនស្រី សៀវ សុវុត្ថា បីក្មួយទៅរកដោះបងប្អូនជិតខាងមានឈ្មោះ ហ៊ា ឲ្យបៅទាំងកណ្ដាលយប់ស្ងាត់ ក្រោមសម្រែកសត្វខ្លែងស្រាកស្រែកយំគួរឲ្យព្រឺព្រួចក្នុងអារម្មណ៍ ។ ថ្ងៃបន្ទាប់មកទៀត ប្រហែលជាម៉ោង ១០ព្រឹក ខ្ញុំដើររកមើលដកដើមយុក្កានៅតាមដងផ្លូវជាតិយកទៅឲ្យគ្រូខ្មែរនោះ ហើយក៏បានជួបយុវជន និងយុវនារីភូមិយើងជាច្រើននាក់ដើរមកពីដកសំណាបនៅឯចុងភូមិខាងលិច ហើយពួកគេបានសួរខ្ញុំអំពីសុខទុក្ខរបស់បងស្រីយើងដោយយកចិត្តទុកដាក់ ។ ពិនិត្យជារួមឃើញថា ជំងឺបងស្រីពុំបានធូរស្បើយឡើយ និងបានតម្រូវឲ្យរូបខ្ញុំផ្ទាល់ទៅតាមឪពុកយើងដែលគេឲ្យគាត់ធ្វើការនៅឡូត៍នេសាទស្ទឹងជ្រៅដើម្បីឲ្យបានឃើញមុខកូនស្រីច្បងរបស់គាត់ជាលើកចុងក្រោយបង្អស់ ។ ភ្លាមៗនោះ ខ្ញុំជាមួយប្អូនប្រុសជីដូនមួយម្នាក់ឈ្មោះ សៀវ ស៊ុនហេង បានបររទេះគោរបស់បង លានណូ ដោយគោម្មាងឈ្មោះអាត្នោត និងម្ខាងទៀតឈ្មោះ អាទែកបរតាមដងស្ទឹងជីក្រែងចុះទៅក្រោម (ទិសខាងត្បូង) ។ ទៅដល់ភូមិអន្លង់សំណរ ខ្ញុំផ្ញើ ស៊ុន ហេង ឲ្យស្នាក់នៅទីនោះ គ្រាន់បានឃ្វាលគោ និងរង់ចាំខ្ញុំវិលត្រឡប់មកពីស្ទឹងជ្រៅវិញ ហើយក៏បានសុំដោយសារជាមួយទូកគេចុះទៅកាន់ស្ទឹងជ្រៅ ។ អ្នកផ្ទះដែលផ្ញើ ស៊ុន ហេង ឲ្យស្នាក់នៅបណ្ដោះអាសន្ននេះគឺជាមនុស្សដែលធ្លាប់រាប់អានជាមួយឪពុកម្ដាយយើង ប្ដីឈ្មោះ ហង់ ប្រពន្ធឈ្មោះ ឡាយ ហើយយើងបរិភោគបាយនៅទីនោះមួយពេលជាមួយសាច់ជ្រូកឆាខ្ញី ដែលពុំធ្លាប់បានជួបប្រទះសោះឡើយ ។ ប្អូនប្រុស សៀវ ស៊ុនហេង ក៏ធ្លាប់បានរត់ចូលទៅរៀននៅតំបន់ដែលគ្រប់គ្រងដោយរបបសាធារណរដ្ឋខ្មែរ ដែលដឹកនាំដោយលោកសេនាប្រមុខ លន់ នល់ កាលពីគេមានអាយុមិនទាន់ដល់១០ឆ្នាំ រហូតដល់ខ្មែរក្រហមវាយបែកក្រុងសៀមរាប ។ ក្រោយមកដោយ ស៊ុនហេង នៅក្មេងស្ថិតនៅក្នុងវ័យកុមារភាពនៅឡើយ ជាហេតុនាំឲ្យពុំមានការចោមរោមយាយីពីខ្មែរក្រហម ដូចជាប្រជាជនថ្មីពេញវ័យដទៃទៀត នោះឡើយ ។

ខ្ញុំទៅដល់ស្ទឹងជ្រៅរៀងយប់បន្តិចហើយ ក៏ពុំបានជួបមុខឪពុកយើងទៀត ព្រោះគេឲ្យគាត់ទៅធ្វើការនៅកន្លែងមួយឈ្មោះថា បាក់ថ្កោល ដែលឆ្ងាយហួសពីស្ទឹងជ្រៅនោះទៅទៀត ។ដល់ជិតភ្លឺ ខ្ញុំបានយល់សប្ដិព្ទតែសំឡេងមនុស្សប្រុសម្នាក់និយាយដាក់ត្រចៀកខ្ញុំខ្លាំងៗថា បងស្រីរបស់ឯង យើងមិនឲ្យគេជាទេ! លុះដឹងខ្លួនឡើង ខ្ញុំភ័យពេកដេកមិនលក់រហូតទល់ភ្លឺ ។ ដល់ភ្លឺឡើង ខ្ញុំបានពឹងពាក់មនុស្សប្រុសម្នាក់ឈ្មោះ ហាន់ ដែលជាកូន ប្រុសរបស់ អ៊ំ ហង្ស ជាពលករធ្វើការនៅទីនោះ ឲ្យគេជូនទៅជួបមិត្ត សន ជាប្រធានឡូត៍ស្ទឹងជ្រៅ ។ ពេលជួបមិត្ត សន យើងបានសុំអនុញ្ញាតពីគេឲ្យឪពុកយើងបានវិលទៅកាន់សហករណ៍មួយរយៈសិន ព្រោះដ្បិតកូនស្រីគាត់ពេលនេះកំពុងតែមានជំងឺឈឺខ្លាំង រង់ចាំឪពុកវិលពីបាក់ថ្នោលស្ទឹងជ្រៅនេះទៅវិញ ។ ជាមួយនោះ ខ្ញុំក៏បានធ្វើការផ្ដាំទុកដាក់ជាមួយឈ្មោះ ហាន់ ឲ្យគេជួយផ្ដល់ដំណឹងទៅឪពុកយើងនៅឯបាក់ថ្នោលនោះផង ដើម្បីឲ្យគាត់បានដឹងរឿងនេះជាបន្ទាន់ ។ ចប់កិច្ចការនេះភ្លាម ខ្ញុំបានសុំដោយសារជាមួយទូកពូម្នាក់ឈ្មោះ តឿ ត្រូវជាឪពុកបង ណៃ ប្រពន្ធឈ្មោះ ឈន់ ជាកូនស្រីរបស់អ៊ំ ហង្ស ដែរ ដោយគាត់ជាអ្នកអុំខាងមុខទូក ឯខ្ញុំអុំនៅខាងកន្សៃទូក ។ ចូលមកដល់ស្ទឹងជីក្រែង គឺមានកំប្លោកច្រើនណាស់ដែលជាឧបសគ្គ ។ មកដល់ភូមិអន្លង់សំណរវិញ យើងពីរនាក់បានបន្តដំណើរដោយរទេះគោត្រឡប់ទៅភូមិថ្នល់តាសិតវិញ ដោយ ស៊ុនហេង ជាអ្នកបររទេះ ចំណែករូបខ្ញុំអង្គុយនៅកណ្ដាល ។ ខ្ញុំមានអារម្មណ៍ខុសពីគេបើអង្គុយបររទេះ ហើយកាន់ខ្សែគោ និងកាន់រំពាត់ ជាពិសេសនៅពេលស្រែកដេញគោម្ដងៗ គឺមានអារម្មណ៍តានតឹង ហេវហត់ខ្លាំងណាស់ មិនខុសគ្នាពីការកាប់ឈើប៉ុន្មានឡើយ ។ នៅពេលមកដល់ភូមិថ្នល់តាសិត ខ្ញុំភ័យអរៗ ម៉ោងប្រហែល៥ល្ងាចទៅហើយ មើលពីចម្ងាយឃើញមានមនុស្សជាច្រើនឈរលើភ្លឺស្រែសែសិបនៅចំពីមុខផ្ទះយើង ខ្ញុំភ័យណាស់ព្រោះពុំចង់ឃើញទិដ្ឋភាពយ៉ាងដូច្នេះទេ ខ្ញុំក៏ចុះពីលើរទេះគោ ដើរសំដៅទៅកាន់ដើមយាងក្បែរនោះ ទុកឲ្យ ស៊ុនហេង បររទេះគោចូលផ្ទះតែម្នាក់ឯងចុះ ។ នៅក្បែរគល់

យ៉ាង ខ្ញុំបានលួចមើលទិដ្ឋភាពនៅពីមុខផ្ទះយើងម្តងទៀតដោយយកចិត្តទុកដាក់ គឺលួចមើលសន្សឹមៗឲ្យឃើញរូបភាពនោះបន្តិចម្តងៗ តែនៅមើលមិនឃើញដដែល ។ ស៊ិនហេង ដោះគោចេញពីរទេះរួចហើយទើប ខ្ញុំដាច់ចិត្តទាំងប្រថុយប្រថានឈានជើងដើរតម្រង់ទៅផ្ទះ ។

ពេលនោះភាពចម្លែកមួយក៏បានស្តែងឡើងនៅចំពោះមុខ គឺប្អូនស្រី សៀវ សុវុត្ថា គេចូលរូបលោកតា បែកផ្សែងដែលជាគ្រូប្រចាំត្រកូល ។ ចំពោះមនុស្សដែលចោមរោមមើលនៅទីនោះ គឺគេមើលប្អូនស្រីខ្ញុំដែលគ្រូចូលរូបឯណោះវិញទេ ។ នៅពេលឡើងទៅដល់លើផ្ទះ មនុស្សនៅទីនោះទាំងអស់គ្នាបានផ្តោតក្រសែភ្នែកមើលមកកាន់រូបខ្ញុំ តែខ្ញុំសង្កេតមើលទឹកមុខអ្នករាល់គ្នានៅពេលនោះប្រែជាញញឹមញញែមទៅវិញ ព្រោះត្បិត បងស្រីយើងដឹងខ្លួនឡើងវិញតិចៗ តែស្ថិតនៅក្នុងភាពវង្វេងវង្វាយ មិនទាន់ស្គាល់ប្តី និងកូនៗនៅឡើយទេ ។ ការដែលបានធូរស្បើយពីជំងឺនេះ គឺអាស្រ័យដោយបានគ្រូខ្មែរនៅក្នុងភូមិជាមួយគ្នាឈ្មោះ សុខ សុវណ្ណ ហៅ គួយ ជាអ្នកយកអាសា ។ ទាំងអស់គ្នាមានការធូរស្រាលក្នុងចិត្តឡើងវិញ ហើយឃើញស្នាមភ្លើងធូបដែលគ្រូនៅភូមិកំពង់ម្កាក់អុជពីថ្ងៃមុនលើខ្លួនបងស្រីនោះ បានប្រែទៅជាពណ៌ខ្មៅវិញ ។ លោកគ្រូ គួយ បានដាក់បញ្ញើគឺតីងរីង មួយដោយមិនឲ្យបងស្រីគេងលង់លក់ក្នុងវេលាដែលសត្វក្របីចូលក្រោលជាដាច់ខាត ។ ដើម្បីឲ្យបម្រាមនេះមានប្រសិទ្ធភាពរាល់ល្ងាចនាពេលថ្មើរនោះ ខ្ញុំមាននាទីជាអ្នកនិទានរឿងព្រេងខ្មែរ ភាគទី១ ភាគទី២ និងរឿងរាមកេរ្តិ៍ ដែលនៅចងចាំព្រោះទើបចេញមកពីសាលាថ្មីៗ សម្រាប់បំភ្លេចងងុយដេករបស់បងស្រី ។ ក្នុងពេលឈឺភ្លឹកនេះ ក្រោយមកទើបបងស្រីដំណាលប្រាប់ពួកយើងថា ព្រលឹងគាត់បានទៅឃើញឪពុកមាឈ្មោះ ហេង ស្រីជា និង ម្តាយមីងបង្កើតជាប្អូនស្រីពៅខាងឪពុកឈ្មោះ សៀវ លីម ដែលបានបាត់ខ្លួននៅភូមិរំលង ឃុំទ្រៀល ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ ពេលដែលបម្រុងនឹងទៅជួបពួកគាត់ដែលអង្គុយបែរខ្នងដាក់នោះ ស្រាប់តែព្រលឹងបងស្រីហោះប៉ើកៗទៅកាន់ទីផ្សេងខុសពីគោលបំណងទៅវិញគួរឲ្យសោកស្តាយ ។ បងស្រីចងចាំបាននៅពេលកំពុងឈឺដោយឃើញបងថ្លៃជីដូនមួយប្រុសឈ្មោះ ខៀវ គីមហ៊ាន មកពីកំពង់ក្តីមើលឃើញមុខគាត់លេចឡើងនៅកៀនជ្រុងជញ្ជាំងខណ្ឌមាត់ទ្វារផ្ទះក្នុងខណៈដែលគាត់ទើបនឹងដឹងខ្លួនបានតិចៗនៅឡើយ ។ រយៈពេលប៉ុន្មានថ្ងៃក្រោយមកទៀត ទើបឃើញឪពុកយើងគាត់ធ្វើដំណើរពីបាក់ថ្លោលមកដល់ផ្ទះនាពេលល្ងាច ដោយគាត់ស្លៀកខោពណ៌ទឹកប៊ិចក្រោមក្បាលជង្គង់បន្តិច និងពាក់អាវដៃវែងពណ៌ទឹកដោះគោពាក់មួកស្លឹកត្នោត មានស្តាយបង្ហេចខោអាវ ហើយស្នាម្ចាងទៀតស្ពាយថង់ត្រីងៀតព្រមទាំងផ្ចិតបក់មួយធ្វើពីស្លាបសត្វទុង ។ យើងទាំងអស់គ្នាកក់ក្តៅក្នុងចិត្តណាស់ ព្រោះបានឃើញបងស្រីគាត់បានធូរស្រាលពីជំងឺផង ថែមទាំងបានឪពុកយើងត្រឡប់មកពីឆ្ងាយវិញទៀតផង ព្រោះគាត់ចេញទៅធ្វើការនៅស្ទឹងជ្រៅប្រហែលជាមួយខែមកហើយ ។ នៅល្ងាចថ្ងៃដដែលនោះ ខ្ញុំបានស្តាប់ឮម្តាយយើងត្អូញត្អែរប្រកបដោយការសោយសោកប្រាប់ទៅឪពុកយើងតិចៗនៅចុងរានបាយខាងក្រោយផ្ទះថា អាណិតកូនស្រីណាស់ ស្នាបបាតដៃកូនស្រីមើលទៅឃើញក្រិនស្ទើរតែគ្រប់ម្រាមពិសេសជាងនេះទៅទៀតនោះគឺ នៅលើគែមមេដៃខាងឆ្វេងមានស្នាមមុតសុសសាច់ទៅដោយម្ជុលដេរ ប្រសិនបើកូនស្រីម្តេចម្តានៅក្នុងពេលនោះទៅ ម៉្លេះសមម្តាយកើតទុក្ខនឹងស្លាប់ទៅតាមកូនជាក់ជាពុំខានឡើយ ។ ស្តាប់ឮយ៉ាងដូច្នេះ ឪពុកយើងគាត់នៅស្ងៀម ព្រមទាំងឱនមុខចុះពុំនិយាយស្តីអ្វីបន្តិចឡើយ ពោលគឺគាត់មានការក្តុកក្តួលនៅក្នុងចិត្តរបស់គាត់យ៉ាងខ្លាំង ។ នៅក្នុងក្រុមគ្រួសារយើងទាំងមូល បងស្រី សៀវ សាវត គាត់មានម៉ាស៊ីនដេរមួយគ្រឿង ហើយបងស្រីមានភារៈជាអ្នកកាត់ដេរសម្លៀកបំពាក់ផ្គត់ផ្គង់នៅក្នុងគ្រួសារ ខោជើងវែងខ្ញុំមួយនោះ បងស្រីច្នៃ ចេញពីខោឡេវមកជាខោដាក់ខ្សែយឺតវិញ ។ ក្រោយមក ពេលខូចខ្សែយឺតអស់ទៅ ខ្ញុំបានយកខ្សែនីឡុងពណ៌បៃតងចងជំនួស និងដើរធ្វើការឲ្យគេរាល់ថ្ងៃ ។ល ។ ចំពោះម្តាយយើង នៅជាយសំពត់ខាងក្រោមរបស់គាត់ៗយកខ្សែមង មកដេរក្តាប់ដោយដៃបន្តប់នៅខាងក្នុងជុំវិញជាយសំពត ដើម្បីនៅពេលឈានជើងដើរទៅមុខកុំឲ្យរ៉ាវរហែក ។ ជំនាន់នោះ សំពត់ ខោ អាវ កន្សែង និង ក្រមាក្រខ្វត់ណាស់ មានបំណះប៉ះពីលើគ្នាជុំខ្លួន គឺ សឹងតែអន់ជាងស្បូមយាចកទៅទៀតក៏ថាបាន ។ ជាងនេះទៅទៀត សូម្បីតែខ្សែវអាវក៏គ្មានថ្មីដែរ មានអ្នកខ្លះគេ ខ្សៀលសំបកពីដុងជ័រធ្វើជាខ្សែវអាវជំនួស

ទៅវិញ ។ មិនដែលស្គាល់ជាតិសាប៊ូកក់សក់ ឬដុសខ្លួននោះទេ ត្រូវបានម្តាយយើងគាត់ដុតដើមដូងបន្ទាធ្វើជាទឹកក្បុងប្រេកដាក់ដបទុកសម្រាប់ប្រើប្រាស់ម្តងម្កាលតែប៉ុណ្ណោះ ។

នៅជិតពាក់កណ្តាលឆ្នាំ១៩៧៨ ទិសអង្គការបានតម្រូវឲ្យប្រជាជនដែលរស់នៅខាងជើងថ្នល់ជាតិធ្វើការរុះរើផ្ទះសម្បែងមករស់នៅខាងត្បូងថ្នល់ជាតិវិញ ។ ដីទំនេរសល់ពីការរើផ្ទះ គឺគេផ្ទេរទៅជាកន្លែងផលិតស្រូវវិញ តែទោះបីជាយ៉ាងណាក៏ដោយប្រជាជននៅតែគេចមិនផុតពីការទទួលទានបបរដដែល ។ ការធ្វើដំណើរដ៏ពេញនិយមជាងគេគឺថ្មើរជើង តែបើបានធ្វើដំណើរដោយគ្រឿងយន្តវិញនោះ ច្បាស់ជាអាយុបង់មិនខានឡើយ ព្រោះខ្ញុំធ្លាប់ជិះឡានទៅ និងមកចូលក្រុងសៀមរាបម្តងដែរ ត្រូវជាប់ឃុំឃាំង៨ខែ ។ នៅថ្ងៃមួយ អង្គការបានយកត្រាក់ទ័រសណ្តោងរ៉ឺម៉កមួយគ្រឿង មកបញ្ឈរចាំដឹកប្រជាជនកូនកាត់ចិន-យួន ចំនួន៧គ្រួសារ (កូនយាយយួនចាំជាតិ) ពីភូមិថ្នល់គាសិតយកទៅកម្ទេចចោលនៅភូមិដុបត្នោត ឃុំពង្រលើ ស្ថិតនៅខាងជើងថ្នល់ជាតិចម្ងាយ២៣គីឡូម៉ែត្រ ។ ពួយិន ក្មេចយកទ្រូដាក់ត្រី ក៏ចុះពីត្រាក់ទ័រដើម្បីទៅយកទ្រូទៅជាមួយ និងមានក្មេងប្រុសម្នាក់ទៀតឈ្មោះ អាលីជើងធំ មិនស្គាល់ថាជាត្រាក់ទ័រទេ ខំស្រែកហៅរថា ហៅ អញបានជិះឡានហើយរ៉ើយ ។ ចំណែកគ្រួសារចិន-យួន មួយគ្រួសារផ្សេងទៀតរស់នៅឆ្ងាយដាច់ពីគេនៅឯមាត់ព្រៃត្រូវបានរួចផុតពីការកាប់សម្លាប់ ។

នៅចុងឆ្នាំ១៩៧៨ ឪពុកយើងរួមជាមួយនឹងឪពុកមាសៀវ ជុនឡៃ បានទៅសុំយកម្តាយបង្កើតរបស់ពួកគាត់ គឺ ឆាយ ស ក្មួយស្រីរបស់ ប៉ូវ គីមស៊ិន និងចៅប្រុសស្រីចំនួនបីនាក់ពីភូមិពោធិ៍សេរី ឃុំកំពង់ក្តី ឲ្យមករស់នៅភូមិថ្នល់គាសិតវិញ ។ នៅភូមិថ្នល់គាសិត ឆាយ ស និងចៅបានរស់នៅជាមួយប្អូនស្រីសៀវ សុវុឌ្ឍា លើផ្ទះគ្រួសារចិន-យួន ឈ្មោះ សេង លុង ដែលគេយកទៅសម្លាប់ចោលអស់ ។

(តទៅលេខក្រោយ)

**សៀវ សុផន**

# ដំណឹងស្វែងរកពូ និងមីង



នាងខ្ញុំឈ្មោះ កប ដាវី ជាកូនរបស់លោកឪពុកឈ្មោះ ពៅ កប ។ ឪពុកខ្ញុំកើតនៅឆ្នាំ១៩៣០ នៅភូមិសូសិតក្រោម ឃុំដំណាក់កន្ទួត ស្រុកកំពង់ត្រាច ខេត្តកំពត ។ គាត់មានឪពុកឈ្មោះ ពៅ កាន់ និងម្តាយឈ្មោះ អ៊ុំ ឆិន ។

ឪពុកខ្ញុំ ពៅ កប បានចូលរួមក្នុងចលនាខ្មែរឥស្សរៈនៅជំនាន់អាណានិគមនិយមបារាំង ។ ក្រោយមក គាត់បានទៅទីក្រុងហាណូយ ប្រទេសវៀតណាម ។

នៅឆ្នាំ១៩៥៤ គាត់បានរៀបការជាមួយប្រពន្ធជនជាតិវៀតណាម និងមានកូនស្រីពីរនាក់ ។ នៅឆ្នាំ១៩៧០ គាត់បានចូលមកកម្ពុជាវិញ ដើម្បីវាយប្រឆាំងនឹងអាមេរិក ហើយក្រោយមកទៀត ខ្ញុំគ្រាន់តែដឹងថាគាត់ត្រូវបានខ្មែរក្រហមសម្លាប់ ។

ជាចុងក្រោយ ខ្ញុំគ្រាន់តែដឹងថា ឪពុករបស់ខ្ញុំមានប្អូនប្រុសឈ្មោះ ពៅ ហ៊ុន និងប្អូនស្រីឈ្មោះ ពៅ ហ៊ីម ។ សព្វថ្ងៃ ខ្ញុំនៅតែចង់ជួប និងសង្ឃឹមថា ពូមីង នឹងបានឃើញខ្ញុំ ហើយអាចមករកខ្ញុំ (ក្មួយ) នៅមន្ទីរពេទ្យធំ (ព្រះកេតុមាលា) ព្រោះសព្វថ្ងៃខ្ញុំជាគ្រូពេទ្យមធ្យមនៅមន្ទីរពេទ្យនេះ ។

**ពីក្មួយ កប ដាវី**

# «សល់មួយគ្រាប់»

## រឿងរ៉ាវ គ្រួសារខ្ញុំ ក្នុងរបបដឹកនាំខ្មៅងងឹត

### ការចងចាំ

#### មុនរបបខ្មែរក្រហម ខែមេសា ឆ្នាំ១៩៧៥

ចាប់តាំងពីពាក់កណ្ដាល ឆ្នាំ១៩៧០ មក ស្ទើរគ្រប់ទីកន្លែង គ្រប់គ្រួសារ មានការពិភាក្សាពីមាត់មួយទៅមាត់មួយ អំពីការទម្លាក់សម្ដេច សីហនុ ចេញពីប្រមុខរដ្ឋពីសំណាក់លោកសេនាប្រមុខ លន់ នល់ និងមានការគាំទ្រពីសហរដ្ឋអាមេរិក ។ កងទ័ព លន់ នល់ បានទម្លាក់គ្រាប់បែកជាច្រើនទៅតំបន់នានា ដែលពួកខ្មែរក្រហមកាន់កាប់ និងតំបន់ដែលពួកយួនវៀតកុង ចូលលុកលុយ និងឈ្លានពានក្នុងទឹកដីកម្ពុជា ។ សូម្បីតែនៅក្នុងបរិវេណសាលារៀនរបស់ខ្ញុំក៏ដោយ ។ ទាំងគ្រូ ទាំងសិស្សជជែកគ្នាអំពីការទម្លាក់គ្រាប់បែកនេះ និងពីការវាយប្រហារគ្នាស្ទើររាល់ថ្ងៃ ។ គ្រូៗបានណែនាំ និងដឹកនាំសិស្សឲ្យជីកត្រង់សេក្បែរៗថ្នាក់រៀន ដើម្បីការពារខ្លួនពីគ្រាប់កាំភ្លើងដែលអាចកើតឡើងដោយចៃដន្យ ។

នៅបរិវេណផ្ទះរបស់ខ្ញុំ ផ្នែកខាងក្រោមជាផ្ទះចាស់ឈើបុរាណមួយខ្នង ដែលជាកេរដំណែលបន្សល់ទុកពីលោកយាយលោកតា ក៏មានជីកត្រង់សេដែរ ។ ខ្ញុំបានឃើញយន្តហោះរបស់ទាហាន លន់ នល់ និងអាមេរិក ហោះសង្កេតការណ៍ស្ទើរតែរៀងរាល់ថ្ងៃពីលើទីក្រុងពោធិ៍សាត់ ។ គ្រប់គ្នានិយមហៅថាយន្តហោះសង្កេតការណ៍នោះថា “ចានស្រាក់” ព្រោះមើលទៅវារៀងដូចជាចានស្រាក់ ។ ក្រោយពីយន្តហោះហោះសង្កេតការណ៍ហោះចេញទៅបាត់មួយសន្ទុះក្រោយមក យើងតែងតែបានឮសូរសំឡេងទម្លាក់គ្រាប់បែកពីទីឆ្ងាយៗ ។ បន្ទាប់មក ក៏ឮដំណឹងពីការស្លាប់ប្រជាជនស្លូតត្រង់ ឆេះផ្ទះសម្បែងរាប់ គោក្របី ជាដើម ។

តាមសាលារៀន មានបិតផ្ទាំងរូបភាពជាគំនូររូបតុក្កតាជាច្រើនបង្ហាញពីសកម្មភាពឃោរឃៅ យង់ឃ្នង កាប់សម្លាប់ លួចប្លន់ពីសំណាក់យួនវៀតកុង និងខ្មែរក្រហម មកលើជនខ្មែរស្លូតត្រង់ តាមទីប្រជុំជន និងជនបទនានា ។

ពេលម៉ោងសម្រាកម្ដងៗ គ្រូៗជុំគ្នា និយាយពីរឿងនយោបាយ និងការងារប្រទេសជាតិ ។ តែគាត់ទាំងអស់គ្នាមិនបានបន្ថយពេលវេលា និងគុណភាពបង្រៀនសិស្សឡើយ ។ គ្រូៗខ្លះ មានមតិគាំទ្រលោក លន់ នល់ ហើយខ្លះទៀត គាំទ្រសម្ដេច សីហនុ តាមការដែលយល់ឃើញរៀងៗខ្លួន ។ ខ្ញុំដូចជាមិនដែលបានឮគ្រូៗនិយាយពីការគាំទ្រ សរសើរ ឬពេញចិត្តក្រុមតស៊ូខ្មែរក្រហមទេ ។

កាលនោះ ខ្ញុំកំពុងរៀននៅសាលាបឋមសិក្សាខេត្តពោធិ៍សាត់ ។ ឪពុករបស់ខ្ញុំបានយកខ្ញុំទៅផ្ញើមិត្តភក្ដិគាត់ជាគ្រូបង្រៀន ដើម្បីឲ្យខ្ញុំបានចូលរៀននៅថ្នាក់ដំបូង ដើមឆ្នាំ១៩៧០ ។ ខ្ញុំបានបន្តរៀន នៅសាលាបឋមសិក្សាខេត្តពោធិ៍សាត់នេះ រហូតដល់ដើមខែមេសា ឆ្នាំ១៩៧៥ ។

បងប្អូនប្រាំនាក់បានចូលរៀនគឺបងស្រីពីរនាក់ រូបខ្ញុំ ប្អូនស្រីម្នាក់ និងប្អូនប្រុសម្នាក់ទេ ដែលបានចូលរៀន ។ ចំណែកប្អូនៗបីនាក់ទៀត នៅក្មេងមិនទាន់គ្រប់អាយុចូលរៀននៅឡើយ ។ ខ្ញុំសប្បាយចិត្តណាស់ ដែលបានទៅសាលារៀន ។ ខ្ញុំចេះអាន ចេះសរសេរ និងគិតលេខជាដើម ជាពិសេស ខ្ញុំបានជួបជាមួយមិត្តភក្ដិជាច្រើន និងបានលេងជាមួយគ្នារៀងរាល់ថ្ងៃ ។ ខ្ញុំពេញចិត្តកម្មវិធីសិក្សាសាលាខ្ញុំណាស់ ហើយក៏ស្រឡាញ់ និងគោរពគ្រូៗ ទាំងអស់ដែរ ។ គាត់បានប្រឹងប្រែងបង្ហាត់បង្រៀនសិស្ស ដោយចិត្តស្មោះត្រង់បំផុតឲ្យសិស្សទាំងអស់មានចំណេះដឹង វិន័យល្អ និងសុខភាពមាំមួន ដើម្បីក្លាយជាទំពាំងស្នងឫស្សីដ៏រឹងមាំ សម្រាប់ការពារ និងកសាងប្រទេសជាតិនាពេលអនាគត ។ រៀងរាល់ព្រឹកល្ងាច មុនចូលរៀន និងចេញទៅផ្ទះ ទាំងគ្រូ ទាំងសិស្ស ត្រូវគោរពទង់ជាតិ និងច្រៀងចម្រៀងជាតិ ដោយចិត្តសប្បាយរីករាយបំផុត ។

ខ្ញុំចាំបានឈ្មោះលោកគ្រូ អ្នកគ្រូបីបួននាក់ដែរ ដូចជាទី១)

អ្នកគ្រូ ជី វើង ទី២) អ្នកគ្រូ ឈូក វណ្ណា ទី៣) លោកគ្រូ កង សុវណ្ណ និងទី៤) លោកគ្រូ ស៊ី ថុន ។ សាលារៀនខ្ញុំ មានទីធ្លាធំទូលាយស្អាតល្អ ហើយអនាម័យណាស់ ។ សាលារៀនមានទីតាំងក្នុងភូមិចម្ការបេកជិតព្រលានយន្តហោះ ។ បន្ទប់រៀនសឹងតែទាំងអស់សាងសង់ពីឈើ ហើយមានតែអគារមួយប៉ុណ្ណោះដែលសង់ពីបេតុង ។ ក្នុងសាលារៀនមានរោងជាងសម្រាប់សិស្សអនុវត្ត និងមានដីវាលធំសម្រាប់ការងារកសិកម្ម និងហាត់កីឡាផ្សេងៗ ។ សិស្សានុសិស្សបានរៀនសូត្រពីការងារដាំដុះបន្លែនានា និងបានរៀនធ្វើសម្ភារផ្សេងៗ ដូចជា តុ កៅអី កន្ទេល អំបោស ឆ្លាក់រូបសត្វពីឈើសម្រាប់តាំងជាដើម ។ តាមកម្មវិធីសិក្សារបស់សាលា គ្រូៗគ្រប់ថ្នាក់ ក៏បាននាំសិស្សទៅកម្សាន្តព្រៃ សិក្សាពីសារប្រយោជន៍នៃដើមឈើ ផ្ទូតទឹកស៊ីង និងទស្សនាសារមន្ទីរចម្លាក់ថ្មកែវដៃ ។ សិស្សម្នាក់ៗត្រូវពណ៌នាអ្វីៗដែលខ្លួនបានឃើញ និងបានយល់ ហើយត្រូវខិតខំធ្វើការទាំងនោះដោយផ្ចិតផ្ចង់បំផុតដើម្បីទទួលបានពិន្ទុល្អ ពេលបូកសរុបចុងឆ្នាំនីមួយៗ ។

ខ្ញុំចាំបានឈ្មោះមិត្តរួមថ្នាក់មួយចំនួន ដែលរៀនតាំងពីតូចជាមួយគ្នា ដូចជា ចេង លីសុខ,ឃីត, ជុំ ថងប៊ុនថុល, ជុំ ថងប៊ុនថេត ឃីវ សុដាន់ថាន់ណារិទ្ធ, លក្ខិណា, សូនី និង សូណា ។ តុមួយមានសិស្សអង្គុយបីនាក់ លាយ សិស្សស្រី និងប្រុស ។

ខ្ញុំចាំបានថា ថ្ងៃចុងក្រោយក្នុងពិធីជប់លៀង សម្រាប់រដូវកាលឈប់សម្រាករយៈពេលខ្លី ឬជាទូទៅហៅថា "វ៉ាកងតូច" និងចូលឆ្នាំខ្មែរនោះ មុនយើងបែកគ្នា សិស្សទាំងអស់បានច្រៀងបទរួមគ្នាមួយ ។ គឺបទ "មិត្តអើយ យើងបែកគ្នានេះ មិត្តអើយបែករហូត ឬមួយយ៉ាងណា? ឬមួយយើងសង្ឃឹមថា យើងបានជួបគ្នាថ្ងៃមួយមិនខាន" ។

ពេលរដូវរំហើយ ក្រោយពីការច្រូតកាត់ស្រូវរួច ខ្ញុំ និងមិត្តរួមសាលា តែងតែដើរកាត់វាលស្រែទៅសាលារៀន ។ ខ្ញុំចូលចិត្តទេសភាពក្នុងស្រុកភូមិខ្ញុំណាស់ ដោយសារខាងក្រោយផ្ទះ មានទេសភាពស្រែដ៏ស្អាត និងមុខផ្ទះមានផ្លូវជាតិ ផ្លូវរថភ្លើង ជាមួយនឹងទេសភាពព្រៃភ្នំ ។ អ្នកភូមិទាំងអស់មានចំណេះដឹងផ្នែកអនាម័យខ្ពស់ ដែលសូម្បីតែតាមដងផ្លូវជាតិ ក៏ស្អាតល្អ មានសណ្តាប់ធ្នាប់ត្រឹមត្រូវណាស់ ។

## គ្រួសារខ្ញុំ

ខ្ញុំកើត និងរស់នៅភូមិមួយជិតក្រុងពោធិ៍សាត់ រហូតដល់ខែមេសា ឆ្នាំ១៩៧៥ ។ គ្រួសារខ្ញុំរស់នៅក្នុងកម្រិតជីវភាពមួយមធ្យមសមរម្យ ។ ឪពុកខ្ញុំឈ្មោះ ខួង សួន ប្រហែលមានអាយុ៣៨ ឬ៣៩ឆ្នាំ ។ ម្តាយខ្ញុំឈ្មោះ សរ ស៊ីនួន ប្រហែលមានអាយុ៣៣ ឬ៣៤ឆ្នាំ ក្នុងឆ្នាំ១៩៧៥ ។

ខ្ញុំ និងបងប្អូនប្រុសស្រីទាំងអស់នៅក្មេងៗនៅឡើយ ។ បងស្រីពីរនាក់របស់ខ្ញុំមានអាយុប្រមាណជាង១២ ឬ១៣ឆ្នាំប៉ុណ្ណោះ ។ បងស្រីទីមួយ ឈ្មោះ សួន វាន្នី និងបងស្រីទីពីរ សួន វណ្ណា វ៉ាម៉ា ។

ខ្ញុំឈ្មោះសួន ណារិទ្ធ គឺជាកូនទីបី ក្នុងគ្រួសារ មានអាយុជាង១០ឆ្នាំ ។ ខ្ញុំមានប្អូនប្រុសស្រីចំនួន៥នាក់ទៀត ។ ប្អូនស្រីទីមួយ ឈ្មោះ សួន វណ្ណារី អាយុ៨ ឬ ៩ ឆ្នាំ និងប្អូនប្រុសទីមួយឈ្មោះ សួន វណ្ណារ៉ា អាយុ៦ ឬ៧ឆ្នាំ ។ បន្ទាប់មកប្អូនប្រុសទីពីរ ឈ្មោះ សួន វណ្ណារ៉េត និងប្អូនស្រីទីពីរឈ្មោះ សួន សុទ្ធារី ដែលខ្ញុំចាំអាយុមិនបាន តែអាយុអ្នកទាំងពីរប្រហែលមិន លើសពី៤ ឬ៥ឆ្នាំ និងចុងក្រោយបង្អស់គឺប្អូនស្រីពៅ ឈ្មោះ សួន ឆវិន្ត ដែលមានអាយុត្រឹមតែ១ខួបប៉ុណ្ណោះនាពេលនោះ ។ បូករួមទាំងឪពុកម្តាយរបស់ខ្ញុំផង យើងទាំងអស់មានសមាជិកសរុបចំនួន១០នាក់ ។ ខ្ញុំសប្បាយណាស់ ដែលមានបងប្អូនច្រើនបែបនេះ ។ បងប្អូនប្រុសស្រីរបស់ខ្ញុំទាំងអស់ស្រឡាញ់គ្នាណាស់ យើងមិនដែលឈ្លោះប្រកែកគ្នាម្តងណាឡើយ ។

លំនៅស្ថានគ្រួសារខ្ញុំ ស្ថិតតាមបណ្តោយ ផ្លូវជាតិលេខ៥ ដែលស្ថិតនៅភូមិអូរស្តៅ ឃុំផ្ទះព្រៃ ស្រុកបាកាន ខេត្តពោធិ៍សាត់ និងមានចម្ងាយប្រហែល២គីឡូម៉ែត្រពីក្រុងពោធិ៍សាត់ ។ ផ្ទះរបស់យើងមានទីតាំងស្ថិតនៅចន្លោះស្ពានដែកពីរ ។ ទីតាំងដីភូមិផ្ទះម្ខាងជាប់នឹងអូរធម្មជាតិ និងម្ខាងទៀតជាប់ផ្ទះអ៊ំស្រីខ្ញុំ ។ នៅចន្លោះស្ពានទាំងពីរសងខាងផ្លូវ មានផ្ទះសរុប ចំនួនប្រាំបួន ។ ផ្ទះប្រាំបីជាគ្រួសារខ្មែរ និងផ្ទះមួយគ្រួសារដែលស្ថិតនៅជាប់ស្ពានម្ខាងទៀត នៅជួរខាងផ្ទះខ្ញុំ មានគ្រួសារដើមកំណើតមកពីវៀតណាម ។ គ្រួសារវៀតណាមនោះបានចាកចេញទៅប្រទេសវៀតណាមវិញ មុនការចូលមកដល់របស់របបខ្មែរក្រហម ។ គាត់មិនបានប្រាប់ពីការចាកចេញដល់អ្នកជិតខាងទេ ។ ទោះបីជាធ្លាប់មានការរាប់អានគ្រួសារខ្ញុំខ្លះៗ ក៏

ដោយ ។ ទល់មុខផ្លូវផ្ទះ ម្ខាងផ្លូវទៀត មានផ្ទះចំនួន៥ ខ្នង ។

ក្រៅពីផ្ទះគ្រួសារអ៊ីស្រី ។ ខ្ញុំខស្សាហ៍ចេញចូលលេងផ្ទះអ្នកជិតខាងទាំងអស់នោះដែរ ។ យើងមិនដែលប្រកាន់ថា អ្នកជិតខាងជាជនជាតិណា ឬមកពីណាទេ ។ អ្នកភូមិយើងរាប់អានគ្នាណាស់ និងជួយយកអាសារគ្នាទៅវិញទៅមក ។ បើផ្ទះណាមួយមានធ្វើនំចំណី ឬបង្អែមច្រើន ។ ចាស់ៗតែងឲ្យកូនៗរបស់ខ្លួន យកចំណី ឬបង្អែមទាំងនោះជូនអ្នកជិតខាង ។ បើមានកូនរបស់គ្រួសារមួយណាមានរឿងអ្វីកើតឡើងតាមផ្លូវ អ្នកជិតខាងជួយភ្លាម ។ បើមានធ្វើពិធីបុណ្យទានអ្វីៗ យើងជួយគ្នាដោយសស្រោកសស្រាំ ។

ភាគច្រើន ក្មេងៗតែងតែមកលេងផ្ទះខ្ញុំ ដោយសារតែមានទីធ្លាដីធំទូលាយ មានស្រះ និងអូរធម្មជាតិ សម្រាប់ស្ទូចត្រី ហើយជារឿយៗ មានបញ្ចាំងភាពយន្តនៅពេលយប់ ព្រោះគ្រួសារអ៊ីស្រីខ្ញុំជាថៅកែរោងភាពយន្តក្នុងខេត្តពោធិ៍សាត់នេះ ។ ម៉្យាង មានតែផ្ទះខ្ញុំមួយគត់ដែលមានសំណង់ធ្វើពីបេតុងជាន់ខាងក្រោម ដែលងាយស្រួលប្រើជញ្ជាំងពណ៌សនេះធ្វើជាអេក្រង់ ។

ផ្ទះគ្រួសារយើង មានទំហំតូចល្មម ប៉ុន្តែដីនៅសល់មុខ និងជុំវិញផ្ទះ មានទំហំធំទូលាយដែលអាចរៀបចំពិធីបុណ្យទាន បានដោយងាយស្រួល ។ ជុំវិញផ្ទះមានដាំដំណាំ និងឈើហូបផ្លែជាច្រើន ។ តាមសងខាងផ្លូវចូលផ្ទះ មានដាំផ្កា ជាលម្អ និងដើមឈើធំម្ប៉ត្រជាក់អមដោយស្រះទឹកធំៗពីរសងខាង ។ ស្រះម្ខាងមានដាំឈូក និងស្រះម្ខាងទៀតដាំព្រលិតគួរឲ្យគយគន់ ។ ខាងក្រោយផ្ទះ ក៏មានស្រះទឹកជ្រៅមួយធំ ដែលជាស្រះមានត្រីច្រើនជាងគេ ។

ក្រុមគ្រួសារបងប្អូនជីដូនមួយខ្ញុំខាងម្ដាយដែលរស់នៅភ្នំពេញ តែងតែមកសម្រាកលំហែកាយនៅផ្ទះខ្ញុំ ។ គាត់តែងសរសើរថាទេសភាពភូមិខ្ញុំស្អាតណាស់ ។

នៅក្រៅរបងខាងក្រោយបរិវេណផ្ទះមានដីស្រែប្រមាណជាង១០ហិកតា ។ ដីស្រែទាំងនោះ ជាកេរដំណែលពីយាយតាខ្ញុំ ។ ដីស្រែទាំងអស់នោះ គ្រួសារខ្ញុំធ្វើស្រូវប្រវាស់ដៃជាមួយកសិករជិតខាងនៅភូមិខាងក្រោយ ដោយចែកផលស្មើគ្នា ។ ក្នុងបរិវេណដីផ្ទះ មានឃ្លាំងមួយធំ ប្រើប្រាស់សម្រាប់ទុកដាក់ស្រូវ និងស្តុករបស់របរផ្សេងៗ ។

គ្រួសារខ្ញុំក៏មានចម្ការក្រូចមួយកន្លែង ដែលមានទីតាំងឆ្ងាយ ហើយត្រូវធ្វើដំណើរតាមផ្លូវក្រួសក្រហម ឆ្ពោះទៅកាន់ប៉ូជនីយដ្ឋានលោកតា ឃ្លាំង មឿង ប៉ុន្តែហួសទៅមុខឆ្ងាយទៀត ។ ខ្ញុំមិនចាំថាចម្ការក្រូចនោះមានទំហំដីប៉ុន្មានទេ ហើយមានទីតាំងក្នុងភូមិណាច្បាស់នោះទេ ។ ខ្ញុំធ្លាប់ទៅលេងចម្ការក្រូចនោះម្ដង ។ ជារៀងរាល់ឆ្នាំ ផ្លែក្រូចពោធិ៍សាត់ និងក្រូចឃ្វិច ត្រូវបានដឹកជញ្ជូនតាមឡានយកទៅលក់នៅព្រំដែនថៃ គឺលក់នៅផ្សារអូរជ្រៅ ។ ផ្លែក្រូចឃ្វិច និងក្រូចពោធិ៍សាត់ទាំងនោះ មានរសជាតិផ្អែមឆ្ងាញ់ណាស់ ។ ឪពុកខ្ញុំជាអ្នកចាត់ចែងរាល់កិច្ចការគ្រប់គ្រងចម្ការ និងលក់ដូរ ។ គាត់សប្បាយនឹងចម្ការក្រូចមួយកន្លែងនេះណាស់ ។

គ្រួសារយើងក៏មានឡ ធ្វើឥដ្ឋ- ក្បឿង មួយកន្លែង ដែលមានទីតាំងនៅក្នុងឃុំរំលេច ជាប់ផ្លូវជាតិលេខ៥ មិនឆ្ងាយពីផ្ទះខ្ញុំប៉ុន្មានទេ ។ ខ្ញុំស្គាល់ទីតាំងនោះច្បាស់ ។

អ្នកជិតខាងទាំងអស់ក្នុងភូមិ និងគ្រួសារយើងរស់នៅដោយរីករាយសុខសាន្ត និងសុភមង្គល ។ ស្រាប់តែមួយរំពេចនោះ អ្វីៗទាំងអស់ត្រូវបានបញ្ចប់ដោយក្រឡាប់ចាក់ ។ កាលនោះ គ្មានអ្នកណាម្នាក់អាចនឹកស្រមៃថា គ្រួសារមួយដែលកំពុងតែរស់នៅដោយសុខសាន្ត ស្រាប់តែត្រូវបែកបាក់ព្រាត់ប្រាស់គ្នាមួយរំពេចសោះ ។ អ្នកភូមិនិយាយថា វាជាសម័យ ឃ្មោកលិច អម្បែងអណ្តែត ។

## ឪពុកខ្ញុំ

បើតាមអ្វីដែលអ្នកជិតខាងខ្ញុំនិយាយ គេថា ឪពុកខ្ញុំធ្វើជា "នាយប៉ូលីស" កាលនៅក្នុងជំនាន់សម្ដេច សីហនុ ។ ប៉ុន្តែ នៅក្នុងរបប លន់ នល់ វិញ គេថាគាត់ធ្វើជា "នាយទាហាន" ។ ពេលណាមួយនោះ ខ្ញុំសួរថា ឪពុកខ្ញុំធ្លាប់ធ្វើការនៅសាលាដំបូងខេត្តពោធិ៍សាត់ ។ មុនឆ្នាំ១៩៧៥ ខ្ញុំគិតថាគាត់ជាមន្ត្រីរដ្ឋការ ធ្វើការនៅសាលាខេត្តពោធិ៍សាត់ ។ គាត់ធ្លាប់និយាយច្រើនពីការងាររបស់គាត់នៅទីនោះ ហើយធ្លាប់នាំខ្ញុំទៅកន្លែងគាត់ធ្វើការម្ដងដែរ ។ ភាគច្រើនគាត់ស្លៀកពាក់ជាស៊ីវិល បើករថយន្តផ្ទាល់ខ្លួនទៅធ្វើការ ។ ម្ដងម្កាល គាត់ស្លៀកពាក់ជាទាហាន ទើបមានអ្នកបើកបររថយន្តប្រភេទហ្ស៊ីបមកទទួលគាត់ដល់ផ្ទះ ទៅកន្លែងធ្វើការ ។

ឪពុកខ្ញុំ មិនសូវនិយាយស្ដីលេងសើចច្រើនទេ ។ ពេលទំនេរពីការងារ គាត់ដាំដំណាំ សម្អាតស្មៅក្នុងបរិវេណផ្ទះ ឬទៅចម្ការក្រូចបាត់ៗ រហូតដល់ល្ងាចទើបត្រឡប់មកផ្ទះវិញ ។

យាយខ្ញុំបាននិយាយថា កាលនៅពីកុមារភាព ឪពុកខ្ញុំបានមកបន្តការសិក្សានៅវិទ្យាល័យស៊ីសុវត្ថិ រាជធានីភ្នំពេញ ដោយស្នាក់នៅក្នុងវត្ត ។ ជំនាន់នោះ ក្នុងខេត្តពោធិ៍សាត់ពុំទាន់មានថ្នាក់សិក្សាកម្រិតវិទ្យាល័យទេ ។

## មុនថ្ងៃ២០ មេសា ១៩៧៥

ប៉ុន្មានថ្ងៃមុនការចូលមកដល់របស់ខ្មែរក្រហម ខ្ញុំហាក់មានអារម្មណ៍មិននឹងនក្នុងចិត្ត ប្រផ្នូលមិនល្អ ។ ខ្ញុំហាក់មានអារម្មណ៍ថានឹងមានអ្វីកើតឡើងចំពោះគ្រួសារខ្ញុំ ។

បងស្រីទាំងពីររបស់ខ្ញុំ ចំណាយពេលវេលាច្រើន ធ្វើកិច្ចការផ្ទះ ហើយភាគច្រើនលេងនៅក្នុងផ្ទះ ដែលជាប្រពៃណីទំនៀមទម្លាប់កូនស្រីក្នុងគ្រួសារខ្មែរ ក៏ដូចជាគ្រួសារដទៃទៀតដែរ សម័យនោះ ។ គាត់ព្យាយាមរៀនសូត្រ ជួយធ្វើកិច្ចការក្នុងផ្ទះជាមួយម្តាយខ្ញុំគ្រប់បែបយ៉ាង ។ ម្តាយខ្ញុំមិនសូវហាមឃាត់ឲ្យខ្ញុំនៅតែក្នុងផ្ទះដូចកូនស្រីទេ ។

ពេលទំនេរ ខ្ញុំចូលចិត្តរត់លេងខាងក្រៅផ្ទះ ឬខាងមុខផ្ទះជាមួយក្មេងៗប្រុសជិតខាង ។ ខ្ញុំឮចាស់ៗឧស្សាហ៍និយាយថា "ពួកខ្មែរក្រហម ភាគច្រើនសុទ្ធសឹងជាអ្នកក្រីក្រជនបទ និងមិនសូវជាចេះដឹងប៉ុន្មានទេ ហើយមិនសូវចេះថ្លឹងថ្លែងវែងឆ្ងាយ និងមានគំនិតចងគំនុំវណ្ណៈជាមួយអ្នកមានធនធាន ។ ខ្ញុំបានយកពាក្យទាំងនេះមកប្រាប់ម្តាយខ្ញុំដែរ តែគាត់ហាក់មិនមានការឆ្លើយតប ឬពន្យល់អ្វីឡើយ ។

ការបាត់ខ្លួនរបស់ឪពុកខ្ញុំ និងការជម្លៀសចេញពីទីរួមខេត្តពោធិ៍សាត់ ពេលខ្មែរក្រហមចូលមកដល់ និងកាន់កាប់ក្រុងពោធិ៍សាត់ ប្រហែលនៅថ្ងៃទី ១៩ ឬ ២០ ខែមេសា ឆ្នាំ១៩៧៥ ។ ពេលនោះគឺជាពេលវិស្សមកាលសម្រាប់សិស្សានុសិស្សទាំងអស់ ហើយក៏ជាពេលឈប់សម្រាកបុណ្យចូលឆ្នាំខ្មែរដែរ ។ កាលណោះ ខ្ញុំមិនសូវបានដឹងអ្វីច្រើនអំពីការរំដោះទីក្រុងភ្នំពេញទេ ។ ប៉ុន្តែ ប៉ុន្មានខែមុនពេលខ្មែរក្រហមបានចូលមកដល់ និងកាន់កាប់ក្រុងពោធិ៍សាត់ មានការផ្សព្វផ្សាយតាមវិទ្យុ និងចាស់ៗនិយាយហូរហែតៗគ្នាថា "ខ្មែរក្រហមបានចូលកាន់កាប់តំបន់ជាច្រើន សឹងពាសពេញផ្ទៃប្រទេសទៅហើយ ។ លោកសេនាប្រមុខ លន់ នល់ ក៏បានចាកចេញទៅបរទេសដើម្បីព្យាបាលជំងឺ ។ គាត់បានតែងតាំងអ្នកបន្ទាប់ពីគាត់ឲ្យមើលកិច្ចការរដ្ឋជំនួសក្នុងពេលអវត្តមាននេះ ។ គេនិយាយថា លោកសេនាប្រមុខ លន់ នល់ បានផ្តាំប្រាប់ប្រជាពលរដ្ឋថា បន្តិចខ្មែរយើងនឹងមានសង្គមមួយដែលប្រជាពលរដ្ឋទាំងអស់គ្នាបានរស់នៅស្មើភាពគ្នា" ។

ពាក្យ "រស់នៅស្មើៗគ្នា" នេះ មានការនិយាយលេង និងវិភាគក្នុងចំណោមមនុស្សពេញវ័យដែរ ។ ចាស់ៗឧស្សាហ៍និយាយថា មានអំពើពុករលួយកើនច្រើនក្នុងរបបដែលសេនាប្រមុខ លន់ នល់ ដឹកនាំ ។ ភាគច្រើនគ្រូៗនិយាយពីរឿងពុករលួយ និងរឿងទំនិញសព្វសារពើឡើងថ្លៃជាដើម ហើយប្រាក់បៀវត្សរ៍ ក៏ចាយមិនគ្រប់គ្រាន់ ។

ប្រជាពលរដ្ឋ ចាប់ផ្តើមមានកំហឹងច្រើនឡើងៗ ពីការទម្លាក់គ្រាប់បែកគ្រប់ទិសទីពីសំណាក់កងទ័ព លន់ នល់ និងទាហានអាមេរិក នៅពេលដែលខ្មែរក្រហមបានចូលកាន់កាប់ក្រុងពោធិ៍សាត់ ។ ម្នាក់ៗយល់ថា ប្រទេសកម្ពុជាស្ថិតនៅក្រោមរបបមួយថ្មី ។ ម្នាក់ៗសង្ឃឹមថា ប្រទេសខ្មែរទទួលបានសន្តិភាពវិញ ។ ភ្លាមៗ ប្រជាជនសប្បាយណាស់ អបអរសាទរនឹងជ័យជម្នះនៃការចូលកាន់កាប់របស់ខ្មែរក្រហម ។ ម្នាក់ៗសប្បាយរីករាយដោយសារសង្គ្រាមបានបញ្ចប់ និងជឿជាក់លើការសម្របសម្រួលរបស់សម្តេច សីហនុ ដូចដែលបានអំពាវនាវឲ្យកងទ័ព លន់ នល់ ដាក់អាវុធចុះ ។

ជារៀងរាល់ថ្ងៃ តាមធម្មតា ពេលព្រឹកឪពុកខ្ញុំទៅធ្វើការ និងត្រឡប់មកផ្ទះវិញនៅពេលល្ងាច ។ ឪពុកខ្ញុំមិនចូលចិត្តពិសាអាហារតាមហាងខាងក្រៅទេ ។ ទោះរវល់យ៉ាងណា ក៏គាត់នៅតែជួបជុំគ្នាដើម្បីស្រស់ស្រូបអាហារពេលល្ងាច ។ ពេលបាយ ឪពុកខ្ញុំតែងតែសាកសួរកូនៗអំពីអ្វីផ្សេងៗដែលយើងបានធ្វើនៅសាលានៅផ្ទះ និងសួរសុខទុក្ខគ្រប់គ្នាជាធម្មតា ។ ម្នាក់ៗត្រូវរៀបរាប់ពីកិច្ចការ និងរឿងរ៉ាវរៀងៗខ្លួននៅក្រោយពេលស្រស់ស្រូបអាហារ ។ បន្ទាប់មក គាត់ក៏ប្រាប់មកយើងវិញម្តងអំពីរឿងរ៉ាវដែលបានកើតឡើងកាលពីថ្ងៃ និងប្រាប់ឲ្យយើងដឹងអំពីអ្វីដែលគាត់នឹងត្រូវធ្វើនៅថ្ងៃស្អែកឡើង ។ យាយតា និងឪពុកម្តាយខ្ញុំតែងតែទូន្មានកូនៗឲ្យឧស្សាហ៍ព្យាយាមរៀនសូត្រ ធ្វើការប្រព្រឹត្តតែអំពើល្អស្រឡាញ់បងប្អូន អ្នកជិតខាង និងស្រឡាញ់មាតុភូមិ ។ ខ្ញុំចងចាំដំបូន្មាននេះរៀងរហូត ។

នៅល្ងាចថ្ងៃទី១៩ ខែមេសា ពេលបាយល្ងាច គាត់បានប្រាប់យើងថា «ថ្ងៃស្អែកប៉ាត្រូវឆាប់ក្រោកពីព្រលឹមជាងថ្ងៃធម្មតាដើម្បីទៅចូលរួមនៅក្នុងកិច្ចប្រជុំមួយនៅសាលាខេត្ត» ។

ប្រហែលជាមាននរណាម្នាក់បានប្រាប់គាត់អំពីរឿងនេះ ខ្ញុំក៏ដឹងមិនច្បាស់ដែរ ។ គាត់បានប្រាប់ថា «អំណាចត្រូវរៀបចំផ្ទេរពីរបប លន់ នល់ ទៅឲ្យខ្មែរក្រហមមុន ហើយគាត់នឹងទៅចូលរួមក្នុងពិធីផ្ទេរអំណាចនៅថ្ងៃស្អែកនេះជាមួយលោកចៅហ្វាយខេត្ត» ។

ឪពុកខ្ញុំនិយាយថា នាយទាហាន និងកូនទាហានជាច្រើននាក់មិនចង់ដាក់អាវុធទេ ។ ដោយមូលហេតុអ្នកទាំងនោះមិនសូវទុកចិត្តខ្មែរក្រហមប៉ុន្មានឡើយ ព្រោះថាពួកខ្មែរក្រហមមានច្រើនក្រុមច្រើនពួក ។ ក្រុមខ្លះបង្កើតឡើងដោយវៀតណាមកុម្មុយនីស្ត ហូជីមិញ និងនៅក្រោមបញ្ជារបស់យួនវៀតកុង ។ ក្រុមខ្លះបង្កើតឡើងដោយក្រុមខ្មែរប្រឆាំងនឹងរបបដឹកនាំរបស់សម្តេច សីហនុ ហើយក្រោមបញ្ជាខ្មែរក្រហមដែលមានចិនកុម្មុយនីស្តជាអ្នកគាំទ្រ ។

ខ្ញុំស្តាប់ដោយយកចិត្តទុកដាក់បំផុតនូវអ្វីៗដែលឪពុកម្តាយខ្ញុំនិយាយប្រាប់ ។ ខ្ញុំបានចងចាំយ៉ាងច្បាស់នូវអ្វីៗដែលឪពុករបស់ខ្ញុំបានប្រាប់កាលពីល្ងាចនោះ ។

ម្តាយខ្ញុំនិយាយថា យើងទាំងអស់គ្នាគួរតែទៅរស់នៅមួយរយៈជិតព្រំប្រទល់ប្រទេសថៃសិន រង់ចាំសភាពការណ៍ស្ងប់ សឹមយើងត្រឡប់មកវិញ ។ ម្តាយខ្ញុំបន្តទៀតថា មានបងប្អូនខាង គាត់បានផ្ញើទូរសារមកឲ្យយើងត្រូវតែទៅជាបន្ទាន់ ។ ប៉ុន្តែប៉ាអល់អែកក្នុងចិត្តមិនយល់ព្រម ។ បើធ្វើដំណើរពីផ្ទះខ្ញុំទៅព្រំប្រទល់ដែនប្រទេសថៃ ប្រើរយៈពេលតែជាងបីម៉ោងប៉ុណ្ណោះ ។ យើងមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់ការចាកចេញនេះដោយងាយស្រួល ។

ខ្ញុំចង់ប្រាប់ប៉ាថា កុំឲ្យទៅចូលរួមដែរ តែស្ទាក់ស្ទើរ ។ កាលណោះ បើសិនជាខ្ញុំធំជាងនេះ ខ្ញុំមុខជាឃាត់ប៉ាខ្ញុំកុំឲ្យគាត់ទៅចូលរួមក្នុងពិធីនោះ ហើយប្រាប់គាត់ឲ្យរត់គេចខ្លួនជាមិនខាន ។ ខ្ញុំមានប្រផ្នូលអាក្រក់ ប៉ុន្តែខ្ញុំមិនទម្លាប់និយាយអ្វីដែលមិនពិត ។ ខ្ញុំអត់ហ៊ាននិយាយប្រាប់គាត់ទេ ។ ខ្ញុំគិតថាឪពុកខ្ញុំក៏មានការសង្ស័យដែរ ប៉ុន្តែគាត់ហាក់មានការទុកចិត្ត និងមិនគិតថា របបថ្មីនឹងកាប់សម្លាប់បញ្ញវន្ត និងប្រជាជនឡើយ ។ គាត់និយាយថា សង្គ្រាមចប់ហើយ ។

អ្នកជិតខាងផ្ទះខ្ញុំជារឿយៗ ក៏បានប្រាប់ឪពុកខ្ញុំដែរថា យើងមិនអាចទុកចិត្ត និងមានជំនឿចិត្តទាំងស្រុងលើខ្មែរក្រហម និងយួនវៀតកុងទាំងអស់នោះទេ ពីព្រោះក្រុមពួកនោះគ្មានកាន់ជំនឿសាសនា មិនប្រើ និងគោរពច្បាប់ទេ ពួកគេក្រឡេចក្រឡុច ចេះប្រើតែច្បាប់ព្រៃទេ ។ ម្យ៉ាងយើងជាសមាជិកនៃក្រុមម្ខាងទៀត ដែលមិនមែនកុម្មុយនីស្ត ហើយធ្លាប់ប្រឆាំងនឹងពួកគេ ។

យប់នោះ អ្នកជិតខាងបានបន្តមកនិយាយលេងជាធម្មតាជាមួយឪពុកខ្ញុំ ។ ពួកគាត់បានរម្លឹករឿងជូរចត់មួយដែលពួកខ្មែរក្រហមនៅឆ្នាំណាមួយនោះ បានសម្លាប់នាយទាហានខេត្តពោធិ៍សាត់ម្នាក់ បើតាមខ្ញុំចាំដូចជា ឈ្មោះ លោក ស័ក្តិបី លី ប៊ុង ។ ខ្មែរក្រហមវះពោះគាត់ រួចប្រកស្មៅ ពេលដែលនាយទាហានរូបនោះទៅចូលរួមនៅក្នុងកិច្ចចរចាមួយជាមួយខ្មែរក្រហម ខ្ញុំក៏ធ្លាប់ឮសូរគ្រូៗនិយាយរឿងនោះម្តង ឬពីរដងដែរ នៅសាលារៀន ។ យប់នោះខ្ញុំគេងមិនលក់ទេ ខ្ញុំនៅចាំសង្កេតមើលសកម្មភាពរបស់ឪពុកខ្ញុំ ។

ស្អែកឡើង ម៉ោង៤ភ្លឺ ថ្ងៃទី២០ មេសា ឆ្នាំ១៩៧៥ ។ ម្តាយខ្ញុំ បងស្រី អង្គុយចាំជូនដំណើរ និងរៀបចំកញ្ចប់អាហារដែលម្តាយខ្ញុំរៀបដាំរួចស្រេចសម្រាប់ជូនប៉ា ។ ខ្ញុំក៏ក្រោកពីព្រលឹមជាងថ្ងៃធម្មតាដែរដើម្បីជូនដំណើរ ។ ឪពុកខ្ញុំ មិនបានយករថយន្តផ្ទាល់ខ្លួនទៅទេ គាត់បានចេញដំណើរជាមួយនាយទាហានម្នាក់ ដែលបើករថយន្តហ្ស៊ីប មកទទួលប៉ាប្រហែលជាម៉ោង៥ភ្លឺ ។ ឪពុកខ្ញុំបានចេញដំណើរទៅមែន ។ អារម្មណ៍ខ្ញុំមិនស្ងប់សោះ រសេះរសោះ ម្តងរត់ទៅផ្ទះអ្នកនេះ ម្តងទៅផ្ទះអ្នកនោះ ដើម្បីសួរពីហេតុការណ៍ផ្សេងៗ ។

ប្រហែលម៉ោង៨ ឬ៩ ព្រឹកថ្ងៃដដែល មានរថយន្តជាច្រើនដឹកកងទ័ពរំដោះខ្មែរក្រហមកាត់ពីមុខផ្ទះខ្ញុំ ពីទិសខាងលិចសំដៅចូលក្រុងពោធិ៍សាត់ ។ រថយន្តមួយបានបន្ថន់ល្បឿន ហើយឈប់ចំពីមុខផ្ទះខ្ញុំ ។ យោធាខ្មែរក្រហមម្នាក់បានលោតចុះពីកាប៊ីនរួចរត់សំដៅយ៉ាងលឿនចូលបរិវេណផ្ទះ ។ គាត់ទាញដៃខ្ញុំអែបគុម្ពផ្កា ហើយប្រាប់ខ្ញុំដោយប្រញាប់ប្រញាល់ថា ឲ្យប្រាប់ប៉ា-ម៉ាក់ ឆាប់នាំកូនៗចេញពីខេត្តពោធិ៍សាត់នេះជាបន្ទាន់ ។ រួចគាត់រត់ឡើងរថយន្តវិញជាប្រញាប់ ។ ភ្លាមៗ ខ្ញុំយកដំណឹងនេះប្រាប់ម៉ាក់ ។ តែគាត់ថារង់ចាំប៉ាត្រឡប់មកវិញសិន ។ **(តទៅលេខក្រោយ)**

**រំហែម សុវណ្ណារិទ្ធិ**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម




មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ វ៉ាន់ថាន់ ពៅដារ៉ា ទូរសព្ទលេខ ០១២ ៨៤៦ ៥២៦ ឬ អ៊ីម៉ែល ៖ *truthpdara@dccam.org* ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។




**សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ

ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ




ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 204, 2016 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.